# ប្រវត្តិ

## ទង់ជាតិ ភ្លេងជាតិ នគររាជ



រ័ត្ន សណ្ដាប់

# ប្រវត្តិ

# ទង់ជាតិ ភ្លេងជាតិ នគររាជ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

00024645

# HISTORY

**OF**
**THE CAMBODIAN NATION FLAG**
**NATION ANTHEM**
**NOKOREACH**

រ័ត្ន សណ្ដាប់
Rath Sandab

អ្នកនិពន្ធ : រ័ត្ន សណ្ដាប់

ចំណងជើង : ប្រវត្តិ ទង់ជាតិ ភ្លេងជាតិ នគររាជ

ការផ្សាយដោយ : ដោយអ្នកនិពន្ធ

កន្លែងផ្សាយ : ភ្នំពេញ

© រក្សាសិទ្ធិ, ព.ស. ២៥៥៦ / គ.ស. ២០១២

លសខអ : ៩៧៨-៩៩៩៦៣-៥៧២-០-៦

ISBN : 978-99963-572-0-6

ព្រះរាជហត្ថលេខាព្រះបាទសម្តេចព្រះបរមនាថ
នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **រ័ត្ន សណ្ដាប់**

អតីតអនុប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

ឋានៈរដ្ឋលេខាធិការ

ឯកឧត្តម ជាទីរាប់អាន

ខ្ញុំ បានទទួលរួចហើយនូវលិខិតរបស់ឯកឧត្តម ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ និង សៀវភៅ ចំនួន ០១ ក្បាល ដែលមានចំណងជើង " **ប្រវត្តិទង់ជាតិ ភ្លេងជាតិ នគររាជ** " របស់ ឯកឧត្តម ដែលបានថ្វាយ ចំពោះខ្ញុំ ។

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ និងសូមជូនពរ ឯកឧត្តម បានប្រកបតែនឹងព្រះពុទ្ធពរ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ឯកឧត្តម ទទួលនូវសេចក្ដីរាប់អាន អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

## ផ្ញើជូន

### ឯកឧត្តម រ័ត្ន សណ្ដាប់

*ជាទីស្រឡាញ់រាប់អាន !*

ខ្ញុំ សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម** ដែលបានផ្ញើជូនសៀវភៅចំនួនមួយក្បាល ដល់ខ្ញុំ ដែលមានបំណងជើងថា " **ប្រវត្តិ ឧទ់ជាតិ ភ្លេចជាតិ នគររាជ** " ដើម្បីខ្ញុំសិក្សាស្វែងយល់។

ជាមួយគ្នានេះដែរខ្ញុំសូមកោតសរសើរដោយស្មោះចំពោះ ឯកឧត្តម ដែលបានចំណាយធនធាន និងពេលវេលាខិតខំស្រាវជ្រាវរៀបរៀង នូវសៀវភៅដ៏មានសារសំខាន់នេះ ផ្ញើជូនមកខ្ញុំ ។

ខ្ញុំសូមប្រសិទ្ធិពរជ័យជូនចំពោះ ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារសូមប្រកបដោយពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម** ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

រាជធានីភ្នំពេញ. ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១១

**ប្រធានរដ្ឋសភា**

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ផ្ញើជូន**

**ឯកឧត្តម រ័ត្ន សណ្ដាប់ អតីតអនុប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា**

**ឯកឧត្តម ជាទីស្រឡាញ់រាប់អាន !**

ខ្ញុំបានទទួលរួចហើយនូវសៀវភៅចំនួនមួយក្បាលដែលមានចំណងជើងថា " **ប្រវត្តិទង់ជាតិ ភ្លេងជាតិ នគររាជ** " ដែលឯកឧត្តមផ្ញើមកជូនខ្ញុំនាពេលកន្លងទៅថ្មីៗនេះ ។

តបចំពោះសមានចិត្ត និងពាក្យពេចន៍ដ៏មានអត្ថន័យប្រពៃថ្លៃថ្លាដែលលើកឡើងក្នុងលិខិតផ្ញើជូនខ្ញុំ ខ្ញុំសូមថ្លែងនូវការកោតសរសើរដោយសុទ្ធចិត្តបំផុតចំពោះឯកឧត្តម ដែលបានខិតខំស្រាវជ្រាវនិពន្ធចងក្រងនូវទម្រង់ទង់ជាតិ អក្សរភ្លេងជាតិនគររាជ និងទំនុកច្រៀង ជាអត្តសញ្ញាណដ៏ពិសេសរបស់ប្រជាជាតិយើង ដែលមានការវិវត្តន៍តាមដំណាក់កាលនៃរបបសង្គមនីមួយៗ ផ្ញើមកជូនខ្ញុំនិងភរិយា ដើម្បីបានសិក្សា ស្វែងយល់ ។

ខ្ញុំនិងភរិយារបស់ខ្ញុំ សូមប្រសិទ្ធពរជ័យជូនចំពោះឯកឧត្តម ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ៖ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១*

**ហ៊ុន សែន**

# មាតិកា

អារម្ភបទ............................................xiii

សេចក្តីផ្តើម............................................១

ជំពូក ១

បឋមកាល

១- អំពីទង់............................................៣

ក. ប្រភពនៃទង់ជាតិ............................................៣

ខ. ប្រវត្តិការប្រើប្រាស់ប្រភេទនៃទង់............................................៦

២- អំពីភ្លេង............................................១៤

ក. ភ្លេងជាតិកាលពីបុរេ............................................១៥

ខ. ដើមកំណើតនៃអក្សរភ្លេង............................................២០

គ. ទម្រង់នៃបទភ្លេង............................................២២

ជំពូក ២

ការវិវត្ត ទង់ជាតិ-ភ្លេងជាតិ

១-ទង់ជាតិ............................................៣១

ក. អំពីពណ៌............................................៣១

ខ. ទង់ជាតិក្នុងទស្សនៈខ្មែរ............................................៣៦

២- ទង់ជាតិ-ភ្លេងជាតិ និងប្រាសាទសិលាក្នុងទស្សនៈនយោបាយ.២០
ក. ផែនដីកម្ពុជាពីឆ្នាំ ១៨៦៣-១៩៤៨.............................. ២០
ក₁. អាណានិគមបារាំងសែសពីឆ្នាំ ១៨៨៧-១៩៤២.... ២៦
ក₂. ការគ្រប់គ្រងដោយជប៉ុន ពីឆ្នាំ ១៩៤២-១៩៤៥.... ២៧
ក₃. អាណានិគមបារាំងសែសពីឆ្នាំ ១៩៤៥-១៩៤៨..... ២៩
ខ. ព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ១៩៤៨-១៩៧០............. ៥០
គ. របបសាធារណរដ្ឋខ្មែរ ពីឆ្នាំ ១៩៧០-១៩៧៥............... ៥៥
ឃ.របបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥-១៩៧៩......... ៦១
ង. របបសាធារណរដ្ឋប្រជាមានិតកម្ពុជា
ពីឆ្នាំ ១៩៧៩-១៩៨៩...................................................... ៦៥
ច.របបរដ្ឋកម្ពុជា ពីឆ្នាំ ១៩៨៩-១៩៩២........................... ៦៩
ឆ.សម័យអ៊ុនតាក់ (UNTAC) ឆ្នាំ ១៩៩២-១៩៩៣........... ៧០
ជ. ខ្មែរនាំគ្នាចុះផ្លូវឆ្ពោះទៅរកសន្តិភាព............................ ៧២

## ជំពូក ៣

## របបរាជានិយម និង សង្គមខ្មែរ

១. ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣..................... ៧៤
ក. ទង់ជាតិ និង បូរណភាពទឹកដី........................................ ៧៥
ខ. អត្ថន័យនៃការគោរពទង់ជាតិ....................................... ៧៧

២. ភេទជាតិ................................................................................ ៨៤
ក. បទទគរាជ.......................................................................... ៨៦
ខ. អត្ថន័យនៃបទទគរាជ............................................................ ៨៧
គ. បទទគរាជជាគ្រឹះនៃ ជាតិ សាសនា ព្រះមហាក្សត្រ. ១០៥
សេចក្តីសន្និដ្ឋាន.........................................................................១១១
ឧបសម្ព័ន្ធ១.................................................................................១១៦
ឧបសម្ព័ន្ធ២................................................................................ ១១៨
ឧបសម្ព័ន្ធ៣................................................................................ ១១៩
ឧបសម្ព័ន្ធ៤.................................................................................១២០
សទ្ទានុក្រម (GLOSSARY).......................................................១២១
គន្ថនិទ្ទេស (BIOGRAPHY)...................................................... ១២៨
អក្ខរក្រម (INDEX).....................................................................១៣២

# អារម្ភបទ

**ខ្មែរ** គឺជាពូជសាសន៍មួយមានប្រពៃណីញញឹមរាក់ទាក់ ស្លូតបូត សុភាពរៀបសារ ចេះជួយយកអាសារគ្នា ទន់ភ្លន់តែមុឹងម៉ាត់ប្រកបទៅដោយថាមពលដ៏ខ្លាំងក្លា នៅពេលដែលប្រើក្នុងករណីចាំបាច់។ ភាពញញឹមរបស់ខ្មែរ ប្រៀបដូចពពួកទេពអប្សរនៅអង្គរវត្ត បើទោះបីមានអ្នកប្រវត្តិសាស្ត្រលើពិភពលោកមកពិពណ៌នាក៏មិនអស់ដែរ។ ព្រោះតែអ៊ីចឹងហើយបានជាអង្គរវត្ត ក្លាយជាអត្តសញ្ញាណជាតិ ព្រមទាំងការចងចាំរបស់ខ្មែរមាននៅក្នុង "**ទង់ជាតិ-ភ្លេងជាតិ**" ជាចំណុចប្រសព្វនៃថ្មើមប្រម៉ាត់របស់ខ្មែរ ។ ដូច្នេះ ៖

ដោយយល់ឃើញថា "**ទង់ជាតិ-ភ្លេងជាតិ**" គឺជានិមិត្តរូបដ៏ពិសិដ្ឋរបស់ជាតិដែលពុំអាចខ្វះបាន ទើបធ្វើឲ្យកូនសៀវភៅនេះកើតជារូបរាងឡើង ។

មិនថាប្រជាជាតិណា សាសន៍ណាទេ នៅក្នុងពិភពលោកយើងនេះគឺគេតែងតែបង្កើត "**ទង់ជាតិ-ភ្លេងជាតិ**" នេះឡើងទៅតាមលំនាំបទ និងរូបភាពផ្សេងៗពីគ្នា ដែលបង្កប់ទៅដោយអត្ថន័យដ៏ជ្រាលជ្រៅ ឧត្តុង្គឧត្តម និង ថ្លៃថ្លាបំផុត សម្រាប់គោរពបូជា។ ដូច្នេះក្នុងគោលបំណងចង់ឲ្យជនរួមជាតិខ្មែរចងចាំនូវអតីតកាល(ប្រវត្តិសាស្ត្រ)របស់ខ្លួនឲ្យបានច្បាស់លាស់ សម្រាប់យកមកធ្វើជាឧបករណ៍រៀបចំសង្គមបច្ចុប្បន្ន និង អនាគតឲ្យប្រសើរ ក្នុងន័យជាប្រយោជន៍ខ្មែរទូទៅ ហើយក៏មិនត្រូវយកប្រវត្តិសាស្ត្រមកធ្វើជាឈ្នាន់ ក្នុងការសងសឹក

ដើម្បីឈ្នះ-ចាញ់គ្នាទេ។

ក្នុងការចងចាំនឹងភាពភ័យរន្ធត់បំផុតរបស់ខ្ញុំ នៅក្នុងប្រវត្តិ-សាស្ត្រគឺរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ពីឆ្នាំ១៩៧៥-១៩៧៩ បានរុញច្រានសង្គមខ្មែរឲ្យវិលត្រឡប់ដើរថយក្រោយ រហូតទៅដល់ប្រវត្តិសាស្ត្រដើមបំផុតនៃមនុស្ស គឺ "សម័យបុព្វកាល" ព្រោះសម័យខ្មែរក្រហមជាសង្គមគ្មានសាសនា និងទីក្រុងដែលយើងអាចហៅបានថា "សង្គមគ្មានអារ្យធម៌ (Non Civilization)" ជាសង្គមគ្មានភាពស៊ីវិល័យ បើទោះបីយើងព្រមទទួលយកនូវភាពរីករាយ និងការឈឺចាប់ខ្លះៗក្នុងប្រវត្តិសាស្ត្រខ្មែរពីមុនៗមកក៏ដោយ ក៏សង្គមខ្មែរនាគ្រានោះ នៅតែរក្សាបាននូវអារ្យធម៌ (Civilization)។

ខ្ញុំរីករាយណាស់ នូវការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) នៅថ្ងៃទី០៧ មករា ១៩៧៩ ហើយបាននាំប្រទេសឲ្យក្លាយជាសង្គមមានអារ្យធម៌ (Civilization) គឺមានសាសនា និងទីក្រុងឡើងវិញ ដែលយើងហៅថាសង្គមមានភាពស៊ីវិល័យ ដូចជាក្នុងទស្សនៈខ្មែរនាសម័យមហានគរដូច្នេះឯង។ អ្វីដែលពោលរៀបរាប់មកនេះ គឺគ្រាន់តែបញ្ជាក់អំពីព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។ អ៊ីចឹងយើងកើតមកត្រូវគិតថា "**អំណាចអាចធ្វើឲ្យជីវិតយើងប្រែប្រួលបាន ប៉ុន្តែមិនអាចលុបបំបាត់នូវប្រវត្តិសាស្ត្ររបស់ខ្លួនបានឡើយ**"។

ក្នុងន័យស្វែងយល់ឲ្យកាន់តែស៊ីជម្រៅច្បាស់លាស់ខ្ញុំក៏បានស្រាវជ្រាវ និងចងក្រង ជាពិសេសអំពីកាលប្រវត្តិ អត្ថន័យ ខ្លឹមសារ និងការវិវត្តនៃ "**ទង់ជាតិ-ភ្លេងជាតិ**" នេះឡើង ដោយបានពឹងពាក់លើឯកសារនានា ព្រមទាំងប្រភពជាច្រើន រួមទាំងការផ្តល់បទសម្ភាសន៍

ការផ្លាស់ប្តូរយោបល់ និងបានការជួយជ្រោមជ្រែងពីគ្រប់មជ្ឈដ្ឋានក៏ពិតមែនក៏ខ្ញុំយល់ថាពុំទាន់គ្រប់គ្រាន់តែជាបុព្វហេតុមួយសម្រាប់ឲ្យអ្នកស្រាវជ្រាវក្រោយៗទៀត ។

ក្នុងនោះមួយអន្លើ លោកសាស្ត្រាចារ្យ **យស ច័ន្ទដារ៉ា** ព្រឹទ្ធបុរសនៃមហាវិទ្យាល័យតូរ្យតន្ត្រី និងលោកសាស្ត្រាចារ្យ **ប៉ែន សំអុល** ជាព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យតូរ្យតន្ត្រី ដែលបានខិតខំជួយផ្តល់យោបល់ កែតម្រូវយ៉ាងផ្ចិតផ្ចង់ និងប្រកបដោយទឹកចិត្តដ៏ប្រពៃ។

តាមរយៈស្នាដៃដ៏តូចស្តើងនេះ ខ្ញុំខិតខំស្រាវជ្រាវ ដោយពុំរង់ចាំអ្វីដែលហៅថា "សុក្រឹត្យភាព" នោះឡើយសម្រាប់អ្នកប្រវត្តិសាស្ត្រ អ្នកស្រាវជ្រាវ អ្នកស្នេហាវប្បធម៌ តែបើខ្ញុំរង់ចាំ ហើយខ្លាចមិនហ៊ានសរសេរនោះ គឺមានន័យថាខ្ញុំកាន់តែពុំទាន់បានបំពេញកាតព្វកិច្ចជូនជាតិមាតុភូមិខ្ញុំទៅទៀត។

ខ្ញុំសូមលំឱនកាយ សូមបួងសួងគោរពដល់វិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ វីរជនខ្មែរស្នេហាជាតិគ្រប់ជំនាន់ ព្រមទាំងអរុក្សអរក្សអ្នកតា, ទេព្តាដែលបានជួយបីបាច់រក្សាការពារនូវ "**ទង់ជាតិ-ភ្លេងជាតិ**" ក៏ដូចជាទឹកដីកម្ពុជាតាំងពីបុព្វេបាននៅគង់វង្សស្ថិតស្ថេររហូតតរៀងទៅ និងសូមឧទ្ទិសកុសលផលបុណ្យ ដែលកើតពីចិត្តដ៏បរិសុទ្ធ ពីកូនសៀវភៅនេះ បើមានជាតិក្រោយមែន សូមឲ្យដួងព្រលឹងវិញ្ញាណក្ខន្ធនៃបុព្វការីជន ទាំងអស់នេះតោងឈោងទៅចាប់ដូចមានចារក្នុងសិលាចារិកនៅស.វទី១១ ក្រោមរាជព្រះបាទឧទ័យាទិត្យទី២ ដែលគេបានរកឃើញនៅនគររាជសីមា (សព្វថ្ងៃប្រទេសថៃ) បញ្ជាក់ពីការស្រឡាញ់ដ៏ជ្រាលជ្រៅអំពីមោទនភាពនៃជាតិខ្មែររបស់

ខ្លួនដែលមានខ្លឹមសារថា "បើផលដែលកើតចេញពីបុណ្យរបស់ខ្ញុំមានមែន ជាតិក្រោយៗសូមឲ្យខ្ញុំធាប់មកកើតនៅកម្ពុជាទៀត"។

ជាទីចុងបញ្ចប់នៃចំណាប់អារម្មណ៍របស់ខ្ញុំ សូមខេមរជនគិតថា "បើកើតមកមិនស្គាល់ចាំឈ្មោះគ្នាចង់រស់គ្រប់គ្នា ត្រូវសាមគ្គីជុំវិញទង់ជាតិ-ភ្លេងជាតិ"។

សូមឱ្យកេរដំណែលអង្គរនៃចក្រភពខ្មែរបានពណ្ណរាយជានិរន្តន៍។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១២

រ័ត្ន សណ្ដាប់

# សេចក្ដីផ្ដើម

"**ទង់ជាតិ-ភ្លេងជាតិ**"គឺជានិមិត្តរូបរបស់ជាតិខ្មែរក៏ដូចជា គ្រប់ជាតិ គ្រប់សាសន៍ ក្នុងលោកទាំងសម័យបុរាណ បច្ចុប្បន្ន តរៀងទៅអនាគតសុទ្ធតែត្រូវការមានប្រទេសហៅថា "**ជាតិ**" សម្រាប់ជាទីជម្រក ដែលមិនអាចខ្វះបាន។ បើសិនពិចារណាអំពី ៖

"**ជាតិ**" គឺសម្គាល់ដោយ "**ទង់**" តំណាងឲ្យប្រទេសមួយ ដោយបញ្ជាក់អំពីអធិបតេយ្យភាព បូរណភាពទឹកដី ជាតិ សាសន៍ និងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ដោយផ្សារភ្ជាប់តាំងពីដើមរៀងមក ដើម្បីឲ្យប្រជាជាតិនីមួយៗចងចាំ និងការពារជាតិកំណើត របស់ខ្លួន ព្រោះមនុស្សកើតមក ត្រូវការរស់នៅក្នុងសង្គម ត្រូវការចិញ្ចឹមបុត្រ ត្រូវការគូសង្សារ ត្រូវការអាពាហ៍ពិពាហ៍ជាដើម។ ដោយ "**ទង់**" ជានិមិត្តរូបជាតិដ៏ពិសិដ្ឋនៃជាតិសាសន៍នីមួយៗ ដូច្នោះឯងទើបគេហៅថា "**ទង់ជាតិ**"។

"**ភ្លេង**" បើនិយាយជារួម គឺជាការសម្ដែង សារតាជាតិ ទឹកចិត្ត និងបំណងប្រជារាស្ត្រ គឺថាប្រជារាស្ត្រមានបំណងយ៉ាងណាក៏បណ្ដោយឲ្យច្រៀងតាមបំណងនោះមិនថាតែមនុស្សទេ សូម្បីតែពពួកសត្វខ្លះក៏គង់បាក់បបខ្វបខ្វាចសម្ញេងភ្លេងដែរ។

ដោយហេតុថា **ភ្លេង** ជានិមិត្តរូបជាតិទើបគេហៅថា "**ភ្លេងជាតិ**"។ អ៊ីចឹងយើងឃើញថា "**ទង់ជាតិ-ភ្លេងជាតិ**" ជាគ្រឿងសម្គាល់ដ៏សំខាន់នៃប្រទេសនីមួយៗនៅក្នុងលោក បើគិតពីក្នុងចំណោមអត្ត-

សញ្ញាណដទៃទៀត។ ដើមហេតុដែលសំខាន់ នៅត្រង់នេះគឺថា "**ទង់ជាតិ-ភ្លេងជាតិខ្មែរ**" មានគ្រប់របប ហើយមានការផ្លាស់ប្តូរជាបន្តបន្ទាប់ គឺបានផ្លាស់ប្តូរទៅតាមរបបនយោបាយប្រទេស ហេតុនេះអ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ កំណត់ការសិក្សាស្រាវជ្រាវនោះគឺ "**ទង់ជាតិ-បទនគររាជភ្លេងជាតិ**" ដែលពីមុននេះស្ថិតក្នុងបរិបថសង្គមនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលអ្នកប្រវត្តិសាស្ត្រហៅថា "**របបសង្គមរាស្ត្រនិយម**" ដែលកាលនោះក្រោមការដឹកនាំដោយ ព្រះករុណា ព្រះបាទនរោត្តម សីហនុ បើនិយាយអំពីប្រវត្តិនៃ "**ទង់ជាតិ-ភ្លេងជាតិ**" នេះមានសភាពអណ្តែត លិច និងអណ្តែតវិញ ប្រៀបដូចព្រះអាទិត្យរះហើយលិច ហើយរះ ដែលអាចហៅបានថាជាករណីពិសេសដ៏កម្រមួយក្នុងរបបនយោបាយសង្គមនៃប្រវត្តិសាស្ត្រកម្ពុជា។

បុព្វហេតុសំខាន់ គឺចង់ឲ្យប្រជាពលរដ្ឋ ទូទាំងប្រទេសជ្រាបថា "**ទង់ជាតិ-បទនគររាជ-ភ្លេងជាតិ**" ដែលខេមរជនប្រុស-ស្រីបានបន្ទឺសូរស័ព្ទ ធ្វើគារវកិច្ចផ្លូវការសព្វថ្ងៃនេះ មានប្រភពមកពីណា? ក្នុងគោលបំណងអ្វី? ដើម្បីអ្វី? អ្វីដែលបានរៀបរាប់មកនេះ គឺក្នុងគោលបំណងចង់ឲ្យខេមរជនប្រុស-ស្រី ស្វែងយល់អំពីសារតា **ទង់ជាតិ-ភ្លេងជាតិ** របស់ប្រទេសខ្លួនតែប៉ុណ្ណោះ។

# ជំពូក ១

# បឋមកាល

## ១- អំពីទង់

*"**ទង់**" គឺជាកញ្ចក់ឆ្លុះបញ្ចាំងនៃជាតិសាសន៍នីមួយៗ ដោយបញ្ជាក់នូវអត្តសញ្ញាណជាតិត្រូវបានប្រើប្រាស់នៅគ្រប់ប្រទេសទាំងអស់ៗ បើពិនិត្យអំពី :*

### ក. ប្រភពនៃទង់ជាតិ

*ជាទូទៅទង់ជាតិត្រូវបានគេសន្និដ្ឋានថា មនុស្សបានប្រើប្រាស់ប្រហែលជាង ៤០០០ ឆ្នាំ មកហើយ[១]ៗ នៅរវាង ៣០០០ ឆ្នាំមុនគ.ស ទង់ជាតិធ្វើពីដែក ហើយត្រូវបានគេរកឃើញទង់នៅក្នុងកាក់របស់ប្រទេសក្រិច និងចម្លាក់ផ្នូរបុរាណរបស់ប្រទេសអេហ្ស៊ីបៗ*

*"**ទង់**" ដើមដំបូងមានឈ្មោះថា* Vexilloid *មកពីពាក្យឡាតាំង* "Latin" *ប្រែថា "មគ្គុទេសក៍" ធ្វើអំពីលោហៈធាតុ ឬ អំពីឈើមានលក្ខណៈដូចជាបង្គោលៗ ប៉ុន្តែក្រោយមកប្រហែលជា ២០០០ឆ្នាំមុនគ.ស ទង់ជាតិត្រូវបានគេយកក្រដាសមកបន្ថែមលម្អ ជាបុព្វហេតុនាំឲ្យយើងឃើញដូចជាទង់ជាតិបច្ចុប្បន្នៗ ទង់ជាតិជាក្រដាសពណ៌ ឬ សម្ភារៈប្រើប្រាស់ជាសញ្ញាសម្រាប់បញ្ជូនសញ្ញាៗ ទង់ជាតិជាសារ*

---

(១) http//Chinese-school-netfirms.com/other-article-flags.html

របស់មនុស្សម្នាក់ ឬក្រុមមួយៗ ចំពោះការប្រើប្រាស់ទង់ជាតិនៅសម័យនោះ ក្នុងន័យដើម្បីផ្ដល់ព័ត៌មាន ឬ ធ្វើសង្គ្រាម ឬ ក៏ជាការសម្គាល់នៅក្នុងការធ្វើសង្គ្រាមថា "**នរណាមិត្ត ឬ នរណាសត្រូវ**" ព្រោះដើមឡើយកងទ័ពស្មៀកពាក់ពិបាកសម្គាល់គ្នាណាស់ៗ

ចំពោះអត្ថន័យនៃការប្រើប្រាស់ពណ៌ក្នុងទង់ជាតិ[២] វិញគឺៈ

- **ពណ៌ក្រហម** ៈតំណាងឲ្យគ្រោះថ្នាក់ ឬសង្គ្រាម
- **ពណ៌ស** ៈតំណាងឲ្យសន្តិភាព ឬការចុះចាញ់
- **ទឹកក្រូច** ៈតំណាងឲ្យសេចក្ដីក្លាហាន ឬការលះបង់
- **ពណ៌បៃតង** ៈតំណាងឲ្យសុវត្ថិភាព ឬក្ដីសង្ឃឹម
- **ពណ៌លឿង** ៈតំណាងឲ្យការប្រុងប្រយ័ត្ន
- **ពណ៌ខ្មៅ** ៈតំណាងការកាន់ទុក្ខ ឬ សេចក្ដីស្លាប់

បើនិយាយអំពីទង់ជាតិ ដែលបានប្រើប្រាស់ជាប់លាប់ជារៀងរហូតមក គឺនៅប្រទេសដាណឺម៉ាក[៣] ព្រោះទង់ជាតិត្រូវបានប្រើប្រាស់នៅរវាងពីស.វទី១៣ រហូតមកដល់បច្ចុប្បន្ន ។

នៅប្រទេសកម្ពុជា "**ទង់**" ត្រូវបានប្រើតាំងពីសម័យព្រេងនាយមកម្ល៉េះៗ បើនិយាយអំពីពាក្យ "**ទង់**" មួយម៉ាត់ គឺគ្របដណ្ដប់ទៅលើវត្ថុដែលមានសណ្ឋាន ទំហំ និងអត្ថន័យ ច្រើនបែបច្រើនយ៉ាងណាស់ៗ ជួនកាលវត្ថុនោះហាក់ដូចជាគ្រាន់តែនិមិត្តសញ្ញានៃកងពលអ្វីមួយ ទ័ពក្ដីពុំមែនជាទ័ពក្ដីៗជួនកាលទៀតហាក់ដូចជាអត្តសញ្ញាណ

---

(២) http//chinese-school.netfirems.com/other-article-flags.html

(៣) en.wikipadia.org/wiki/flag#history

នៃបុគ្គលអ៊ីចឹង ដូចជាទង់ព្រលឹង ដែលអាចារ្យយោគី តែងយកទៅគ្របលើធាតុសពនៅពេលប្រែរូប។ "ទង់" ម៉្យាងទៀតមានរូបរាងសម្បកក្រៅរាងដូចសត្វក្រពើ ដូចនេះគេក៏សន្មតតាមថា "**ទង់ក្រពើ**"[២]។

និយាយរួមទង់ទាក់ទងនឹងសព គេហៅថា "**ទង់ស**" ឬ "**ទង់សព**" ឬ "**ទង់អភិធម្ម**" ដូច្នេះតែម្ដងទៅ ក្នុងន័យតំណាងឲ្យជាតិកំណើតថ្មី ព្រោះខ្មែរបង្កើតអ្វីមួយបង្កប់មកជាមួយនូវអត្ថន័យក្នុងប្រព័ន្ធនៃជំនឿ។

"**ទង់**" ក្នុងទស្សនៈខ្មែរគឺជាវត្ថុដែលមានជីវិត ដូច្នេះហើយ បានជាអាចារ្យត្រូវបើកព្រះនេត្រសិនក្រោយដេរហើយ មុនយកទៅប្រើនៅលើកដំបូង។ ដោយសារទង់ជាវត្ថុមានជីវិត ដូច្នេះហើយបានជានៅពេលលើកទង់ម្ដងៗ គេតែងឃើញមានភាពអធិកអធមខ្លាំងណាស់ ពុំមែនជាកិច្ចដែលធ្វើស្វាត់កំប៉ាំងឡើយ។ ការធ្វើពិធីហ៊ោកញ្ជៀវ គឺក្នុងន័យប្រកូកប្រកាសដល់ឋានទេព្ដា ដើម្បីជាកិច្ចដឹងឮ គឺពុំមានន័យជាការសើចសប្បាយ ក្នុងន័យធម្មតាឡើយ គឺជាការភ្ជាប់ទំនាក់ទំនងឋានមនុស្សទៅនឹងឋានសួគ៌យ៉ាងប្រាកដណាស់។

ដោយអនុលោមទៅតាមសណ្ឋាន និងទ្រង់ទ្រាយរបស់ "**ទង់**" ត្រូវបានគេឲ្យឈ្មោះផ្សេងៗគ្នា ដូចជា ទង់ជាតិ ទង់ជ័យ ទង់សាសនា ទង់ផ្កាលា ទង់ប្រចាំកង ទង់គណបក្សនយោបាយ ស័ព្ទភាសាបាលីដែលគេចំណាំប្រើសម្គាល់ទង់គឺ **ធជៈ (សំ ធ្វជៈ) បដាកៈ និង កេតុ**[៥]។

---

[២] កញ្ញា ម៉ៅ សេងយាន និង អាំង ជូលាន, Khmer Renaisance, លេខ៣, ឆ្នាំ ២០០៨

[៥] សម្ដេចសង្ឃ ជួន ណាត, វចនានុក្រមខ្មែរ, ព.ស ២៥១១, គ.ស ១៩៦៧, បោះពុម្ពលើកទី៥ ទំព័រ២៩៨

មិនតែប៉ុណ្ណោះ "**ទង់**" ក៏ត្រូវបានគេយកប្រើក្នុង ទស្សនៈនយោបាយ គឺបង្ហាញពីការចូលរួមគ្នាជាធ្លុងមួយ ដូចជាពាក្យថា ជ្រោងខ្ពស់ទង់ទាំងពីរគឺ "**ស្នេហាជាតិ និងសាមគ្គីអន្តរជាតិអធន**" ជានិច្ចកាល ត្រូវគួបផ្សំឲ្យទៅជាចរន្តតែមួយ ដែលបោះពុម្ពផ្សាយដោយគណៈឃោសនាអប់រំមជ្ឈឹម, ឆ្នាំ១៩៨១ នៃបក្សប្រជាជនបដិវត្តកម្ពុជា។ ដូច្នេះពាក្យ "**ទង់**" ដែលប្រើនេះ ពុំពាក់ព័ន្ធនឹងប្រភេទនៃទង់គោរពបូជាផ្សេងៗឡើយ។ តែមានន័យថាការចូលរួមសហការគ្នាឲ្យទៅជាកម្លាំងដ៏មហិមាខ្ពស់ត្រដែតឡើងដូចទង់នៃការគោរពអ៊ុចឹងដែរ ។

ដូចនេះទង់បានបង្កប់នូវទស្សនៈពីរសំខាន់គឺទស្សនៈសាសនា និងទស្សនៈនយោបាយ។

## ១. ប្រវត្តិការប្រើប្រាស់ប្រភេទនៃទង់

បុព្វហេតុនាំឲ្យកើតទង់ ប្រហែលជាមានប្រភពពីសញ្ញាសម្គាល់ត្រកូល ឬសម្គាល់កុលសម្ព័ន្ធរបស់មនុស្សពីសម័យដើម។ ការប្រើប្រាស់ទង់ពីដំបូងទី គឺដើម្បីបង្ហាញអត្តសញ្ញាណ ឧត្តមភាព ឬជ័យជម្នះរបស់ខ្លួន ប៉ុន្តែចាប់តាំងពីព្រេងនាយរៀងមក ទង់ត្រូវបានគេនិយមប្រើទាំងសម្រាប់គោលបំណង សាសនា នយោបាយព្រមទាំងពិធីផ្សេងៗទៀត។ ដូចជាក្នុងគម្ពីរ**មហាភារតៈ**បាននិយាយទាក់ទងដល់ **វានរកេតុ** (ទង់ពានរ) ចំណែកពាក្យ **វ្ឫសភ ធ្វជៈ** (ទ្រង់គោឧសភរាជ) ត្រូវបានគេប្រើជាគុណបទ សម្រាប់សម្តែងលក្ខណៈរបស់ព្រះសិវៈ។

បើយើងពិនិត្យនូវការរៀបរាប់អក្សរសាស្ត្រ ក៏មានពាក្យពេចន៍យ៉ាងច្រើន យោងដល់ទង់ដែលគេប្រើនៅក្នុងពិធី ឬឱកាសផ្សេងៗ

ទាំងសម្រាប់ផ្លូវលោក ទាំងសម្រាប់ផ្លូវសាសនា ពិធីផ្សេងៗទៀត។ មានសេចក្ដីយោងច្រើនទៀត បាននិយាយពីការប្រើទង់ជានិមិត្តរូបសម្គាល់រាជរថរបស់ក្សត្រ ពីព្រោះកាលណាគេមើលឃើញពីចម្ងាយនូវទង់លើចុង ផ្ដោលរាជរថ គេអាចកំណត់បានថា ជាព្រះរាជរថរបស់ស្ដេចអង្គណានោះហើយ។ គេប្រើទង់ មិនមែនគ្រាន់តែជាសញ្ញាសម្គាល់កងទ័ព ឬ ជាសញ្ញាសម្គាល់ក្បាលទ័ពប៉ុណ្ណោះទេ ប៉ុន្តែគេប្រើសម្រាប់លើកទឹកចិត្តកងទ័ពផងដែរ។ ដូចដែលគេបានឃើញនៅក្នុងពិធីក្បួនដង្ហែ ព្រះមហាក្សត្រគង់លើដំរី ឬសេះដឹកនាំទ័ព យាងចេញច្បាំង គេឃើញមានទាហានក្រុមអ្នកកាន់ទង់ ក្រុមក្មេង ដែលគេហៅថា "**ព្រះភ្លើង**" ដែលយើងប្រទះឃើញមាន នៅចម្លាក់ប្រាសាទបាគង ប្រាសាទបាយ័ន្ត និងប្រាសាទអង្គរវត្តជាដើម។ បើបរិយាយនៅប្រាសាទបាគង គេអាចពិពណ៌នាបានថា កាលដើមឡើយនៅជញ្ជាំងជាន់ទីប្រាំ មានចម្លាក់សព្វកន្លែង។ ឥឡូវនេះចម្លាក់រេចរិលមើលពុំសូវយល់ ហើយនៅសល់តែផ្ទាំងបន្តិចបន្តួចប៉ុណ្ណោះដែលនៅល្អ។ គេឃើញទ័ពយក្សកំពុងច្បាំងដោយមានទង់មួយកំពុងបាក់ធ្លាក់មកដី។ កន្លងជាងពីរសតវត្សតមក ខ្មែរឆ្លាក់រូបទង់របៀបនេះច្រើននៅអង្គរវត្ត។ មិនតែប៉ុណ្ណោះ ថែវខាងជើងស្លាបខាងលិចនៃប្រាសាទអង្គរវត្ត នៅក្នុងអត្ថបទអក្សរសាស្ត្រ គេបានពិពណ៌នាអំពីដំណើររឿងធ្វើសង្គ្រាមរវាងពួកទេព្តា និង ពួកអសុរៈ ថាសេចក្ដីភិតភ័យក្នុងចំណោមពួកទេព្តាត្រូវបានរលាយបាត់ទៅ នៅពេលដែលគេក្រឡេកឃើញពីចម្ងាយ នូវទង់របស់ព្រះឥន្ទ្រាធិរាជ និង ទង់របស់ទេព្តាសំខាន់ៗដទៃទៀត ដែលបានលេចប្រាកដឡើងក្នុងចក្ខុវិស័យរបស់

គេ ដែលកំពុងប្រយុទ្ធយ៉ាងជាប់ដៃនៅក្នុងសមរភូមិ។ ដោយបានការលើកទឹកចិត្តនេះ ទេព្តាទាំងឡាយក៏បានដេញពួកអសុរៈឲ្យរត់ខ្ចាត់ខ្ចាយអន្តរធានទៅ។ ទិដ្ឋភាពចម្លាក់នៅប្រាសាទបាយ័ន្តថេវខាងកើតប៉ែកខាងត្បូង ក៏បង្ហាញពីប្រវត្តិព្រះបាទជ័យវរ្ម័នទី៧ ក្នុងការនាំក្បួនទ័ពចេញច្បាំង គឺមានក្បួនដង្ហែរដោយទ័ពសេះ, ដំរី, ថ្មើរជើង, មានពាក់អាវក្រោះ ដៃកាន់ខែល ដាវ លំពែង ដឹកស្បៀងអាហារ គ្រឿងកស្តុភាមានអ្នកកាន់ទង់ជ្វាលា ក្រុមភ្លេង មានអ្នកវាយឃ្មោះ អ្នកផ្លុំត្រែស័ង្ខ យ៉ាងអឺកធឹក ទៅជាមួយ ដែលស្ថិតក្រោមការដឹកនាំនៃមេទ័ពជាច្រើននិងនាយម៉ឺន គ្រប់ជាន់ថ្នាក់ជិះលើដំរី សេះ ព្រះរាជាគង់លើដំរីពាក់ម្កុដ អាវក្រោះ ដៃកាន់ដំបងរាជ្យ។ ក្បួនទ័ពត្រូវបាននាំមុខដោយទង់និងភ្លេង។



ចម្លាក់នៅប្រាសាទបាគង ទ័ពយក្សកំពុងច្បាំងដោយមានទង់មួយបាក់ធ្លាក់មកលើដី ហើយទង់របៀបនេះមានច្រើននៅអង្គរ

**ទង់មហារាជៈ** ទង់សម្រាប់មហាក្សត្រម្ចាស់ផែនដីហៅថា "ទង់មហារាជ"[៦] ទង់នេះមានលក្ខណៈ គឺផ្ទៃពណ៌ផ្ទៃមេឃជាយជុំវិញជាពណ៌ក្រហម ត្រង់រវាងកណ្ដាលផ្ទៃប៉ាក់ពណ៌មាសដាក់ពីលើព្រះខ័ន ហើយមានរូបឆ័ត្ររួតមួយគូអមសង្ខាង។ បើពណ៌នាទាំងអស់ទៅឃើញថាមានពណ៌បីដែរគឺ ពណ៌មាស ពណ៌ផ្ទៃមេឃ ពណ៌ក្រហម ទុកជាត្រៃរង្គដូចដើម។ ទង់មហារាជនេះ ប្រើបានចំពោះតែព្រះមហាក្សត្រផែនដី តាមប្រក្រតីត្រូវបង្ហូតនៅជង់ទង់ធំនៅមុខព្រះបរមរាជវាំងនិងប្រាសាទដែលស្ដេចគង់ជាធម្មតានៅក្នុងព្រះបរមរាជវាំង បើមានការត្រូវស្ដេចទៅគង់នៅដំណាក់វាំងឯណាមួយក្រៅពីព្រះបរមរាជវាំងតាំងពី ២៤ម៉ោងទៅ ត្រូវបង្ហូតទង់មហារាជខ្នាតតូចនៅព្រះរាជរថ នោះជាគ្រឿងសម្គាល់ថាស្ដេចគង់នៅក្នុងព្រះរាជរថនោះ ឬជាអ្នកដែលអង្គុយនៅក្នុងព្រះរាជរថនោះ គឺព្រះរាជាម្ចាស់ផែនដី អ្នកនៅជិតខាងត្រូវសម្ដែងសេចក្ដីគោរពតាមសមគួរ។

**ទង់ជ័យៈ** ជាគ្រឿងសម្គាល់ក្នុងសង្គ្រាមប្រសិទ្ធិថា ជាប្រធាននៃជ័យជម្នះ។ ដូចជាគេកំណត់យកថ្ងៃទី៩ វិច្ឆិកា ១៩៥៣ ហើយត្រូវបានគេលើកយកជាទិវាបុណ្យឯករាជ្យជាតិ រៀងរាល់ថ្ងៃទី៩ វិច្ឆិកានៃឆ្នាំនីមួយៗនោះជាអធិបតីនៃទង់ជ័យ។ បើពណ៌នា អំពីការប្រើប្រាស់នៃទង់ជ័យ គឺជាទង់សម្រាប់ស្ដេច សឹក មេទ័ព មេកង ប្រើក្នុងរាជការ សង្គ្រាម ហៅថា "**ទង់ជ័យ**" មានលក្ខណៈ ផ្សេងពីទង់ខាងលើនេះខ្លះ ដូចអធិប្បាយតទៅនេះតាមបែបបុរាណ បើជាទង់ជ័យ

---

[៦] ឧកញ៉ា ទេព វិទូក្រសេម, កម្ពុជសុរិយា, ឆ្នាំគម្រប់១៤ ភាគទី១, ព.ស ២៤៨៥ គ.ស ១៩៤២ ទំព័រ២៩-៣៦

សម្រាប់ព្រះមហាក្សត្រ ម្ចាស់ផែនដី សឹងទ្រង់តំណែងជាស្ដេចសឹក **(ចមពល)** ដោយព្រះអង្គឯងនោះរូបទង់ក៏ដូចជាទង់មហារាជដែលពោល ហើយប្លែកតែនៅចុងដងទង់ធ្វាក់ ជារូបព្រះនារាយណ៍ទ្រង់គ្រុឌ **(គឺព្រះនារាយណ៍គង់លើគ្រុឌ)** ពុំនោះសោតនៅត្រង់កណ្ដាលផ្ទៃទង់ប៉ាក់ដោយសូត្រពណ៌មាសជារូបព្រះនារាយណ៍ទ្រង់គ្រុឌជាជំនួសរូបព្រះខ័នព្រះមហារាជ តាមរឹមជាយជុំវិញប្រដាប់ដោយព្រុយរំយោលដែលធ្វើអំពីសូត្រពណ៌ដ៏វិចិត្រ ។

អ្នកឯទៀត **(ក្រៅអំពីព្រះរាជា)** ដូចយ៉ាងសម្ដេច ព្រះមហាឧបរាជជាដើម បើទទួលតំណែងជាស្ដេចសឹកធំកាន់កាប់ទ័ពហ្លួង (ទ័ពធំ) ជំនួសព្រះរាជាម្ចាស់ផែនដីនោះ នឹងប្រើទង់បែបនេះបាន ក្រៅអំពីស្ដេចសឹកចមទ័ពប្រើមិនបានទេ ។

ចំណែកទង់ជ័យសម្រាប់មេទ័ព មេកងរេ ស្ដេចសឹក ចុះមកមានលក្ខណៈប្រហែលនឹងទង់ជាតិនោះឯង ប្លែកតែនៅចុងដងទង់ធ្វាក់ជារូបហនុមានហោះ ពុំនោះសោតនៅកណ្ដាលផ្ទៃទង់ប៉ាក់ដោយសូត្រពណ៌ស ជារូបហនុមានហោះ **(គ្មានរូបប្រាសាទ)** នៅរឹមជាយជុំវិញប្រដាប់ដោយព្រុយរំយោលយ៉ាងវិចិត្រ ។

បើសង្កេតមើលទង់ជ័យក្នុងកងទ័ពរបស់ព្រះបាទសូរ្យវរ្ម័នទី២ ដែលធ្លាក់ទុកនៅព្រះរបៀងប្រាសាទនគរវត្ត ឃើញថាទង់ជ័យគ្រានោះ គ្មានតួទង់មានតែដង ហើយនិងរូបព្រះនារាយណ៍ ទ្រង់គ្រុឌ រូបហនុមានហោះ នៅចុងដងទង់ប៉ុណ្ណោះ ក្នុងសៀវភៅនិរាសនគរវត្ត របស់សម្ដេច ព្រះយ៉ាដាំរង់រាជានុភាព ហៅទង់នេះថា កបិធ្វជ, គ្រុឌពាហ៍គឺទង់រូបហនុមានហៅថាកបិធ្វជ,ទង់រូបព្រះនារាយណ៍ទ្រង់គ្រុឌ

ហៅថាគ្រុឌពាហ៍ សម្រាប់ប្រើនាំទ័ពក្នុងរាជការ សង្គ្រាម គឺជាទង់ជ័យ នាំទ័ពនោះឯង។ នៅក្នុងព្រះត្រៃបិតក ក៏បានប្រៀបធៀបភិក្ខុទៅនឹងប្រភេទនៃទង់ជ័យដូច្នេះថា ៖

បុគ្គលប្រាំពួកប្រៀបដោយទាហាននេះរមែងមានក្នុងពួកភិក្ខុក៏យ៉ាងនោះឯង។ ភិក្ខុ៥ ពួក តើយ៉ាងដូចម្ដេច។ ភិក្ខុខ្លះក្នុងសាសនានេះគ្រាន់តែឃើញចុងនៃធូលីក៏រុញរាថយក្រោយ មិនតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនៅភាពថយកម្លាំងក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ។ ចុះអ្វីជាចុងធូលីរបស់ភិក្ខុនោះ។ ភិក្ខុក្នុងសាសនានេះបានឮថា ក្នុងស្រុកក្ដី ក្នុងនិគមក្ដី ឯណោះមានស្រីឬកុមារី មានរូបល្អគួររមិលមើលគួរជ្រះថ្លាប្រកបដោយពណ៌នៃសរីរៈដ៏ល្អក្រៃលែង ភិក្ខុនោះលុះបានឮដំណឹងនេះហើយ ក៏រុញរាថយក្រោយ មិនតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យឮប្រាកដនៅភាពថយកម្លាំង ក្នុងសិក្ខាលះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញនេះឈ្មោះថា ចុងនៃធូលីរបស់ភិក្ខុនោះ។ ទាហាននោះឃើញចុងនៃធូលីហើយក៏រុញរាថយក្រោយ មិនហ៊ានតទល់ មិនហ៊ានកាន់សង្គ្រាមមានឧបមា យ៉ាងណាមិញ បុគ្គលនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ បុគ្គលខ្លះក្នុងលោកនេះមានសភាពយ៉ាងនេះឯង។ នេះបុគ្គលទី១ ប្រៀបដោយទាហានរមែងមានក្នុងពួកភិក្ខុ។ មួយទៀតភិក្ខុខ្លះ ក្នុងសាសនានេះអត់ទ្រាំក្នុងចុងធូលីបាន តែលុះឃើញនូវចុងនៃទង់ជ័យហើយក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចបន្តនូវ ព្រហ្មចរិយធម៌ធ្វើប្រាកដនូវភាពថយកម្លាំង ក្នុងសិក្ខាលះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាប

វិញ។ ចុះអ្វីជាចុងនៃទង់ជ័យរបស់ភិក្ខុនោះ។ ភិក្ខុក្នុងសាសនានេះ មិនបានឮថាក្នុងស្រុកក្តី ក្នុងនិគមក្តី ឯណោះ មានស្រ្តី ឬ កុមារីមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌នៃសរីរៈ ដ៏ល្អក្រៃលែង ភិក្ខុនោះលុះបានឃើញនូវរូបស្រី ឬកុមារីនោះហើយ ក៏រួញរាមិនហ៊ានតទល់មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំងក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ នេះឈ្មោះថា ចុងនៃទង់ជ័យរបស់ភិក្ខុនោះ។ ទាហាននោះអត់ទ្រាំនូវចុងនៃធូលីបានដែរ តែលុះបានឃើញនូវចុងនៃទង់ជ័យ ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្រ្គាមមានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ។ បុគ្គលខ្លះក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង។ នេះបុគ្គលទី២ ប្រៀបដោយទាហានរមែងមានក្នុងភិក្ខុបុគ្គលទី២។ មួយទៀត ភិក្ខុខ្លះក្នុងសាសនានេះអត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យបានដែរ តែលុះបានឮសម្លេងហ៊ោ (នៃបច្ចាមិត្ត) ក៏រួញរា ថយក្រោយ មិនហ៊ានតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំងក្នុងសិក្ខា លះបង់នូវសិក្ខាវិលត្រឡប់មកកាន់ភេទថោកទាបវិញ។ ចុះអ្វីជាសំឡេងហ៊ោរបស់ភិក្ខុនោះ។ មាតុគ្រាម ចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយសើចល្បួង និយាយ ចែចង់សើចខ្លាំង ចំអកចំអន់ភិក្ខុនោះកាលបើត្រូវមាតុគ្រាម សើចល្បួង និយាយចែចង់ សើចខ្លាំង ចំអកចំអន់ ក៏រួញរា ថយក្រោយ មិនទប់ទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំង ក្នុងសិក្ខាលះបង់

នូវសិក្ខាវិលត្រឡប់មកកាន់ភេទថោកទាបវិញ នេះឈ្មោះថា សំឡេង ហ៊ោរបស់ភិក្ខុនោះ។ ទាហាននោះអត់ទ្រាំនូវចុងនៃធូលីអត់ទ្រាំនូវចុង នៃទង់ជ័យបានដែរ តែលុះបានឮសំឡេងហ៊ោ ក៏រួញរា ថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម មានឧបមាយ៉ាងនោះដែរ។ បុគ្គលខ្លះ ក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង។ នេះបុគ្គលទី៣ ប្រៀបដោយ ទាហាន រមែងមានក្នុងពួកភិក្ខុ។ មួយទៀត ភិក្ខុខ្លះ ក្នុងសាសនានេះ អត់ទ្រាំនូវចុងនៃធូលី។ អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោបានដែរ តែត្រូវគេបៀតបៀន ក៏វិនាសស្លាប់ខ្លួន ព្រោះការប្រហារ (របស់បច្ចាមិត្ត)។ ចុះអ្វីជាការប្រហាររបស់ភិក្ខុ នោះ។ មាតុគ្រាមចូលទៅរកភិក្ខុ ក្នុងសាសនានេះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយអង្គុយកៀកកើយ ដេក ជិត ឱបរឹត ភិក្ខុនោះ កាលបើត្រូវមាតុគ្រាម អង្គុយកៀកកើយ ដេកជិត ឱបរឹតហើយ ក៏មិនបានលះបង់នូវសិក្ខា មិនបានធ្វើឲ្យប្រាកដនូវភាព ជាអ្នកថយកម្លាំងទេ ហើយសេពនូវមេថុនធម្ម (នឹងមាតុគ្រាមនោះ) នេះជាការប្រហាររបស់ ភិក្ខុនោះ។ ទាហាននោះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោ (នៃបច្ចាមិត្ត) បានដែរ តែត្រូវគេបៀតបៀនក៏វិនាសស្លាប់ខ្លួនក្នុងសង្គ្រាម មានឧបមាយ៉ាង ណាមិញបុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ។ បុគ្គលខ្លះក្នុង សាសនានេះមានសភាពយ៉ាងនេះឯង។ នេះបុគ្គលទី៤ ប្រៀបដោយ ទាហានរមែងមានក្នុងពួកភិក្ខុ។ មួយទៀតភិក្ខុខ្លះ ក្នុងសាសនានេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោ អត់ទ្រាំនូវការប្រហារបាន ភិក្ខុនោះឈ្នះនូវសង្គ្រាមនោះមានសង្គ្រាម

ឈ្នះស្រឡះហើយ ក៏នៅគ្រប់គ្រងក្បាលសង្គ្រាមជ័យនោះឯង។

ជាទូទៅ បើនិយាយអំពីការប្រើប្រាស់ "ទង់" នេះជនជាតិណាក៏មានប្រើប្រាស់ដែរ ហើយសុទ្ធតែបញ្ជាក់អំពីអារ្យធម៌ជាតិ ។

## ២- អំពីភ្លេង

ភ្លេង Bleṇ : តន្ត្រី Tantri : ពាក្យភ្លេងមកពីពាក្យ "លេង" ដូចជាលេងភ្លេង លេងតន្ត្រី លេងល្បែង... បានក្លាយពីពាក្យ ភ្លេង ល្បែង។ ដូចមានក្នុងសិលាចារិក[៧] K149 មានសេចក្តីថា "កុ លេង" មានន័យថា ស្រីឈ្មោះ "លេង" ឬស្រីដែលជាអ្នកលេងល្បែងផ្សេងៗ និងសិលាចារិក[៨] K989C មានសេចក្តីថា "ចម្រ្យាង តម្រួច បុជាបាល-តូយ៉្យ" មានន័យថា អ្នកចម្រៀង អ្នកគ្រប់គ្រងពលសម្រាប់ពិធី និងភ្លេង។

កាលពីបរមបុរាណ ការប្រើប្រាស់កម្លាំងពលកម្មរបស់មនុស្សក្រោយពីសម្រាកការងារមនុស្សបានជួបជុំគ្នាដើម្បីជជែក ឬស្តាប់គ្នាទៅវិញទៅមក ដើម្បីពិពណ៌នាអំពីមនោសញ្ចេតនា ឬក៏បទពិសោធន៍ពលកម្ម ចំពោះអ្នកដែលមាននិស្ស័យចេះទាក់ទាញឲ្យគេស្តាប់ខ្លួនច្រើនត្រូវខំបំពងសម្លេងឲ្យឮបានឆ្ងាយ និងក្រអួនរំពងថែមទៀត ការនិយាយឮ និងក្រអួននេះត្រូវការជាចាំបាច់ ក្នុងការប្រកាសជាដំណឹងប្រកួតហៅគ្នាជួបដើម្បីប្រាស្រ័យទាក់ទងគ្នា មានន័យថាជាការប្រើប្រាស់បច្ចេកទេសសម្លេងនេះឯង។ ដំបូងគឺសម្រែកហ៊ោឡើងនៅពេលដែលគេធ្វើពលកម្មនូវវត្ថុធ្ងន់ៗ ដើម្បីធ្វើការអូសទាញឲ្យព្រមគ្នាស្រុះ

---

[៧] K149, ICIV, ទំព័រ២៩ បន្ទាត់១៨

[៨] K989C, 930 សក, ICVII, ទំព័រ១៧៧ បាត់ដំបង

ដៃគ្នាគេក៏ចាប់ផ្ដើមបន្ទឺសម្លេងជាចង្វាក់ "ហោ......ហឺបៗ......" ការបន្ទឺពាក្យពេចន៍នេះ ក៏មានការវិវត្តជាទំនុកបទដែលបង្ហាញពីមនោសញ្ចេតនាក្នុងការពុះពារ ឬត្អូញត្អែរ។

មនុស្សគ្រប់សញ្ជាតិក្នុងលោក ដែលបានសេចក្ដីសុខកាយសប្បាយចិត្ត ឥតមានវិបត្តិអ្វីក្នុងចិត្តតែងបញ្ចេញដោយកាយ ឬ វាចារ មានៈ រត់ លោត ហក់រាំ ច្រៀងជាដើម។

## ក. ភ្លេងជាតិកាលពីបុរេ

កំណាកំណើតនៃបទចម្រៀងកើតមកពីសំនៀងនៃការគ្រហឹមភ្ជាប់ជាមួយអត្ថបទសំណោរ ត្រូវបានប្រើប្រាស់សម្រាប់លើកតម្កើង ឬបញ្ចេញនូវទស្សនៈនៃការសរសើរសាសនា ឬ ការគោរពបូជា។ សំនៀងសូត្រគ្រហឹមដំបូងគេបំផុត ដោយអមទៅដោយបទភ្លេងត្រូវបានអភិរក្សទុក គឺសំនៀងគ្រហឹមរបស់ជនជាតិក្រិច ដើម្បីឧទ្ទិសដល់គំហើញនៃអាប៉ូឡូនាទីក្រុងដែលហ្វីស នាសតវត្សទី២ មុនគ.ស។ រីឯអារ្យធម៌បុរាណផ្សេងទៀត ត្រូវបានអភិរក្ស និងកត់ត្រាទុកនូវបទសំនៀងគ្រហឹមដោយពុំមានភ្លេង។ សំនៀងគ្រហឹមទាំងនេះ គេហៅថា **"ហ៊ីម"** (Hymn)[៩] ជាបទសូត្រវិទ្យា សម្រាប់ថ្វាយអាទិទេព បទសូត្រសរសើរព្រះជាម្ចាស់ ការសម្តែងសេចក្ដីចម្រើន។ បទគ្រហឹមទាំងនេះ រួមមានសំនៀងគ្រហឹមរបស់ចិន ឥណ្ឌា និង អេហ្សីបជាដើម។ ជាក់ស្ដែងឧបករណ៍ស្គរស្ពាន់ ដែលរកឃើញនៅអាស៊ីក្នុងពេលសម្ដែងភ្លេងនៅឥណ្ឌា ដែលសង់រាប់ពាន់ឆ្នាំមុនគ.ស។ ឧបករណ៍ជាច្រើន នៃ

---

(៩) http://en.wikipedia.Org/wiki/hymn

ភ្លេងអេហ្សីប ដែលរកឃើញនៅក្នុងសាជីអាយុ ២០០០-៣០០០ឆ្នាំមុនគ.ស។ បទចម្រៀងចិនកត់ត្រាទុកឡើងរវាងពាក់កណ្តាលស.វទី៧ រីឯប្រទេសលោកខាងលិចវិញ ភ្លេងពិតជានិមិត្តរូបលេចធ្លោរជាងគេ។

បុព្វហេតុជម្រុញឲ្យភ្លេងនៅអឺរ៉ុបខាងលិច មានការលូតលាស់យ៉ាងឆាប់រហ័ស ព្រោះបណ្តាលមកពីប្រទេសលោកខាងលិច គឺមានប្រភពភាសា ទឹកដីជាប់នឹងប្រទេសក្រិកបុរាណ ដែលឥទ្ធិពលនៃវប្បធម៌សិល្បៈរបស់ក្រិក តែងតែសណ្ឋិតយ៉ាងជ្រៅនៅក្នុងវប្បធម៌ប្រទេសអឺរ៉ុបខាងលិច ដោយហេតុថាបណ្តាប្រទេសលោកខាងលិចមានវឌ្ឍនភាពខាងវិស័យវិទ្យាសាស្ត្រ ជឿនលឿន ប្រព័ន្ធគមនាគមន៍សម្បូរបែបតភ្ជាប់គ្នា ធ្វើឲ្យកើតមានទីក្រុងយ៉ាងឆាប់រហ័សដែលនៅទីនោះឯង គឺជាមជ្ឈមណ្ឌលជឿនលឿនក្នុងការសាបព្រួសនូវខឿនសិល្បៈ Romance និង Go Thic នៅក្នុងសិល្បៈស្ថាបត្យកម្ម គំនូរចម្លាក់ និងអក្សរសិល្បៈ។ ជាពិសេស គឺនៅបណ្តាប្រទេសលោកខាងលិច មានរបបសក្តិភូមិ ដែលរីកចម្រើនឡើងនៅលើមូលដ្ឋាននៃការផ្តួលរំលំនៃចក្រពត្តិ រ៉ូម៉ាំង ស.វទី៥ ដែលជាប្រទេសចក្រពត្តិមហាអំណាច មានទឹកដី ដ៏ធំល្វឹងល្វើយ និង មានជនជាតិចម្រុះសាសន៍រស់នៅទីនោះ ដូចជាជនជាតិខេន (Ken)[១០] ហើយត្រូវបានរដ្ឋអំណាចមជ្ឈឹម ចាប់បង្ខំអនុវត្តរបបសមាហរណកម្មជាតិសាសន៍

[១០] Ken ជាកុលសម្ព័ន្ធរស់នៅភាគពាយ័ព្យនៃប្រទេសអង់គ្លេស នៅសម័យនោះ ជនជាតិ Ken ទោះក្នុងវណ្ណៈសង្គមក៏ដោយពួកគេកោតស្ញប់ស្ញែងតន្ត្រីករអ្នកចម្រៀងជាពួក Voix ទាំងនោះណាស់។

រហូតធ្វើឲ្យជាតិសាសន៍ទាំងនោះ ងើបឈរឡើងរើបម្រះដើម្បីរក្សាអត្តសញ្ញាណជាតិ លុះដល់ពេលក្លាយជារដ្ឋឯករាជ្យហើយ វប្បធម៌សិល្បៈជាអាទិ៍ មានភ្លេងផងដែរ របស់ប្រទេសនីមួយៗ តែងបង្ហាញឡើងទាំងចរិត "ជាតិ" ទាំងចរិត "អន្តរជាតិ" យ៉ាងច្បាស់ក្រឡែត ។

យ៉ាងណាមិញ សំនៀងគ្រហឹមនេះត្រូវបានកម្រិតសម្រាប់ទុកតែការពិភាក្សា នៅក្នុងវប្បធម៌អឺរ៉ុបតែប៉ុណ្ណោះ។ ហេតុនេះហើយបានជាបទភ្លេងជាតិចាប់ផ្តើមមានសារៈសំខាន់ណាស់នៅទ្វីបអឺរ៉ុប នាស.វទី១៩ ក្នុងនោះបទភ្លេងជាតិ ដែលមានអាយុកាលចាស់ជាងគេ គឺនៅប្រទេសហូឡង់[១១] ដែលត្រូវបានគេសរសេរឡើងនៅរវាងឆ្នាំ១៥៦៨-១៥៧២ មានឈ្មោះជាភាសាហូឡង់ ថា "Het Wilhelmus" ជាភាសាអង់គ្លេសថា "The William" ការបង្កើតភ្លេងជាតិនេះក្នុងគោលបំណងតំណាងឲ្យរាជវង្សប្រទេសហូឡង់ ដណ្តើមបានឯករាជ្យពីប្រទេសអេស្ប៉ាញ។ និពន្ធដោយលោក "Philip VanMarnix" ជាអ្នកគាំទ្រទៅលើស្តេច William ។ ចំណេរក្រោយមកភ្លេងជាតិនេះត្រូវបានប្រទេសហូឡង់ប្រកាសទទួលស្គាល់ជាផ្លូវការនៅឆ្នាំ១៩៣២ ។

នៅប្រទេសកម្ពុជា "**ភ្លេង**" គឺជាការចាំបាច់មួយ សម្រាប់ឲ្យបរិយាកាសក្នុងពិធីបុណ្យ និង ពិធីទំនៀមផ្សេងៗ មានភាពរីករាយរុងរឿង អឺកធឹក ។ **ភ្លេង** ត្រូវបានបុព្វបុរសខ្មែរ ផ្សារភ្ជាប់ទៅនឹងទេវកថាខ្មែរ នៅពេល **ព្រះថោង** រៀបអាពាហ៍ពិពាហ៍ ជាមួយនឹង**រាជបុត្រីស្តេចកុដ្ឋុងនាគ** ព្រះឥន្ទ្រាធិរាជទ្រង់ប្រើទេវបុត្រមួយអង្គ ដែលជំនាញខាង

---

[១១] http://en.wikipadia.org/wiki/het wilhelmus

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ភ្លេង គឺ "ព្រះពិស្ណុការ" ឲ្យនិមិត្តខ្លួនជាអ្នកភ្លេង ដើម្បីលេងក្នុងពិធីនោះឲ្យបានអឹកធឹក ទើបភ្លេងនេះជាប់ជាទំនៀមរៀងមក។ ដោយឡែកភ្លេងក៏ជាការកំណត់ចង្វាក់នៃការរាំផងដែរ ហេតុនេះបុព្វហេតុនាំឲ្យកើតការរាំក៏ជាអាថ៌កំបាំងផងដែរ ប៉ុន្តែមនុស្សយល់ថាអ្វីៗទាំងនោះវាកើតឡើងបាន ដោយការប៉ិនប្រសប់របស់មនុស្ស ដែលយើងអាចបែងចែកការកកើតភ្លេងនេះជាបីផ្នែកធំគឺ ផ្នែកទី១៖ "ភ្លេងតាមរយៈសម្លេងនៃធម្មជាតិ" ដូចជាផ្គរ ភ្លៀង ខ្យល់ រុក្ខជាតិ សត្វ និងសម្លេងអ្វីផ្សេងៗ គឺមូលដ្ឋានដែលបង្កើតឲ្យមានសម្លេង ហើយធ្វើឲ្យមនុស្សមានការចាប់អារម្មណ៍ក៏ទាញយកធម្មជាតិមកកែច្នៃឲ្យក្លាយទៅជាគ្រឿងឧបករណ៍ភ្លេងផ្សេងៗ ដូចជាមនុស្សបានយកឫស្សី ឬឈើកាត់ប្រវែងផ្សេងៗគ្នាមកបង្កើតជាឧបករណ៍ភ្លេង កេះ ឬគោះ ខ្លះទៀតក៏យកថ្ម លោហៈផ្សេងៗ មកបង្កើត ដែលគេប្រទះឃើញមានការប្រើប្រាស់តាំងពីសម័យបុរេប្រវត្តិ គឺមានលក្ខណៈដូចជាថ្មសម្លេង គឺស្គរមហោធិក[១២] ស.វទី៤-២មុនគ្រឹស្តសករាជដែលធ្វើអំពីសំរឹទ្ធិសព្វថ្ងៃត្រូវបានតម្កល់ទុកនៅសារមន្ទីរជាតិ។ បើរៀបរាប់ស្គរមហោធិក ឬស្គរភ្លៀង គឺមានដើមកំណើតដោយអំពើរបស់មនុស្ស ក្នុងការដែលបានទទួលអារម្មណ៍ជាសុខ ឬជាទុក្ខដោយពិតប្រាកដ ដែលមិនអាចនឹងទប់បានដែលអាចឲ្យមានកិរិយាផ្សេងៗ ឲ្យប្រាកដខាងក្រៅឡើង។

---

(១២) មហោធិក ឬ ស្គរភ្លៀង ជាឈ្មោះស្គរ ឬ ឃ្មោះ មួយប្រភេទ ធ្វើអំពីស្ពាន់ ទង់ដែង និងសំរឹទ្ធិមានរាង ស្រដៀងនឹងត្បាល់បុកស្រូវសម្រាប់ជាគ្រឿងប្រគុំ។ គេប្រើក្នុងព្រះរាជពិធីផ្សេងៗ។ មហោធិក ក្លាយមកពីមហា+ធិក ដែលមានន័យថាសម្លេងលាន់ ឬ ខ្លាំង ស្គរនេះគេហៅថាស្គរភ្លៀង ដោយសម័យបុរាណ គេប្រើប្រាស់ស្គរនេះ ក្នុងពិធីសុំទឹកភ្លៀងមកប្រើប្រាស់។

ផ្នែកទី២ "របាំ ឬរាំ" ពាក្យថា របាំ ឬ រម្មៈ ក្លាយមកពីពាក្យដើម "រាំ ឬរំ" ដែលមានតួនាទីជាកិរិយាស័ព្ទ យើងមានឃើញក្នុងសិលាចារិកថា "កុ រំ"... (K548, ខេត្តតាកែវ អង្គរបុរី) មានន័យថាឈ្មោះអ្នក រ-បំ = របំ រាំ...។ រ-មំ= រមំ មានន័យថា អ្នករាំ, មានន័យថាការរាំរបាំ, រនំ =រនំមានន័យថា មុខងាររបស់អ្នករាំ...។ បើតាមទេវកថាគឺតម្រារាំហៅ នាដសាស្ត្រនេះជារបស់ឥសីឈ្មោះ ***ភារតៈ***[១៣] បានតាក់តែងឡើងជាដំបូងដែលបានរៀបរៀង  តាមបែបបទរបស់ព្រះឥសូរ ជាគ្រូដើមលោករាំ និងទ្រង់ប្រទានឲ្យរាំក្នុងពិធីផ្សេងៗ ដើម្បីទទួលនូវមង្គលសួស្តីនិងសុគតិភពនៅថ្ងៃមុខៗក្នុងតម្រាបានតំណាលទៀតថា នៅស្រុក ចិទម្ពរ មានទេវស្ថានមួយសាងទុកឡើង កាលពុទ្ធសករាជគឺមានប្រមាណ ១៨០០ ចម្លាក់ប្រថាប់ស៊ុំគេឆ្លាក់ជារូបព្រះឥសូរទ្រង់រាំជាក្បាច់ រាំផ្សេងៗ ចំនួន ១០៨ ក្បាច់ ឬ១០៨ បែបតាមដែលមានក្នុងតម្រារាំរបស់ "***ភារតៈឥសី***"[១៤] និងផ្នែកទី៣៖ "ចម្រៀង" គឺមិនខុសគ្នាអំពីភ្លេង ឬ របាំប៉ុន្មានទេ ទោះបីមនុស្ស ឬសត្វសុទ្ធតែមានការច្រៀងផ្សេងៗគ្នាទៅតាមភាសា ហើយមនុស្សនៃជាតិសាសន៍នីមួយៗ ក៏ដូច្នោះដែរ។ ភាពប៉ិនប្រសប់របស់មនុស្សអ៊ីចឹងហើយ ទើបយើងឃើញការបញ្ចូលគ្នា រវាងភ្លេងនិងភ្លេង និងការបញ្ចូលគ្នារវាងភ្លេង និងរបាំ ព្រមទាំងចម្រៀងជាដើម ។

---

[១៣] ឈ្មោះរឿងមួយមានសេចក្តីពិស្តារវែងឆ្ងាយ នៅប្រទេសឥណ្ឌាពីព្រេងនាយទាក់ទងដោយពូជពង្សមហាក្សត្រ ព្រះនាម ភារតៈខ្មែរ សម័យបុរាណរាប់អានគោរពថាជារឿងដ៏សក្តិសិទ្ធិ

[១៤] ស៊ិន ហ៊ាន, ដើមកំណើតរបាំ, កម្ពុជសុរិយាឆ្នាំ, ទី០១  លេខ៣ ទំព័រ៣៣៨ គ.ស ១៩៥៩

## ខ. ដើមកំណើតនៃអក្សរភ្លេង

អក្សរភ្លេងដែលគេយកមកប្រើប្រាស់ទូទាំងសកលលោក រហូតមកដល់សព្វថ្ងៃនេះ គឺជាអក្សរភ្លេងដែលមានដើមកំណើតមកពីបច្ចឹមប្រទេស។ ការបង្កើតអក្សរភ្លេងនេះឡើង គឺដើម្បីងាយស្រួលក្នុងការកំណត់ទៅលើកកម្ពស់នៃសម្លេង ចង្វាក់ដង្ហើមល្បឿនងាយស្រួលចំណាំការអាន ការកត់ត្រា ការច្រៀង ការសម្តែងចេញតាមរយៈឧបករណ៍នីមួយៗបញ្ចោឲ្យលេងស៊ីសង្វាក់គ្នា ចាប់ពីពីរនាក់ឡើងទៅ រហូតដល់រាប់រយនាក់ (វង់ភ្លេង Symphony) បានគឺតាមរយៈអក្សរភ្លេងសកលនេះឯង។

ការកកើតនិមិត្តសញ្ញាអក្សរភ្លេង គឺនៅរវាងស.វទី៦-៥ មុន គ.ស នៅភាគខាងលិចនៃវប្បធម៌បុរាណចិន[១៥] ក្រោយមកអក្សរភ្លេងនេះ ត្រូវបានគេប្រទះឃើញនៅប្រទេសអេហ្ស៊ីប និង វត្ថុលេខជារូបភាព និងនិមិត្តសញ្ញា ដែលតំណាងឲ្យពាក្យនូវតំណាងអក្សរភ្លេង។ ដូច្នេះជនជាតិអេហ្ស៊ីប អាចធ្វើការគូសធ្លាក់ និងកែសម្រួលអក្សរភ្លេងដែលប្រើប្រាស់កាលពីសម័យបុរាណ។ អក្សរទាំងនោះ ជាទូទៅតែងមានលក្ខណៈខុសគ្នានូវ របៀបអ្នកលេងភ្លេង នៃឧបករណ៍នីមួយៗ ។

ក្រោយមក អក្សរភ្លេងត្រូវបានសរសេរឡើង ជាលើកដំបូងនៅទ្វីបអឺរ៉ុប ដោយលោក Romano ជនជាតិអង់គ្លេស។ នៅក្នុងការសរសេរដំបូងនៃអក្សរភ្លេង គឺអ្វីៗដែលត្រូវរក្សាទុកនូវអ្វីដែលងាយ

---

[១៥] លោក ស៊ុន សារ៉ាត, សារណាបរិញ្ញាបត្រផ្នែកតន្ត្រីវិទ្យា ការសិក្សាស្រាវជ្រាវអំពីអក្សរភ្លេងឆ្នាំសិក្សា២០០៣-២០០៤

ចាប់ក្មេងៗ អ៊ីចឹងហើយបានជាមានអក្សរភ្លេងដំបូងពីរទម្រង់ដែលនៅសល់ គឺ ទី១- បានមកពីការច្រៀង និងទី២- បានមកពីការលេងរបស់ឧបករណ៍ ។

តន្ត្រីបុរាណក្រិចបានបន្សល់ទុកនូវប្រព័ន្ធអក្ខរតន្ត្រីបែបអក្សរ Notion Alphalétique ដែលគេមិនបានកំណត់ឲ្យបានជាក់លាក់អំពីកម្រិតថេរនៃកម្ពស់សម្លេងនីមួយៗឡើយ។ មជ្ឈឹមសម័យបានបន្សល់ទុកជាបទភ្លេងសរសេរជាប្រព័ន្ធថ្មីមួយទៀត គឺប្រព័ន្ធអក្ខរតន្ត្រីបែបសញ្ញា (Notion Neume) ដែលបានត្រូវគេ រកឃើញនៅស.វ ទី ៩ ។

ជារួមអក្សរភ្លេង គឺជានិមិត្តសញ្ញារបស់តន្ត្រីនៃសម្លេង។ នៅពេលដែលអ្នកស្ដាប់តន្ត្រី យើងអាចអង្កេតឃើញថា តម្លៃរបស់អក្សរភ្លេងវាមិនដូចគ្នាទាំងអស់ទេ សម្លេងខ្លះពេលស្ដាប់ទៅឮសូរវែង ខ្លះឮសូរមួយៗយឺតៗ ខ្លះទៀតសម្លេងខ្លីៗ រីឯខ្លះទៀត វាខ្លីមែនទែន ហើយដែលគេបានបង្កើតឡើងដោយមានលក្ខណៈខុសៗគ្នាទៅតាមតំបន់និងប្រទេសនីមួយៗដូចជា អក្សរភ្លេងបុរាណចិន មានឈ្មោះថា "Gung, Shang, Jiao, Zhi, Yu ជាមួយនិង Chin, Jiao ហើយនិង biem, gung អក្សរភ្លេងប្រទេសឥណ្ឌាដូចជា Sa, re, ga, pa, dha, ni, sa ដោយឡែកចំពោះអក្សរភ្លេងសកលមានប្រាំពីរណោត គឺ Do, Ré, Mi, Fa, Sol, La, Si។

ហេតុនេះ បើពិនិត្យអំពីអក្សរភ្លេងសម័យបុរាណគឺមានលក្ខណៈស្មុគស្មាញ និងកង្វះខាតរាល់បច្ចេកទេសជាច្រើន តែមកដល់បច្ចុប្បន្នអក្សរភ្លេងមានលក្ខណៈសុក្រិត្យ និងសម្បូរបែប។

## គ. ទម្រង់នៃបទភ្លេង

បើនិយាយអំពីភ្លេង គឺមានកំណាកំណើតតាំងពីបឋមកាលមកម៉្លេះ ប៉ុន្តែសំណេរក្នុងកំណត់ត្រាអំពីសិល្បៈភ្លេងខ្មែរ មានជួបការលំបាកខ្លាំង ព្រោះពុំមានឯកសារចងក្រងទុក។ ការដែលយើងអាចប្រគំបទភ្លេងទាំងនោះបានខ្លះ ក៏ដោយសារតែលេងតាមការចេះចាំតៗគ្នា ពីជំនាន់មួយទៅជំនាន់មួយ ឯឈ្មោះអ្នកនិពន្ធទៀតសោតក៏យើងពុំបានស្គាល់ រហូតដល់សម័យក្រោយៗទៀតបទភ្លេងទាំងនោះក៏ក្លាយជាបទភ្លេងប្រជាប្រិយ ដោយសាររកអ្នកនិពន្ធមិនឃើញ។

គួរឲ្យសោកស្តាយឧបករណ៍ភ្លេងខ្លះបានបាត់បង់រូបរាងគឺនៅសល់តែឈ្មោះ និង មានតែនៅក្នុងរូបចម្លាក់តាមប្រាង្គប្រាសាទនានាប៉ុណ្ណោះតួយ៉ាងដូចជាឧបករណ៍គងពាក់កណ្តាលវង់ជាដើម។ បទភ្លេងបុរាណខ្មែរពីសម័យដើមមានច្រើនសន្ធឹកសន្ធាប់ណាស់ ហើយច្រើនបែបច្រើនទម្រង់ទៀតផង ដែលស្ថិតនៅស្ទើរពាសពេញផ្ទៃប្រទេសតាមខេត្ត ស្រុក ភូមិ ឃុំ វត្តអារាម និង តាមតំបន់ ជនជាតិភាគតិច។ តែទោះជាយ៉ាងនេះក្តី ភ្លេងនៅក្នុងប្រព័ន្ធចម្រៀងខ្មែរ មិនខុសពីបរិបថនៃ "**ភ្លេង**" ក្នុងបណ្តាប្រទេសនានាលើលោកទេគឺថា "**ភ្លេង**" ឬហៅថា "**គីតសិល្បៈ**" អាចមានឫទ្ធិអំណាចទាក់ទាញរហូតដល់ទឹកចិត្តរបស់សត្វទៀត។ ដូចជា ចំពោះសត្វវិញការផ្លុំស្នែងអាចធ្វើឲ្យដំរីដែលជាសត្វមានកម្លាំងខ្លាំង ត្រូវចុះខ្សោយបានដោយថាមពលទោរទន់ តាមបញ្ជារបស់មនុស្ស សត្វពស់ដែលជាសត្វមានពិសអាចបាក់ខ្លួបចុះមករាំដោយសារសម្លេងខ្លុយ។ ពេលច្បាំងមានសម្លេងគេងអាចជួយជំរុញឲ្យមានកម្លាំងក្លាហាន។ យុទ្ធជនខ្លះពោលថា

"ពេលណាឮសម្លេងភ្លេងជ័យ ខ្ញុំមានចិត្តបែបជ្រួលរំភើប ឈាម កំហឹងឡើងប្រាល ផ្ទុកនូវកំហឹង កម្លាំងចិត្ត និងកម្លាំងកាយ"។ ជំនាន់ដើមយុទ្ធជនតោងរៀនស្តាប់ភ្លេងសញ្ញាជើងស្គរនៃក្រុមរបស់ខ្លួនឲ្យបានប្រាកដដើម្បីងាយចំណាំគឺ សញ្ញាធ្វើដំណើរចេញ ឬដំណើរទៅមុខឈប់សម្រាកត្រឡប់ថយក្រោយ ឬចូលវាយសម្រុក។ មិនតែប៉ុណ្ណោះភ្លេងអាចជួយរកសន្តិភាពជូនមនុស្សលោក ដូចមានតំណាលថាៈ "**បទភ្លេងចម្រៀង បំបាត់នូវស្នូរគ្រាប់បែក**"។ និយាយរួម ភ្លេងគឺជាការបកស្រាយមនោសញ្ចេតនានៃសិល្បៈ តាមរយៈសូរស័ព្ទពីរយ៉ាងៈ ទី១ តាមរយៈឧបករណ៍ និងទី២ តាមរយៈសម្លេងមនុស្ស ឬចម្រៀង។ ម៉្យាងទៀតភ្លេង មានលក្ខណៈជាប្រវត្តិសាស្ត្រ ដូចជាភ្លេងរបស់ខ្មែរនាសម័យអង្គរ បានប្រាប់ឲ្យយើងដឹងពីភាពខ្ពស់ត្រដែត រុងរឿងយ៉ាងណា... ហើយក៏បានប្រាប់តទៅទៀតដែរ នៅសម័យក្រោយៗអង្គរជាបន្តបន្ទាប់ពីភាពចុះទន់ខ្សោយ ភាពអន្តរាយ ភាពនិរាសព្រាត់ប្រាប់...។ មួយវិញទៀត "**ភ្លេង**" ឬចម្រៀងរបស់ជាតិណាសាសន៍ណា រមែងជាទីចាប់ចិត្តចាប់អារម្មណ៍ខ្លាំងនៃជាតិសាសន៍នោះ។ បានន័យថា នៅក្នុងជាតិសាសន៍ណាក៏មានភ្លេងចម្រៀងដែលជាលក្ខណៈសិល្បៈដ៏រឹងមាំ ដក់ជាប់ក្នុងចិត្តនៃជនជាតិនីមួយៗដែរ។ មិនតែប៉ុណ្ណោះ ភ្លេងអាចឲ្យគេយល់ថ្លឹងប្រមាណនូវជម្រៅចិត្តរបស់មនុស្ស។ ហេតុនេះហើយភ្លេងត្រូវបានគេប្រើប្រាស់ផ្សេងគ្នា ទៅតាមពេលវេលា និងសកម្មភាពតួយ៉ាងដូចជា នៅក្នុងចម្បាំងក្រុមភ្លេងគងមានតួនាទីសំខាន់ក្នុងក្បួនដង្ហែទ័ព គឺក្រុមភ្លេងគងត្រូវបានគេលេងនៅមុខក្បួនដង្ហែព្រះមហាក្សត្រ ដឹកនាំទ័ពយាងចេញច្បាំង ក្រុមពួក

គេមិនខុសពីកងទ័ពប៉ុន្មានទេ ម្យ៉ាងទៀត នៅពេលដែលចាប់ផ្តើមច្បាំង ក្រុមភ្លេងគងមានការប្រគំកាន់តែខ្លាំងឡើងៗ ដើម្បីលើកសន្ទុះទឹកចិត្តអ្នកចម្បាំងឲ្យកាន់តែមានទឹកចិត្តក្លាហានឡើងៗក្នុងការប្រយុទ្ធគ្នា ដោយយើងឃើញនៅប្រាសាទបាយ័ន្ត ថែវខាងក្នុងជ្រុងខាងត្បូងឈៀងខាងកើត នេះបង្ហាញថាក្នុងពេលចម្បាំង ឬ ប្រកួតជ្រើសរើស ចាំបាច់ត្រូវការនូវភ្លេង ដែលយើងឃើញរហូតដល់បច្ចុប្បន្ន ដូចជា កីឡាប្រដាល់ក្បាច់គុនបុរាណខ្មែរ ដែលយើងយល់ថា បន្តពីសម័យបុរាណ ។

កាលដែលបុព្វបុរសខ្មែរពីជំនាន់បុរាណកាល បានបន្សល់ទុកចម្លាក់នៅតាមប្រាសាទ សិលាចារិក សាស្ត្រាស្លឹករឹត ឬ តាមប្រភពនានាក្តី បានប្រាប់ឲ្យយើងដឹងអំពីវិស័យសិល្បៈ តូរ្យតន្ត្រី (ភ្លេង) ដែលត្រូវបានអ្នកស្រាវជ្រាវសន្មតថា ជាប្រភេទសិល្បៈអរូបិយ គឺមានច្រើនបែបច្រើនបទណាស់ តួយ៉ាងដូចជា មាននៅក្នុងទំនៀមទម្លាប់ប្រពៃណីរៀបអាពាហ៍ពិពាហ៍ កាលឡើងអារ័ក្ស ឬក៏ពិធីបុណ្យជាតិផ្សេងៗទៀតរបស់ខ្មែរសុទ្ធតែបានភ្ជាប់ភ្លេង។ ដូចមានបញ្ជាក់ បទបុរាណខ្លះដែលភ្ជាប់ប្រពៃណីរៀបអាពាហ៍ពិពាហ៍ របស់ខ្មែរដូចជា បទ "ព្រះថោងនាងនាគ, នាគព័ន្ធ" ជាដើម សុទ្ធតែបានប្រាប់អំពីការកកើតទឹកដីខ្មែរ កើតឡើងដោយការរៀបអាពាហ៍ពិពាហ៍ ដោយផ្សារភ្ជាប់បទភ្លេងរវាងរាជបុត្រីខ្មែរនៃស្តេចកុដ្ឋនាគជាមួយព្រះថោង។

អត្ថន័យនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺកើតបានជាគ្រឹះយ៉ាងរឹងមាំនៃប្រពៃណីខ្មែរសម្រាប់ "ស្ត្រី" និង "បុរស" មុននឹងស្រីអនុញ្ញាតឲ្យបុរស មិនថាមានបុណ្យស័ក្តិប៉ុណ្ណា ឬ មកពីណាទេ មុនរួម

មេត្រីស្នេហាបានលុះត្រាតែឆ្លងកាត់នូវគន្លងប្រពៃណីជាមុនសិន។ ដូច្នេះ ការភ្ជាប់ការកកើតទឹកដី ព្រមជាមួយការភ្ជាប់នូវប្រពៃណីដ៏ល្អរបស់ស្ត្រីនេះ បានធ្វើឲ្យសង្គមខ្មែរក្លាយជាអារ្យធម៌មួយបុរាណជៀសផុតការលួចស្រលាញ់គ្នាតាមបែបអានារ្យជនបានជារៀងរហូតមកដល់បច្ចុប្បន្ន។ ដូចពាក្យចាស់ប្រដៅកូនចៅ ឲ្យជៀសវាងថាកុំឲ្យយកគ្នាពាសវាលពាសកាល ដូចសត្វធាតុនោះអី។ ដែលខុសគ្នាពីជនជាតិនៅអឺរ៉ុបខ្លះ មានប្រទេសមួយចំនួនមានអារ្យធម៌សម័យ (ថ្មី) ដូច្នេះគេអាចរួមមេត្រីស្នេហាតាមលក្ខណៈដែលបានព្រមព្រៀងគ្នា ដោយពុំចាំបាច់ឆ្លងកាត់ប្រពៃណីអាពាហ៍ពិពាហ៍ព្រោះប្រទេសគេពុំមានអារ្យធម៌បុរាណ នៃការផ្សារភ្ជាប់ប្រពៃណី។

តាមរយៈទេវកថា អំពីដើមកំណើតស្រុកខ្មែរ គឺបានលាតត្រដាងប្រាប់ឲ្យយើងដឹងថា ខ្មែរគោរពទៅលើគោលការណ៍ នៃមេ-បា គឺព្រះរាជាមានតួនាទីលក្ខណៈសំយោគជាមេផង និងបាផង។ ព្រមជាមួយការផ្លាស់ប្តូរភេទលើរចនាសម្ព័ន្ធ និង មនោគមវិជ្ជា ហើយក្លាយខ្លួនដ៏រឹងមាំដូចជា៖ ពីឈ្មោះ ភូមិ ស្រុក ក្លាយទៅជារដ្ឋ ពីមេ-បា ក្លាយជាព្រះរាជាមានន័យថា ដឹកនាំដោយស្តេច។

បទភ្លេងខ្មែរនៅក្នុងទេវកថានេះ បញ្ជាក់ថាប្រហែលបទភ្លេងដែលកើតជាដំបូងគេបង្អស់នៅលើទឹកដីខ្មែរ ព្រមជាមួយគ្នានៃការកកើតរដ្ឋផងដែរ ព្រោះថាកាលពីមុន នៅពេលដែលប្រវត្តិសាស្ត្រខ្មែរពុំទាន់បានទទួលឥទ្ធិពលព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាពីប្រទេសឥណ្ឌា ខ្មែរពុំមានសាសនាទេ គឺខ្មែរមានជំនឿផ្ទាល់ខ្លួនដែលហៅថា "**ជីវចលនិយម**" (ព្រលឹងនិយម) ដែលស្មើររាប់ថា

សាសនាមិនកើត ពីព្រោះគ្មានអ្វីជាគោលការណ៍ធំៗ ដូចនេះការគោរពព្រលឹងនិយមជាមួយនឹងធម្មជាតិមាន អារុក្ខអារក្ស អ្នកតាមេ-បា ដែលមានលំនៅលើដីជាមួយមនុស្សដូចគ្នា ដែលយល់ថាជាអ្នកផ្តល់សេចក្តីសុខ និង ទុក្ខ គឺអាស្រ័យនូវអ្នកទាំងនោះជាអ្នកសម្រេចជោគវាសនារបស់ខ្លួនៗ តាមជំនឿជីវចលខ្មែរមិនដែលនិយាយពីឋានលើ ឋានក្រោម ឋានសួគ៌ ឋាននរកអ្វីទេៗ ខ្មែរពុំដែលពិចារណាថា ពេលស្លាប់ និងទៅជាអ្វីទៅឋានណានោះទេៗ ដូច្នេះតាមរយៈជំនឿនេះ ខ្មែរយល់ថាពិភពលោករបស់មនុស្សមានលក្ខណៈរាបស្មើ ពុំមានឋានលើឋានក្រោមទេៗ គេសង្កេតឃើញមានខ្មួមអ្នកតាក៏ជាមនុស្សដូចគ្នាព្រៃភ្នំ ឬ ដំបូក... គឺស្ថិតក្នុងពិភពតែមួយ តែបន្ទាប់ពីទទួលយកព្រះពុទ្ធ សាសនាថេរវាទ យ៉ាងពេញទំហឹងហើយគឺគេបានបែងចែកឋានជាបី គឺ ឋានសួគ៌ ឋានកណ្តាល និងឋាននរក ដែលជាហេតុនាំឲ្យមនុស្ស និងអមនុស្សនៅដាច់ពីគ្នា ដូច្នេះមនុស្សក៏រិះរកមធ្យោបាយ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរបស់ពិភពអមនុស្សដដែលតាមរយៈការសែនព្រេនផ្សេងៗ។ ដូច្នេះ ហើយបានជាខ្មែរមានប្រភេទឧបករណ៍ទាំងអស់ ដើម្បីបម្រើដល់វត្ថុសក្តិសិទ្ធិ ដែលគេត្រូវគោរពបូជាៗ ម៉្យាងទៀតនៅក្នុងបទភ្លេងខ្មែរមានច្រើនប្រភេទ ច្រើនទម្រង់ណាស់ៗ តែគេអាចសរុបមកត្រឹមបីទម្រង់គឺ **ទី១ ទម្រង់ភ្លេងសុទ្ធ** គឺភាគច្រើនប្រើសម្រាប់ពិធីសាសនា ជាពិសេស ប្រភេទភ្លេងសុទ្ធនេះស្តាប់ក្នុងន័យគិតពិចារណាៗ **ទី២ ទម្រង់ភ្លេង-ចម្រៀង** គឺជាការរួមគ្នាសម្តែងរវាងក្រុមភ្លេង និងអ្នកច្រៀង និង**ទី៣ ទម្រង់ច្រៀងសុទ្ធ** (ដែលមានវង់ភ្លេងអមកំដរនៅពេល ឬនៅត្រង់វគ្គច្រៀងបន្ទរ) គឺច្រៀងដើម្បីរៀបរាប់ ពន្យល់អំពីអ្វីមួយចំពោះប្រភេទទម្រង់នេះ គឺប្រៀប

ដូចជាការនិយាយប្រាប់អ៊ីចឹងដែរ។ ទម្រង់ប្រភេទនេះ មានបទម៉្យាង ដែលគេច្រៀងគឺ "**បទអេ្ហ**" ប្រើក្នុងកម្មវិធីអុំទូក។ ចម្រៀង "**អេ្ហ**" ប្រហែលជាបទចម្រៀងដែលបានកើតនៅក្នុងសម័យអង្គរ រវាងសតវត្សទី១២ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ នៅពេលដែលព្រះអង្គត្រូវស្តេចយាងទៅធ្វើសឹកសង្គ្រាមជើងទឹក ដោយដឹកនាំកងទ័ពទូកដ៏ច្រើនមហិមាក្នុងការធ្វើចម្បាំងជាមួយសត្រូវ។

ដោយព្រះបញ្ញាញាណ ព្រះអង្គក្នុងការធ្វើសឹកសង្គ្រាម ទើបធ្វើឲ្យទ្រង់បានរំដោះប្រទេសជាតិឲ្យរួចផុតពីខ្លាំងសត្រូវ នៅរវាង គ.ស ១១៧៧-១១៨១ ប្រកបដោយជោគជ័យ ស្ថិតនៅក្រោមការដឹកនាំរបស់ព្រះអង្គ បានញ៉ាំងឲ្យប្រជារាស្ត្រមានសេចក្តីរំភើប ស្ញប់ស្ញែង ទ្រាំមិនបានស្រែកហ៊ោកញ្ជ្រៀវ ខ្ញៀវខ្ញារ កងរំពងពេញផ្ទៃទឹក ពេលនោះហើយទើបសន្មតថាចម្រៀង(អេ្ហ)ចាប់ផ្តើមបន្លឺឡើងសម្រាប់កំដរបរិយាកាស។

បើតាមប្រសាសន៍ កញ្ញា **ណម ណារ៉ែម** អតីតនិស្សិតមហាវិទ្យាល័យ តូរ្យតន្ត្រីដែលបានចងចាំតាមរយៈលោកយាយឈ្មោះ **ឯម ធាយ** ជាសាស្ត្រាចារ្យ ហើយទទួលគោរម្យងារ ជាវីរៈសិល្បៈករនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានមានប្រសាសន៍ថា៖ ចម្រៀង "អេ្ហ" គេចែកចេញជាបីបទគឺ :

- បទទី១ : បទ "អេ្ហ"
- បទទី២ : បទសុវណ្ណហង្ស
- បទទី៣ : ផាត់សុផាន់

ចម្រៀងអេ្ហ នេះគឺច្រៀងនៅមុនពេលព្រះករុណាប្រទានភ្លើងប្រទីប។ បើតាមលោកសាស្ត្រាចារ្យ **ប៉ែន សំអុល** ព្រឹទ្ធបុរសរង មហាវិទ្យាល័យតន្ត្រីតន្ត្រី បានមានប្រសាសន៍ថា ទម្រង់បទ "អេ្ហ" នេះត្រង់វគ្គបន្ទរ គឺប្រគំរួមគ្នាជាមួយវង្សភ្លេងមហោរី។ តាមភស្តុតាងដែលឃើញមាននៅតាមចម្លាក់ប្រាង្គប្រាសាទនានាដូចជាប្រាសាទបាយ័ន្ត ប្រាសាទបន្ទាយឆ្មា គេឃើញរូបព្រះឆាយាល័ក្ខ ព្រះបាទជ័យវរ្ម័នទី៧ គង់ប្រថាប់លើព្រះទីនាំងទូក ដោយទ្រង់កាន់ធ្នូ និងលំពែងយ៉ាងស្វាហាប់ប្រកបដោយឫទ្ធានុភាព។

តំណាលតពីពេលនោះមក ក៏មានព្រះរាជពិធីសមយុទ្ធ អកអំបុក សំពះព្រះខែ និង បណ្តែតប្រទីបរៀងរាល់ឆ្នាំ ដើម្បីជាការរំឭកនូវជ័យជម្នះ ក្នុងសឹកសង្គ្រាមរបស់ទ័ពទូកនៃកងទ័ពជើងទឹកខ្មែរ ដែលឃើញមានមកដល់សព្វថ្ងៃនេះ។

បើនិយាយអំពីរបៀបច្រៀងចម្រៀង "អេ្ហ" គឺអ្នកច្រៀងមានឥរិយាបថអង្គុយបត់ជើងច្រៀង ហើយទាមទារឲ្យអ្នកច្រៀងម្នាក់ក្នុងចំណោមអ្នកច្រៀងទាំងអស់ជាអ្នកចាប់ផ្តើម ទើបអ្នកផ្សេងៗចូលបន្ទ ទាំងអស់គ្នា ។

ជាទូទៅចម្រៀង "អេ្ហ" ស្ទើរពុំត្រូវបានប្រជារាស្ត្រខ្មែរឮស្គាល់ទេ ពីព្រោះ ទម្រង់ចម្រៀងនេះ គេមិនយកទៅប្រើជាទូទៅក្នុងពិធីផ្សេងៗ ឡើយ។ ហើយក៏ស្ថិតក្នុងទម្រង់ប្រភេទនៃចម្រៀងពិសេសមួយ គឺគេមិនបានតាក់តែងឲ្យអ្នកច្រៀង ច្រៀងទៅតាមតុងនៃអក្សរភ្លេងនោះទេ គឺអ្នកចម្រៀងស្រែកច្រៀងទៅតាមកម្លាំងនៃកម្ពស់សម្លេងខ្លួនឯងតែប៉ុណ្ណោះ ។

ក្នុងការជាពន្ទឹមួយ ដើម្បីឲ្យលោកអ្នកបានស្គាល់នូវទម្រង់ចម្រៀងបទ "អ្កេ" នេះយើងសូមចុះផ្សាយនៅ (ឧបសម្ព័ន្ធទី១)។ ដូចបានពោលខាងដើមហើយថា បទភ្លេងខ្មែរមានច្រើនបែបច្រើនបទណាស់ ហើយរាល់បទភ្លេងនីមួយៗ គឺតម្រូវទៅតាមកម្មវិធី ។

និយាយរួម ភ្លេងបង្ហាញអត្តសញ្ញាណជាតិ និង មានលក្ខណៈជាអ្នកបម្រើ ជាគ្រូពេទ្យ អ្នកណែនាំ និងអប់រំ រស់នៅជាមួយមនុស្សគ្រប់ស្រទាប់វណ្ណៈយ៉ាងជិតស្និទ្ធ តែជាអាវុធមុខពីរ គឺអាចនាំទៅរកផ្លូវល្អ ឬអាក្រក់ ទៅតាមរបបសង្គម ឬ ទស្សនៈនៃវណ្ណៈមួយ ឬក្រុមមនុស្សមួយក្នុងសង្គម។ បទភ្លេងក៏អាចព្យាបាលរោគបានដែរ សូរ្យសៀងតន្ត្រីដែលយើងបានស្ដាប់រាល់ថ្ងៃ ក្រៅពីជួយបង្កើនសេចក្ដីសុខខាងអារម្មណ៍ឲ្យយើងហើយនោះ សូរ្យសៀងតន្ត្រីអាចជួយព្យាបាលរោគបានទៀតផង។ នៅក្នុងការពិសោធន៍គេឃើញមានអ្នកជម្ងឺជាច្រើន ដែលមានសកម្មភាពឆេវឆាវជាច្រើននាក់ បានចូលទៅសាកល្បងព្យាបាលដោយសូរ្យសៀងតន្ត្រី។ គ្រូពេទ្យបានប្រាប់ថា អាការៈរបស់អ្នកជម្ងឺទាំងនេះបានល្អប្រសើរឡើង ក្រោយពេលបានស្ដាប់បទភ្លេង។ តាមការស្រាវជ្រាវ តន្ត្រីខ្លះក៏មានកម្រិតរលកពិសេសអាចធ្វើឲ្យផ្លាស់ប្ដូរពណ៌ និងខ្នាតរបស់កោសិកាគ្រាប់ឈាមក្រហម ណោត A ទៅជាពណ៌ស៊ីជម្ពូរ។ ណោត C ធ្វើឲ្យ កោសិកាលូតកាន់តែវែងឡើង ណោត E ធ្វើឲ្យរូបរាងកោសិកាកាន់តែមូល។ ក្រៅពីនេះណោតចាប់ពី A-B នៅក្នុងកម្រិតរលកប្រមាណ ៤០០-៤៨០ Hz អាចធ្វើឲ្យកោសិកាមហារីកបែករលាយបាន។ អ្នកពិសោធន៍បានប៉ាន់ស្មានទុកថា រលកកម្រិតរបស់ណោតភ្លេងខ្លះមានរលកកម្រិត

ដូចគ្នានឹងកោសិកាប្រភេទខ្លះនៅក្នុងរាងកាយមនុស្សដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការព្យាបាលអ្នកជម្ងឺដោយសូរ្យសៀងតន្ត្រី វាគ្រាន់តែជាជម្រើសមួយប៉ុណ្ណោះ ហើយបទចម្រៀងដែលប្រើព្យាបាលអ្នកជម្ងឺគួរជាបទចម្រៀងប្រភេទក្លាស៊ិក ដែលជួយបង្កើនអារម្មណ៍សប្បាយ។ ដូច្នេះ ភ្លេងគឺចាំបាច់សម្រាប់ប្រជារាស្ត្រទាំងអស់ មិនមែនសម្រាប់តែតន្ត្រីករទេ ពលរដ្ឋស្មើរមួយរយភាគរយ ចេះអានអក្សរភ្លេងច្រៀងរាំ។ ជារួមភ្លេងមានតួនាទីបម្រើ និងអន្ទងព្រលឹងទាំងមនុស្ស និងអមនុស្ស។

ក្នុងបរិបថ ដែលបរិយាយអំពី "**ទង់-ភ្លេង**" នេះគឺភ្លេងដែលយើងលើកយកមកនិយាយនេះ គឺបទនគររាជថាហេតុអ្វីបានយកមកធ្វើបទជាតិ? ដែលគេកំណត់ថា "**ភ្លេងជាតិ**" រួចធ្វើការកំណត់សម្គាល់អំពីពាក្យ "**ទង់**" ដែលត្រូវបានគេកំណត់ថា "**ទង់ជាតិ**" សុទ្ធជាតំណាងនៃ "**ទង់-ភ្លេង**" និមិត្តរូប "**ជាតិ**" ។

រាល់ចម្ងល់ទាំងប៉ុន្មានដែលបានរៀបរាប់ខ្លះៗ មកនេះ ជាកត្តាជុំរុញឲ្យខ្ញុំចាប់អារម្មណ៍ និងដោយយល់ឃើញថា មានគំនិតសមល្មម និងបង្កើតបានជាប្រធានបទមួយ ដោយផ្តោតសំខាន់ពិនិត្យអំពីប្រភពនៃ "**បទនគររាជ**" ព្រមជាមួយប្រព័ន្ធជំនឿនៃ "**ទង់ជាតិ**" ។

ដូច្នេះខ្ញុំមិននិយាយអំពីបទភ្លេង ក៏ដូចជាអំពីទង់ដែលប្រើទូទៅជាអាទិ៍: ទង់សាសនា, ទង់គណបក្សនយោបាយ, ឬ ទង់ក្រុមហ៊ុនផ្សេងៗទៀតឡើយ រីឯបទភ្លេងប្រើក្នុងកម្មវិធីផ្សេងៗទៀតក៏ដូច្នេះដែរ។

# ជំពូក ២

# ការវិវត្ត ទង់ជាតិ-ភ្លេងជាតិ

## ១- ទង់ជាតិ

ដូចបានបរិយាយរួចខ្លះៗមកហើយថា "**ទង់**" មានច្រើនប្រភេទ ច្រើនសណ្ឋាន ដូច្នេះហើយទើបគេបានកំណត់ទង់មួយជារបស់ជាតិ ហៅថា "**ទង់ជាតិ**"។ អ្វីទៅជាទង់ជាតិ? គឺជានិមិត្តសញ្ញា ឬរូបតំណាងឲ្យប្រទេសនីមួយៗ លក្ខណៈសម្គាល់នៃទង់ជាតិ គឺជាទង់ផ្ទាំងសំពត់ ឬចម្រៀកសំពត់ ដែលគេដេរឲ្យមានសណ្ឋានជាពណ៌ ជារូបភាព ឬគំនូសដែលជាសញ្ញាសម្រាប់ប្រើតំណាងឲ្យជាតិ ឬសម្គាល់អ្វីមួយ សូម្បីធ្វើដោយក្រដាសក៏ហៅថា "**ទង់ជាតិ**" ដែរ ។ បើយោងទៅលើព្រះត្រៃបិតកក៏បានពណ៌នាអំពីគ្រឿងសម្គាល់ប្រទេសថា អ្វីជាគ្រឿងពិតប្រាកដរបស់រថ (ប្រទេស), អ្វីជាគ្រឿងពិតប្រាកដរបស់ភ្លើង, អ្វីជាគ្រឿងពិតប្រាកដរបស់ដែន, អ្វីជាគ្រឿងពិតប្រាកដរបស់ស្រី ក្នុងនោះ គឺទង់ជាគ្រឿងពិតប្រាកដរបស់រថ (ប្រទេស), ផ្សែងជាគ្រឿងពិតប្រាកដរបស់ភ្លើង, ព្រះរាជាជាគ្រឿងពិតរបស់ដែន, ភស្តាជាគ្រឿងពិតប្រាកដរបស់ស្រី ។

### ក. អំពីពណ៌

រាល់ៗជាតិក្នុងលោកនេះ ដែលមានសេចក្តីចម្រើនរុងរឿង ហើយរមែងមានទង់ប្រចាំជាតិទាំងអស់ ប្លែកតែប្រើពណ៌ផ្សេងៗ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ខ្ទាស់គ្នាប៉ុណ្ណោះ ដែលជាគ្រឿងសម្គាល់ ជាតិ សាសនា មហាក្សត្រ និងអធិបតេយ្យភាព (ភាវៈជាធំ) ជាដើម, ក្នុងពណ៌នីមួយៗដែលយកមកប្រកបជាអង្គទង់ឡើង សុទ្ធតែមានប្រវត្តិរបស់គេ អធិប្បាយហេតុផលទុកឲ្យយល់ផង មិនមែនចេះតែចាប់ដាក់ៗទៅតាមទំនើងចិត្តនោះទេ តែនឹងកំណត់ឲ្យជាការទៀងទាត់ថាពណ៌បែបនេះ ជាគ្រឿងសម្គាល់យ៉ាងនោះ ឲ្យត្រូវត្រង់គ្នាទាំងអស់ពុំបានទេព្រោះស្រេចតែសេចក្តីត្រូវការ ពោលគឺប្រព្រឹត្តទៅតាមសេចក្តីនិយមរបស់អ្នកដើមការបញ្ញត្តិឡើង ឬដោយអាស្រ័យមានហេតុភេទឯណានីមួយៗជាសំខាន់ដ៏ទាក់ទាម ដោយពណ៌នោះកើតឡើងក្នុងក្រុម ឬ ស្រុកទេសរបស់គេនោះគេក៏សន្មតយកពណ៌នោះ ទុកជាពណ៌ទង់ជាតិរបស់គេមួយយ៉ាងតែតោងរៀងខ្ទាស់គ្នាដោយពណ៌ផ្សេងៗ យ៉ាងតិចត្រឹមពីរពណ៌។ តួយ៉ាងដូចជាទង់អូឡាំពិកមានកងរង្វង់មូលប្រាំតំណាងឲ្យការចូលរួមរបស់មនុស្សមកពី៥ទ្វីប។ ទង់របស់អង្គការសហប្រជា-ជាតិ តំណាងដោយមែក ដើមអូលីវ មានអត្ថន័យជា "សារសន្តិភាព"។ តាមសេចក្តីនិយម ដោយច្រើនពណ៌សជាគ្រឿងសម្គាល់សាសនា, ពណ៌ក្រហម ជាគ្រឿងសម្គាល់ជាតិ មហាក្សត្រ, ពណ៌ខៀវ ផ្ទៃមេឃជាគ្រឿងសម្គាល់អធិបតេយ្យ។

សម្រាប់ប្រទេសឥណ្ឌា ក្នុងសម័យបុរាណ ការកំណត់ប្រើពណ៌ទង់ ឬ ប្រើគ្រឿងសម្លៀកបំពាក់របស់គេឃើញ ដូចជាមានរបៀបបែបផែនទៀងទាត់ណាស់ ព្រោះគេមានគ្រូ ឬមានតម្រាតែមួយបែប តួយ៉ាងដូចវណ្ណៈ ប្រភេទមនុស្ស ៤ ជំពូកក្នុងប្រទេសឥណ្ឌា គេបញ្ញត្តិពណ៌សម្រាប់វណ្ណៈនោះ ជាការទៀងទាត់រហូតមកគឺ ក្សត្រ ជាតិ

អ្នកចម្បាំង ពណ៌ក្រហម, ព្រាហ្មណ៍ អ្នកកាន់ សាសនា ពណ៌ស, វេស: ពួកអ្នកធ្វើការរកស៊ីជាធម្មតាពណ៌លឿង សូទ្រ: ពួកកម្មករ ពណ៌ខ្មៅ ។

ចំណែកឯខ្មែរយើង ក៏ជាមនុស្សជាតិដែលមានអារ្យធម៌ សឹង ទាក់ទាមដោយអារ្យធម៌ឥណ្ឌាយ៉ាងច្រើន ហេតុនោះការដែលប្រើទង់ ឬពណ៌គ្រឿងសម្លៀកបំពាក់ទាំងពួងច្រើន និយមទៅតាមបែបឥណ្ឌា តួយ៉ាងដូចជាពណ៌ទង់ជាតិ និង ពណ៌សម្រាប់ព្រះមហាក្សត្រជា ដើម។ អំពីពណ៌ទង់ជាតិកាលពីសម័យព្រេងនាយមានបីពណ៌ (ត្រៃរង្គ) នេះបើតាមការ អះអាង ឧកញ៉ា ទេព ពិទូរក្រសេម [១៦] បាន បញ្ជាក់ថា ៖

-ពណ៌ស : ជាផ្ទៃពង បួនជ្រុងទ្រវែង

-ពណ៌ក្រហម : អមជុំវិញពណ៌ស និង

-ពណ៌ផ្ទៃមេឃ : អមជុំវិញពណ៌ក្រហមបែបជាជាយ

អធិប្បាយ តាមវណ្ណបថក្នុងសាសនាព្រាហ្មណ៍ ដែលជា សាសនាចាស់ជាងគេក្នុងលោក ហើយដែលខ្មែរយើងធ្លាប់កាន់កន្លង មកក្នុងសម័យព្រេងនាយនោះនិយមពណ៌ស ដែលជាពណ៌បរិសុទ្ធ ជាពណ៌សម្រាប់សាសនា ចូរមើលពួកព្រាហ្មណ៍ អ្នកកាន់សាសនា រមែងស្លៀកពាក់សជាគ្រឿងសម្គាល់។ ចំណែកខាងព្រះពុទ្ធសាសនា ឃើញដូចជានិយមពណ៌ស តាមទំនងនេះខ្វះដែរ ចូរមើលពួកអ្នក

---

[១៦] ឧកញ៉ា ទេព ពិទូរក្រសេម, កម្ពុសុរិយា ព.ស. ២៤៨៤ គ.ស. ១៩៤២, ភ្នំពេញ

ឧបាសកឧបាសិកា អ្នកដែលកាន់ម៉ឺងម៉ាត់ក៏និយមស្លៀកសពាក់ស ដោយច្រើន វៀរលែងតែពួកបុព្វជិតគោងប្រើពណ៌លឿង ដោយ អំណាចពុទ្ធបញ្ញត្តិខណ្ឌដោយឡែកផ្សេងៗ ដោយហេតុនេះជនជាតិ ខ្មែរ កាលនឹងផ្ដើមធ្វើទង់សម្រាប់ជាតិឡើង ក៏បានលែលកបញ្ញត្តិ យកតាមទំនងនេះ គឺទង់បែបដើមមុនសម័យនគរធំ ដាក់ពណ៌ស ជាឋានជាគ្រឿងប្រកាសជាអ្នកកាន់សាសនា ដែលប្រៀបដោយដួង ចិត្តបរិសុទ្ធសឹងតាំងនៅកណ្ដាលរូបកាយ តែលុះមកដល់សម័យក្រុង សោធរបុរៈ (នគរធំ) ក្នុងរវាងព.ស. ១៤០០ ដល់ ១៧០០ ដែលកើត ប្រាសាទថ្មធំៗសឹងល្អអស្ចារ្យ ក្នុងលោកនេះឡើងក៏កែប្រែទង់ជាតិ ដើម្បីទទួលកិត្តិយសជាថ្មីនោះ ដោយដកពណ៌សចេញទុកតែពណ៌ ក្រហម និងពណ៌ខៀវ ផ្ទៃមេឃ ជាជាយជុំវិញ ហើយដាក់រូបប្រាសាទ (កំពូលបី) ពណ៌ស ជាជំនួសត្រង់កណ្ដាល គឺដាក់សង្កត់លើផ្ទៃក្រហម នោះកាលមើលទៅក៏ឃើញហាក់ដូចជាពណ៌ត្រែរង្គដូចដើម ។

ឯពណ៌ក្រហមជាគ្រឿងសម្គាល់ព្រះមហាក្សត្រ ដែលជាអ្នក សុរជាតិនឹងជាអ្នកច្បាំង សឹងមានអាការៈប្រៀបដូចជា សុរិយរង្សី ឬ ប្រៀបដូចលោហិតរបស់វីរបុរសអ្នកក្លាហាន ។ តាមគតិស្ដេចសៀម ក្នុងចក្រីវង្សនេះ មានព្រះអង្គ "យ៉តហ្វា" ជាដើមបានកំណត់យក ពណ៌លឿងជាពណ៌ប្រចាំព្រះបរមរាជវង្សថៃ[១៧]។ ចំពោះខ្មែរវិញគួរ តែពិចារណាចំពោះពណ៌នេះឬទេ?

---

[១៧] ចូរមើលសៀវភៅសិល្បាករភាគ១ ឆ្នាំទី២ ព.ស២៤៨០ ក្នុងរឿង "គ្រឿងសម្គាល់ អាយ៍ណាឃោស" ។

គួររំឭកថា នៅក្នុងរជ្ជកាលទី២និងទី៥ ទង់ជាតិថៃ មានរូប "ដំរីស" តែដល់រជ្ជកាលទី៦ ក្នុងរជ្ជកាលព្រះបាទ **ម៉ុង គុកក្លាវ** ពីឆ្នាំ ១៩១០-១៩២៥ ព្រះអង្គបានប្រឌិតឡើងនូវទង់ជាតិ មានលក្ខណៈជាត្រៃរង្គ គឺពណ៌ខៀវ ស ក្រហម ដើម្បីយល់អំពីអត្តសញ្ញាណរបស់ជាតិសៀម តាមរយៈព្រះរាជនិពន្ធស្ដីពីទង់ជាតិនេះ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩១៧ ចំពោះទង់ជាតិថៃនេះ គឺបានបង្កើតឡើងមាន៥ឆ្នូត ដែលធំបំផុតនោះគឺពណ៌ខៀវកណ្ដាល ចំណែកឯពណ៌ស និងពណ៌ក្រហមត្រូវបានបែងចែកពាក់កណ្ដាលឲ្យញែកពីគ្នាស្របទៅខាងលើ និងខាងក្រោមនៃពណ៌ខៀវ តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺពណ៌ទង់ជាតិថៃនេះមានលក្ខណៈជាត្រៃរង្គ ដូចពណ៌ទង់ជាតិខ្មែរក្នុងរជ្ជកាលព្រះបាទនរោត្តម ដែលព្រះអង្គបានបង្កើតឡើងនៅរវាងឆ្នាំ១៨៦៣ ដែរ។ ចំណែកឯពណ៌ផ្ទៃមេឃ ជាគ្រឿងសម្គាល់អធិបតេយ្យដែលធំខ្ពស់គ្រប់ពីលើគពផែនដី។ បើតាមឧកញ៉ា **ពិទូ ក្រសេម**(១៨) បានអះអាងថា មកដល់សម័យមួយក្នុងរជ្ជកាលព្រះបាទ សិទ្ធពអមរិន្ទ្រ បានកែប្រែទង់ជាតិម្ដង ដោយផ្លាស់ប្ដូររូបប្រាសាទចេញ ដាក់រូបសេះសជំនួសព្រោះក្នុងរជ្ជកាលនោះ ទ្រង់និយមសេះសណាស់ លុះផុតរជ្ជកាលនោះ ហើយរជ្ជកាលក្រោយមកបានត្រឡប់ផ្លាស់រូបសេះសចេញ ដាក់រូបប្រាសាទដូចដើមវិញ។ តែគួរឲ្យសោកស្ដាយ យើងពុំបានស្រាវជ្រាវឃើញនូវរូបទង់ជាតិនេះទេ អ្វីដែលយើងដឹងច្បាស់ មុនអាណាព្យាបាលបារាំងសែស ១៨៦៣ ខ្មែរមានទង់ជាតិមានរាង

(១៨) ឧកញ៉ា ទេព ពីទូរក្រសេម, ប្រវត្តិទង់ប្រចាំជាតិខ្មែរ, កម្ពុសូរិយា, ឆ្នាំទី១ លេខ១ ឆ្នាំ ១៩៤២

ត្រីកោណ តែពុំដឹងថាកើតនៅសម័យណាទេ លុះសម័យរជ្ជកាល ព្រះបាទ នរោត្តម ខ្មែរមានទង់ជាតិមានប្រាសាទអង្គរកំពូលប្រាំ ហើយ បានវិវត្តន៍នៅរហូតមកដល់សព្វថ្ងៃនេះ។ ទោះបីប្រទេសជាតិមាន វិបត្តិ ហើយមេដឹកនាំខ្មែរមាននិន្នាការនយោបាយផ្សេងៗពីគ្នា ឈាន ទៅដល់ច្នៃបង្កើតទង់ជាតិថ្មីប្រចាំក្រុមរបស់ខ្លួន ក៏ដោយគឺត្រូវយក ស្មារតីចងចាំនៃយុគសម័យអង្គរ ពោលគឺយករូបប្រាសាទអង្គរវត្តធ្វើ ជាគោលបំណងនយោបាយរៀងៗខ្លួន ការជ្រើសរើសពណ៌ទង់ជាតិ ផ្សេងៗគ្នា ឬរចនាបថប្រាសាទប្លែកគ្នា ដូចជាខ្លះយកប្រាសាទកំពូលបី ខ្លះយកប្រាសាទកំពូលប្រាំ ខ្លះទៀតយកប្រាសាទកំពូលបីដែរ តែ ថែមរូបផ្កាយធ្វើជានិមិត្តសញ្ញានៃទង់ជាតិប្រចាំក្រុម ឬរបបគ្រប់គ្រង របស់ខ្លួនក៏ដោយប៉ុន្តែចំណុចរួមគឺរូបប្រាសាទអង្គរវត្ត។ ពណ៌ទង់ ជាតិខ្មែរនេះរាប់ថាត្រូវតាមលក្ខណៈពណ៌ត្រៃរង្គ ដែលលោកនិយម ល្អណាស់ ។

## ខ. ទង់ជាតិក្នុងទស្សនៈខ្មែរ

"**ទង់**" ក្នុងទស្សនៈនៃផ្នត់គំនិតខ្មែរ មានពាក្យថា "**អានិសង្សទង់**" ទង់ជាគ្រឿងគោរពបូជា ដែលហាក់ដូចជាបង្កប់នូវសញ្ញាណអ្វីមួយ អ៊ុំចឹង សម្រាប់ឲ្យមនុស្សត្រូវតែពិចារណា។ ដោយហេតុថាទង់ស្ថិត នៅក្នុងបរិបថពីរគឺ ពេលសប្បាយក៏គេលើកទង់ និង ពេលកើតទុក្ខក៏ គេលើកទង់។ មានអ្នកស្រាវជ្រាវជាច្រើនបានសិក្សាតែទៅលើទង់ "**ព្រលឹង**"។ ចំណែកឯកិច្ចការជំនឿទាក់ទងនឹង "**ទង់ជាតិ**" ដើម្បីស្វែង រកអត្ថន័យក្នុងប្រព័ន្ធជំនឿ ខ្មែរហាក់ដូចជាពុំទាន់មានការស្រាវជ្រាវ នៅឡើយទេ។

ទង់ជាតិគឺជាទង់តំណាងឲ្យជាតិមានន័យថាជាគ្រឿងសម្គាល់នូវជាតិសាសន៍នីមួយៗ ហើយក៏ជាការកំណត់នូវដែន អធិបតេយ្យភាពទឹកដីផងដែរ។ ដូចជានៅតាមស្ថានទូតនីមួយៗ ត្រូវបានសម្គាល់ដោយទង់ជាតិនៃប្រទេសនោះ សូម្បីប្រទេសម្ចាស់ផ្ទះ ក៏ត្រូវមានកាតព្វកិច្ចគោរពនូវដែនអធិបតេយ្យនៃស្ថានទូតផងដែរ ។

ដោយឡែកចំពោះការប្រើប្រាស់ "**ទង់ជាតិ**" ដែលបុព្វបុរសខ្មែរសម័យបុរាណប្រើថា តើមានលក្ខណៈនិងទម្រង់យ៉ាងណាដែរទេ? ទោះបីគេដឹងថានៅតាមប្រាសាទបាយ័ន្ត ខ្មែរមានទង់ជ្វាលាក៏ដោយៗ ជាក់ស្តែងរបៀបក្បួនហែចតុរង្គ[១៩] សេនាក្នុងពិធីប្រោះព្រំនិងសមយុទ្ធនោះ ទើបតែនឹងលើកលែងធ្វើ ក្នុងកាលមិនយូរប៉ុន្មានតែកាលឈប់លែងធ្វើហើយ ក៏ហើយតែម្តង ទៅស្រាវជ្រាវរកក្បួនខ្នាតដែលធ្លាប់ធ្វើមកទាំងប៉ុន្មានក៏មិនឃើញមានប្រាកដដល់មួយចប់សោះ មុខគួរឲ្យស្តាយណាស់កាលបែរទៅស៊ើបសួរតាមចាស់ព្រឹទ្ធាចារ្យទាំងពួង ក៏បានទទួលតបមកវិញថា "**ធ្វើបែបយ៉ាងក្បួនសឹកៗ**" ដោយច្រើនអ្នកខ្លះក៏ថា បែបយ៉ាងក្បួនហែក្នុងព្រះរាជាពិធីរាជាភិសេកៗ របៀបក្បួននោះ គេត្រូវការឲ្យទាហានកាន់គ្រឿងសាស្ត្រាវុធគ្រប់ដៃល្បែងសឹកលេងទាំងពួង គ្មានគ្រឿងហែហមទាំងពួង មានតែទង់ប្រចាំកង និងគ្មានកងទ័ពភ្លេងតូរ្យតន្ត្រីទាំងពួង មានតែស្គរជ័យសម្រាប់វាយប្រកាសក្នុងវេលាមានជ័យជម្នះៗ តែបើនៅ

[១៩] ជាពិធីនៃកងទ័ពមានបួនអង្គ គឺកងទ័ពដំរី កងទ័ពសេះ កងទ័ពរថ ឬរទេះ កងទ័ពថ្មើរជើង

ក្នុងរបៀបក្បួនហែក្នុងព្រះរាជពិធីរាជាភិសេកនោះវិញ គឺគេត្រូវការឲ្យគគ្រឹកគគ្រេងល្អមើលល្បែងលេងមានច្រើនយ៉ាង រហូតដល់ទៅមានស្រីតែងជាល្ខោនគ្រឿងហែរួមទាំងទង់ផង មានគ្រប់បែប ភ្លេងតូរ្យតន្ត្រីមានគ្រប់បែបយ៉ាងៗ ការរៀបរៀងក្បួនសមយុទ្ធប្រចាំឆ្នាំក្នុងជាន់នេះ ដោយអាស្រ័យប្រៀបធៀប តាមក្បួនទ័ពបុរាណខ្លះ តាមក្បួនហែក្នុងព្រះរាជពិធីរាជាភិសេកខ្លះតែសេចក្ដីពិត របៀបក្បួនសមយុទ្ធប្រចាំឆ្នាំគង់មិនដូចក្បួនព្យុហយាត្រាដែលលើកចេញទៅច្បាំង ឬក្បួនហែក្នុង ព្រះរាជាពិធីរាជាភិសេកស្មោះតែម្ដងទេ តាំងនៅក្នុងរវាងរបៀបក្បួនហែទាំងពីរនោះ គឺត្រូវការឲ្យទង់នាំទ័ព, ទង់ប្រចាំកង, ទង់ប្រចាំកងទ័ព និងមានទង់គ្រឿងហែខ្លះ ភ្លេងខ្លះ តែការល្បែងលេងទាំងប៉ុន្មានគ្មានៗ សង្កេតមើលរបៀបចាត់ក្បួនទ័ពបុរាណ ដូចជារូបភាពកងទ័ព នៅប្រាសាទបាយ័ន្តឃើញកងសេនាទាំង៤ ពួកដើរចម្រុះគ្នាចេញទៅតែម្ដងមិនបានញែកជាសង្កាត់ៗ ជាកងសេនាដំរី, កងសេនាសេះ, កងសេនារថ, កងសេនាថ្មើរជើងទេៗ រូបភាពកងទ័ពព្រះបាទសូរ្យវរ្ម័នទី២ ដែលឆ្លាក់ទុកនៅប្រាសាទនគរវត្ត ឃើញមានសេនាថ្មើរជើងដើរមុខពីសង្កាត់ ជាទ័ពស្រួចតពីនោះ មកកងសេនាទាំង៤លើកដើរចម្រុះគ្នាតែម្ដង ព្រះបាទសូរ្យវរ្ម័នគង់លើដំរី នៅត្រង់រវាងកណ្ដាលកងទ័ព ។



◂ រូបភាព ក្បួនដង្ហែទង់ផ្កាលា

តមកទៀតនោះ បើហ្នឹងរៀបរាប់ឲ្យប្រាកដប្រជាថាតើទង់ជាតិមានមានទម្រង់និងការវិវត្តបែបណានោះទេ? បើទោះបីលោក **អ៊ុំង ហុងសាធ** ក្នុងសារព័ត៌មានអ្នកជាតិនិយមថ្ងៃទី១៨-៦ ១៩៦០ បានអះអាងថា ទង់ជាតិខ្មែរបានកើតឡើងនៅរវាងព.ស. ៦២៣ គឺត្រូវនឹងគ.ស. ៨០ ក្នុងរជ្ជកាលព្រះកេតុមាលា ព្រះចៅប្រទេសកម្ពុជា ដែលទ្រង់គង់ប្រថាប់នៅប្រាសាទអង្គរធំក៏ដោយៗ ប៉ុន្តែគ្រាន់តែដឹងថាមុនសម័យអាណាព្យាបាលបារាំងសែស ១៨៦៣ ខ្មែរមានទង់ជាតិរបស់ខ្លួនដែលមានជារាង "ត្រីកោណ" ផ្ទៃខាងក្នុងពណ៌ "លឿង" ព័ទ្ធជុំវិញមានជាយធ្មេញៗ ពណ៌ "ខៀវខ្ចី" យើងមិនដឹងថាប្រភពទង់ជាតិនេះកើតក្នុងរជ្ជកាលណាទេៗ បើពិចារណាអំពីទង់ជាតិនេះ គឺថាមានរូបសណ្ឋានស្រដៀងគ្នានឹងទង់ជាតិ ដែលគេឃើញនៅអាស៊ី ដូចជាចិន ជប៉ុន កូរ៉េ ដែលបញ្ជាក់អំពីលក្ខណៈជាទង់ជាតិ ក្នុងអត្ថន័យរបស់ពិភពលោកនាសម័យនោះៗ



ទង់ជាតិកម្ពុជាមុនឆ្នាំ១៨៦៣

## ២- ទង់ជាតិ-ភ្លេងជាតិ និងប្រាសាទសិលាក្នុងទស្សនៈនយោបាយ

សក្តិភាពនៃសម័យមហានគរដ៏រុងរឿង ពីសតវត្សទី៩ ដល់សតវត្សទី១៣គ.ស ប្រទេសកម្ពុជាបង្កើតបាននូវអរិយធម៌មួយដ៏ល្បីល្បាញ និងជាទីមោទនៈនៃមនុស្សជាតិផងទាំងពួង ដែលអ្នកប្រវត្តិសាស្ត្រហៅថា ចក្រភពនៃអារ្យធម៌អង្គរមានប្រាសាទរាប់ពាន់ប្រកបដោយក្បូរក្បាច់រចនាល្អគ្មានពីរ នៅពាសពេញទូទាំងប្រទេស រហូតដល់សព្វថ្ងៃជានិមិត្តរូបនៃទេពកោសល្យថ្លៃប្រឌិតនៃសិល្បៈខ្មែរ។ សព្វថ្ងៃនៅតែរក្សាបាននូវសម្រស់ដ៏ល្អឥតខ្ចោះ ទាំងខាងស្ថាបត្យកម្ម ទាំងខាងសិល្បៈតុបតែង ដែលមនុស្សលោកស្ទើរតែពុំអាចជឿបានថា មនុស្សអាចធ្វើបាននូវអច្ឆរិយវត្ថុយ៉ាងដូច្នេះ។ ប៉ុន្តែចាប់ពីចុងសតវត្សទី១៥ មកអរិយធម៌ដ៏រុងរឿងនេះ ក៏ធ្លាក់ចុះបន្តិចម្តងៗស្ទើរតែរលាយសាបសូន្យ រហូតដល់រាជ្យរាជ្យឆ្នាំ១៤៣២ ព្រះរាជាបង្ខំចិត្តបោះបង់ក្រុងអង្គរ គឺដោយសារការទន្ទ្រានឈ្លានពានពីបរទេស ព្រមជាមួយនូវការសាមគ្គីភេទ (បែកបាក់សាមគ្គី) ផ្ទៃក្នុងជាហេតុធ្វើឲ្យស្ថានភាពរបស់ប្រទេសចុះដុនដាប រហូតដល់ធ្លាក់ទៅក្នុងក្រញាំដៃពួកអាណានិគម បានផ្លាស់ប្តូរដាក់នឹមត្រួតត្រាបន្តបន្ទាប់គ្នាអស់រាប់រយឆ្នាំ។

### ក. ផែនដីកម្ពុជា ពីឆ្នាំ១៨៦៣-១៩៤៨

ដូចបានពោលខាងដើមហើយថា អារ្យធម៌ខ្មែរចាប់ផ្តើមកកើតជារូបរាងតាំងពីមុនសម័យអង្គរធ្លាក់ចុះម្ល៉េះ។ នៅដើមស.វទី១៩ ថ្វីត្បិតតែប្រទេសសៀម និងប្រទេសអាណ្ណាមនៅតែកៀបសង្កត់យ៉ាងខ្លាំងលើខ្មែរក៏ដោយ ក៏ខ្មែរមិនបាត់បង់ប្រាជ្ញាស្មារតី និងការចងចាំដែរ។

គេអាចយកព្រះបាទអង្គឌួង មកជាគោលក្នុងការអះអាងនេះ។

ព្រះបាទអង្គឌួង ទទួលការអប់រំរៀនសូត្រនៅបាងកក ហើយមកសោយរាជ្យនៅស្រុកវិញក្រោមការត្រួតពិនិត្យរបស់សៀម។ តែបើពោលតាមទស្សនៈអារ្យធម៌និងសង្គមវិញ អង្គរស្ថិតនៅជាខ្មែរឥតមានរង្គោះរង្គើ។ ប្រជាពលរដ្ឋរស់នៅតាមភូមិស្រុកនានា ដែលកកើតយូរមកហើយនៅជុំវិញប្រាសាទ ឬស្ថានីយ៍បុរាណផ្សេងៗ។ បើពិនិត្យលើការកត់ត្រាទាំងឡាយនៃជនជាតិអឺរ៉ុប ដែលបានទស្សនាអង្គរកាលពីស.វទី១៩ យើងអាចយល់ថា អង្គរស្ថិតក្នុងស្មារតីចងចាំនៃអ្នកស្រុកជានិច្ច។ បើទុកជាអំណាចនិងអនុភាពនៃកម្ពុជាចុះអន់ថយយ៉ាងណាក៏ដោយ អង្គរនៅតែជាទីដែលពុទ្ធសាសនិកខ្មែរ និងបរទេសជិតខាងមក ឬប្រាថ្នាមកធ្វើបូជនីយកិច្ច ដូចកាលនៅសម័យអង្គរដែរ។ មិនត្រឹមតែប៉ុណ្ណោះ អង្គរ ជាពិសេសអង្គរវត្ត ឈានចូលកាន់តែច្បាស់ឡើងមកស្មារតីនិងនិមិត្តរូបខ្មែរ។

"អង្គរ" ជាពាក្យនិយាយក្លាយពី "នគរ" ប្រែថា ធានី ជាពិសេសរាជធានី។ បើនិយាយតាមន័យក្លាយនៃពាក្យសព្វថ្ងៃនេះ គេអាចជំនួសបានថា "បុរី" ឬ "ក្រុង"។ ឯពាក្យ "អង្គរវត្ត" មិនត្រូវយល់តាមប្រព័ន្ធឃ្លាខ្មែរ ឬអម្បូរភាសាមន-ខ្មែរទេ ត្រូវយល់តាមប្រព័ន្ធ ឬ ឃ្លាភាសាឥណ្ឌូ-អឺរ៉ុប (ក្នុងនោះមានសំស្ក្រឹត-បាលី)។ ពោលគឺមានន័យថា "វត្តនៃរាជធានី"។ ឈ្មោះមួយទៀតនៃអង្គរវត្ត ហើយដែលអ្នកស្រុកសៀមរាបនិយមហៅដល់សព្វថ្ងៃ គឺ "អង្គរតូច"។ ដូច្នេះក្នុងន័យក្លាយដែលពោលខាងលើ ប្រែថា "ក្រុងតូច"។ ហៅរបៀបនេះដើម្បីញែកអង្គរតូចឱ្យដាច់គ្នាពី "អង្គរធំ" ដែលមានផ្ទៃដីធំជាង។

នៅស.វ. ទី១៦ មានសិលាចារឹកមួយហៅ អង្គរវត្ត ថា "ព្រះមហានគរឥន្ទ្រប្រស្ថ...ព្រះពិស្ណុលោក"។សិលាចារឹកមួយទៀតចារនៅស.វ.ទី១៧ ហៅថា "ឥន្ទបត្តម្ហានគរ ស្រីសុធរបវរពិស្ណុលោក"។ ក្នុងឈ្មោះក្រោយនេះ ពាក្យថា "ម្ហានគរ" បង្ហាញឱ្យឃើញថាពីភាពថ្កុំថ្កើង និងសក្ការៈនៃអង្គរជំនាន់នោះ។ ឯពាក្យព្រះ "ពិស្ណុលោក" វិញ មិនគឺអ្វីក្រៅពីមរណៈនាមនៃព្រះរាជាដែលសាងអង្គរវត្តនោះទេ ពោលគឺ "បមរ វិស្ណុលោក"។ "ស្រីសុធរ" ក៏ដូចគ្នាដែរ គឺសំដៅទៅលើឈ្មោះនៃរាជធានីអង្គរ ដែលនិយមហៅតាំងតែពីកកើតមក (ចុង ស.វ. ទី៩) ពោលគឺ "ស្រីយសោធរ"។ ឯពាក្យ "ឥន្ទ្រប្រស្ថ" និងពាក្យ "ឥន្ទបត្ត" ជាពាក្យតែមួយទេ ហើយប្រែថា "បុរីនៃព្រះឥន្ទ្រ" គ្រាន់តែមួយជាទម្រង់សំស្ក្រឹត ឯមួយទៀតជាទម្រង់បាលី។ នៅក្នុងអារ្យធម៌ព្រាហ្មណ៍ ឥន្ទ្រប្រស្ថជាឈ្មោះនៃបុរីនៅលើស្ថានមនុស្សយើងនេះ ដែលព្រះឥន្ទ្រចុះមកគង់ម្តងៗ។ ការប្រើឈ្មោះនេះ សឱ្យឃើញថា អង្គរវត្តព្រមទាំងអារ្យធម៌ទាំងមូលល្បីសុះសាយរហូតមានលក្ខណៈជាទេវកថា។ ឯការវិវត្តពីសំស្ក្រឹតឥន្ទ្រប្រស្ថមកបាលីឥន្ទបត្ត ក៏ហាក់ដូចជាបង្ហាញពីការដូរសាសនា ពីព្រាហ្មណ៍មកថេរវាទដែរ។ មកទល់សព្វថ្ងៃនេះ វត្តជើង និង វត្តត្បូងដែលស្ថិតនៅក្នុងបរិវេណប្រាសាទអង្គរវត្ត មានឈ្មោះជាផ្លូវការ "វត្តនគរឥន្ទបត្តបូរី"។

បើយោងទៅតាមទេវកថា ដែលកើតឡើងនាសម័យកណ្តាល អង្គរវត្តពុំមែនសាងឡើងសម្រាប់ព្រះឥន្ទ្រផ្ទាល់ទេ គឺសម្រាប់ព្រះរាជបុត្រព្រះអង្គ ដែលជាទេពពាក់កណ្តាល ជាមនុស្សពាក់កណ្តាល ហើយដែលមាននាមថា ព្រះកេតុមាលា។ រឿងនោះនិទានថា ព្រះឥន្ទ្រ

បញ្ហាដល់ព្រះពិស្សុកម្ម (សំស្ក្រឹត ៖ វិស្វកម៌) ដែលជាជាងជំនាញក្នុងពពួកទេព ឱ្យសាងចម្លងវាំងប្រាសាទរបស់ព្រះអង្គនៅឋានសួគ៌ មកលើដីស្ថានមនុស្ស សម្រាប់ព្រះកេតុមាលាជាបុត្រ។

អនុភាពនៃអង្គរវត្ត ផ្ដោតនៅក្នុងមនោគតិខ្មែរ រហូតដល់ខ្មែរបង្កើតទេពអង្គដែលគេបូជា ជាពិសេសក្នុងការសាងសង់ផ្សេងៗ។ ទេពនេះមាននាមថា "ពិស្ណុការ" ពោលគឺខ្មែរយកសព្ទនៃឈ្មោះអង្គរវត្ត (ដែលជាមរណៈនាមនៃព្រះបាទសូរ្យវរ្ម័នទី២ផង) - ពិស្ណុលោក - មកលាយបញ្ចូលកាត់គ្នាជាមួយ "(វិស្វ)កម៌" ដែលជាឈ្មោះមេជាងនៃឋានព្រះឥន្ទ្រ។ សព្វថ្ងៃព្រះពិស្ណុការនេះគេបូជាខ្លាំងណាស់ក្នុងពេលប្រកបការងារផ្សេងៗ ជាពិសេសក្នុងការសាងសង់។

បើលោតមកបច្ចុប្បន្នកាលយើងឃើញថា ទង់ជាតិដែលរបបផ្សេងៗក្នុងប៉ុន្មានទសវត្សនេះប្រកាន់យក សុទ្ធសឹងតែមានរូបអង្គរវត្តជាដំហរ។ ដោយសារតែខ្មែរជ្រួតជ្រាបនូវទស្សនៈបច្ចឹមប្រទេសម្ដងបន្តិចៗ តាំងពីបារាំងសែសកាន់កាប់ប្រទេសមកនោះ អង្គរក៏កាន់តែផ្ដោតជ្រៅឡើងវិញ នៅក្នុងមនសិការខ្មែរ រហូតដល់ពុំអាចផ្ដាច់ពីអតីតកាល ព្រមទាំងប្រវត្តិសាស្ត្រជាតិបាន។

នៅចុងទសវត្ស១៨៥០ ពោលគឺនៅចុងរាជនៃព្រះបាទអង្គឌួងនេះឯងដែលអង្គរចាប់ផ្ដើមមានន័យថ្មី ហើយកាន់តែធំជាងជាលំដាប់ដោយសារបច្ចឹមប្រទេសមហាអំណាចធំៗចាប់ផ្ដើមស្គាល់។

នៅក្នុងបរិវថនេះ បើយើងលោតមកបន្តិចក្នុងរជ្ជកាលព្រះបាទនរោត្តម ក្នុងឆ្នាំ១៨៦៣ ព្រះអង្គបានជ្រើសយករូបប្រាសាទអង្គរវត្ត

កំពូលប្រាំពណ៌ "**ស**" សង្កត់ផ្ទៃខាងក្នុងពណ៌ "**ក្រហម**" ព័ទ្ធជុំវិញពណ៌ "**ខៀវ**" ដ៏ជាទីសក្ការៈរបស់ខ្មែរ ទុកជាប្រកពបញ្ញាញាណជាតិនិងជានិមិត្តសញ្ញាលើទង់ជាតិ ។

- ពណ៌ទង់ជាតិនេះរាប់បានថាមានលក្ខណៈត្រៃវង្គ ដើម្បីសម្តែងពីអត្តសញ្ញាណជាតិរបស់ខ្មែរ ចំពោះមុខអារ្យប្រទេសនានាក្នុងសកលលោក។ គួរកត់សម្គាល់ថា ពណ៌ទង់ជាតិមានលក្ខណៈជា "ត្រៃវង្គ" គឺពណ៌ខៀវ ស ក្រហម ប្រសិនបើគេពិចារណាក៏ឃើញពីផ្នែកនៃពណ៌ គឺមានលក្ខណៈស្រេបពណ៌អឺរ៉ុបខាងលិច ដែលតែងតែប្រើពណ៌មាស ឬពណ៌ លឿង និងពណ៌ក្រហមដែលអធិប្បាយបន្តទៅទៀតបានថា ដើម្បីធ្វើឲ្យខ្មែរមើលទៅឃើញថា អារ្យប្រទេសមានលក្ខណៈប្រហាក់ប្រហែលជាមួយនឹងអឺរ៉ុបខាងលិច ទាំងរូបភាព និង ខ្លឹមសារពណ៌ជាផ្នែកៗ តាមរបៀបអឺរ៉ុបលោកខាងលិច បើបរិយាយវិញ គឺអឺរ៉ុបខាងកើតធ្លាក់ចុះជាងអឺរ៉ុបខាងលិច ហើយនិងកុំភ្លេចថា នៅក្នុងបរិបថរបស់ពិភពនាសម័យនោះជាតិ ឬ ប្រទេសដែលឯករាជ្យក៏នៅមានកម្រិតជាពិសេសនៅអាស៊ី និងអាហ្វ្រិក។ បើអធិប្បាយអំពីអត្ថន័យនៃពណ៌គឺ មានលក្ខណៈជាត្រៃវង្គ គឺពណ៌សតំណាងឲ្យសាសនារីឯពណ៌ក្រហមសម្គាល់ព្រះមហាក្សត្រឬសារជាតិជាអ្នកចម្បាំងនៃវីរៈបុរសខ្មែរ ចំណែកពណ៌ខៀវជាគ្រឿងសម្គាល់អធិបតេយ្យភាព ។



ទង់ជាតិ ផែនដីកម្ពុជា ពីឆ្នាំ ១៨៦៣-១៩៤៨

ក្រៅពីទង់ជាតិ ដែលជានិមិត្តសញ្ញាសម្គាល់ជាតិគេបានប្រើ គ្រឿងលម្អខ្លះទៀតដើម្បីផ្តល់កិត្តិយស និងឱឡារិកភាព នៅក្នុងព្រះរាជពិធីដង្ហែក្បួនធំៗដូចជា**ចាមរ សែនត្វូន**[២០] **បែមន់**[២១] **ក្លស់ អភិរម្យ**[២២]ជាដើមៗ តែអ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺមកដល់សម័យនេះ យើងនៅតែពុំដឹងថា ខ្មែរមានបទគោរពទង់ជាតិ និង

(២០) សែនត្វូនគឺជាផ្ចិតមានសណ្ឋានមូលធ្វើអំពីសំពត់ផ្កាមាស ឬផ្កាប្រាក់ជាដើមមានដងកូក់ខាងចុង ប្រើសម្រាប់ជាគ្រឿងបាំងកំដៅថ្ងៃមិនឲ្យចាំងត្រូវ។

(២១) បែមន់គឺជាគ្រឿងប្រដាប់មួយប្រភេទមានសណ្ឋានដូចស្លឹកមនមានដងស្រដៀងនឹងចាមរដែរ ប៉ុន្តែត្រង់កំពូលមានរាងស្រួចរៀវ ហើយរៀចកូក់ងាកទៅខាងបន្តិច។

(២២) អភិរម្យ ឬអភិរំ គឺជាឆ័ត្ររួតមានរំកាយដូចក្លស់ សម្រាប់ជាគ្រឿងរុងរឿង រីឯចាមរគឺជាគ្រឿងមួយប្រភេទ មានសណ្ឋានដូចផ្ចិតសម្រាប់មន្ត្រីសង្ឃរាជាគណៈដូច្នោះ ប៉ុន្តែគ្មានកំពូល និងផែកៗជុំវិញទេ ហើយមានដងវែងៗ គ្រឿងប្រដាប់ទាំងប៉ុន្មានប្រភេទនេះឃើញមានប្រើដើម្បីលើកកិត្តិយស និងសេចក្តីរុងរឿងនៅក្នុងព្រះរាជពិធីហែក្បួនធំៗ ដូចជាក្នុងព្រះរាជាពិធីរាជាភិសេកជាដើម ៕

សញ្ញាជាតិនោះទេ ព្រោះយើងចាប់អារម្មណ៍ថា កាលណាមានទង់ជាតិគួរមានភ្លេងគោរពទង់ជាតិ។ អ្វីដែលបានរៀបរាប់មកនេះគឺឯកសារត្រូវបានបាត់បង់ដោយសារសង្គ្រាម។ ម្យ៉ាងទៀតស្របពេលជាមួយគ្នានេះដែរ បញ្ហានិន្នាការនយោបាយពិភពលោក គឺជាបញ្ហាប្រឈម ដូច្នេះបរិយាកាសនៅក្នុងបរិបថសង្គមកម្ពុជានាចន្លោះសម័យនោះ គឺត្រូវបានធ្លាក់ក្រោមការត្រួតត្រារបស់អាណានិគម ដោយហេតុដូចនេះហើយ ទង់ជាតិរបស់អាណានិគម ក៏បានត្រូវកំណត់ផងដែរ ដូចជា៖

### ក១. អាណានិគមបារាំងសែស ពីឆ្នាំ១៨៨៧-១៩៤២

នៅក្នុងស្ថានភាពពេលនោះ ប្រទេសកម្ពុជាស្ថិតនៅក្រោមនឹមអាណាព្យាបាលបារាំងសែស នៃសន្ធិសញ្ញាចុះថ្ងៃទី១ ខែសីហា ឆ្នាំ១៨៦៣ គឺជាសន្ធិសញ្ញាទីមួយនៃអាណាព្យាបាលបារាំងសែសមកលើប្រទេសកម្ពុជាតាមរយៈសន្ធិសញ្ញានេះបារាំងសែស បានក្លាយជាអាណាព្យាបាលតំណាងកម្ពុជា ដែលស្ថិតនៅក្រោមអំណាចទេសាភិបាលតំណាងបារាំងសែសនៅកូសាំងស៊ីន។ ប៉ុន្តែអាណាព្យាបាលបារាំងសែស ដែលក្លាយទៅជាអាណានិគមពិតប្រាកដពីឆ្នាំ១៨៨៧មក ដោយយកចិត្តទុកដាក់ខ្លាំងឡើងៗទៅលើអង្គរ។

សូមបញ្ជាក់ថា បញ្ហាសន្ធិសញ្ញានៃអាណាព្យាបាលបារាំងសែសមកលើកម្ពុជា គឺជាដើមកំណើតនៃស្ថានភាពនាំឲ្យប៉ះពាល់បញ្ហាគំនូសព្រំដែន ដោយបានបន្សល់ទុកក្នុងពេលធ្វើអាណាព្យាបាលរហូតដល់សព្វថ្ងៃ ។

ប្រទេសកម្ពុជានៅពេលនោះ បញ្ហាមួយដែលត្រូវចោទឡើងក្នុងចំណោមបញ្ហាផ្សេងៗជាច្រើនទៀតនោះ គឺស្តីអំពីលក្ខណៈនៃអត្តសញ្ញាណជាតិ ជាពិសេសបញ្ហាអំពីអត្តសញ្ញាណទង់ជាតិរបស់អាណានិគមបារាំងសែសក៏ត្រូវកំណត់ដែរៗ មិនតែប៉ុណ្ណោះ សូម្បីតែបញ្ហាអក្សរសាស្ត្រខ្មែរ ក៏អាណានិគមបារាំងសែសមានគម្រោងការណ៍សរសេរភាសាខ្មែរដោយប្រើអក្សរឡាតាំង ប៉ុន្តែត្រូវបានអាក់ខានវិញ ព្រោះមានចលនាបះបោរយ៉ាងខ្លាំងក្លា នៃព្រះសង្ឃក៏ដូចជាប្រជាពលរដ្ឋខ្មែរៗ



រូបគំនូរពុទ្ធប្រវត្តិ
នៅវត្តអង្គរាជបុរី



ទង់ជាតិអាណានិគមបារាំងសែស
ឆ្នាំ១៨៨៧-១៩៤២

## ក៣. ការគ្រប់គ្រងដោយជប៉ុន ពីឆ្នាំ ១៩៤២-១៩៤៥

ទោះបីនៅឆ្នាំ ១៨៦៣ ប្រទេសបារាំងសែសចាប់ផ្តើមត្រួតត្រាធ្វើជាអាណាព្យាបាលលើកម្ពុជាក៏ដោយ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៣៧ មក ប្រទេសជប៉ុនដែលជាប្រទេសចក្រពត្តិយោធានិយមចាប់ផ្តើមពង្រីកឥទ្ធិពលរបស់ខ្លួន ជាពិសេសច្បាំងចេញមុខប្រឆាំងប្រទេស

ចិន ហើយព្រមទាំងបានកាន់កាប់ភាគខ្លះនៃប្រទេសនេះទៀតផង។ ប្រទេសបារាំងសែស និងប្រទេសអង់គ្លេស គាំទ្រលោក ជៀង កៃជៀក ដែលច្បាំងទប់ទល់នឹងកងទ័ពជប៉ុន។ ប្រទេសបារាំងសែស និង ប្រទេសអង់គ្លេសតែងផ្តល់ជំនួយយោធាដល់ប្រទេសចិន តាមស្រុក តុងកឹង ។ ថ្ងៃទី១៩ ឧសភា ១៩៤០ គឺពីរថ្ងៃក្រោយប្រទេសបារាំង យល់ព្រមចុះចាញ់នៃសង្គ្រាមកងទ័ពអាឡឺម៉ង់។ឆ្លៀតក្នុងឱកាសនោះ ប្រទេសជប៉ុន ព្រមានអាណានិគមមិនឲ្យជួយកងទ័ពចិនទៀត។ បី-បួនថ្ងៃបន្ទាប់មក កងទ័ពជប៉ុនក៏ចូលកាន់កាប់ស្រុកតុងកឹង។ ខែ កក្កដា ១៩៤០ កងទ័ពជប៉ុនមកដល់ប្រទេសកម្ពុជា ។

នៅថ្ងៃទី៣០ សីហា ១៩៤០ រដ្ឋាភិបាលបារាំងសែស ដែលបាន ចុះចាញ់ពួកអាឡឺម៉ង់ ព្រមទទួលស្គាល់ថា "ប្រទេសជប៉ុន ត្រូវការ ជាចាំបាច់នូវភូមិភាគអាស៊ីចុងបូព៌ាប្រទេស"។ នៅខែ កញ្ញា ១៩៤០ រដ្ឋាភិបាលបារាំងសែសអនុញ្ញាតឲ្យកប៉ាល់ ជប៉ុនមានសិទ្ធិចូលមក កំពង់ផែ ហៃហ្វុង និងមានសិទ្ធិប្រើប្រាស់វាលយន្តហោះ ទាំងប៉ុន្មាន នៅឥណ្ឌូចិន ។

ជារួមកងទ័ពជប៉ុន បានវាយយកមូលដ្ឋានរបស់បារាំងសែស ទាំងឡាយ នាថ្ងៃទី១៤ មិថុនា ១៩៤៥ ដោយបានកាន់កាប់ឥណ្ឌូចិន ទាំងមូល ព្រោះប្រទេសជប៉ុនយកឥណ្ឌូចិនជាមូលដ្ឋានទ័ពយុទ្ធសាស្ត្រ ប្រយុទ្ធជាមួយប្រទេសចិន។ ហេតុនេះហើយបានជានៅចន្លោះពេល នោះ ពីឆ្នាំ១៩៤២-១៩៤៥ ប្រទេសជប៉ុនគ្រប់គ្រងកម្ពុជា ជំនួស អាណានិគមបារាំងសែស ហើយទង់ជាតិក៏មានការបញ្ជាក់ជាការ គ្រប់គ្រងនៅពេលនេះ។



ទង់ជាតិការគ្រប់គ្រង់ដោយជប៉ុន ឆ្នាំ ១៩៤២-១៩៤៥

### ក៣. អាណានិគមបារាំងសែសពីឆ្នាំ ១៩៤៥-១៩៤៨

នៅថ្ងៃទី០៩ សីហា ១៩៤៥ កងអាកាសចរណ៍អាមេរិក បានទម្លាក់គ្រាប់បរិមាណូ នៅទីក្រុង ហេរ៉ូស៊ីម៉ា និងណាកាសាគី ធ្វើឲ្យប្រទេសជប៉ុនប្រកាសចុះចាញ់សង្គ្រាម ក្រោយពេលដែលត្រូវសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបរិមាណូ ។

មូលដ្ឋានកងទ័ពជប៉ុន ត្រូវបានដកចេញពីឥណ្ឌូចិន ជាហេតុបណ្ដាលឲ្យអាណានិគមបារាំងសែស មានជីវិតរស់ឡើងវិញនៅឥណ្ឌូចិន ហើយទង់ជាតិសម័យអាណានិគមបារាំងសែស ដែលមានពីមុនក៏ត្រូវបានត្រឡប់មកប្រើប្រាស់វិញ។ គួរកត់សម្គាល់ថាតុលាការអន្តរជាតិទីក្រុងឡាអេ បានសម្រេចសេចក្ដីឲ្យកម្ពុជាឈ្នះថៃលើប្រាសាទព្រះវិហារ នៅថ្ងៃទី១៥ មិថុនា ១៩៦២ គឺតាមរយៈព្រឹត្តិការណ៍ ដំណើរទស្សនកិច្ចនៃព្រះអង្គម្ចាស់ ដាម រ៉ុង អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធានវិទ្យាស្ថានភូមិន្ទសៀម ទទួលបន្ទុក

ការងារទាក់ទងនឹងបណ្ណាល័យបុរាណវត្ថុវិទ្យា មកកាន់ប្រាសាទព្រះវិហារក្នុងឆ្នាំ១៩៣០ ព្រះអង្គម្ចាស់ត្រូវបានទទួលស្វាគមន៍ ជាផ្លូវការដោយតំណាងបារាំងសែសប្រចាំនៅកម្ពុជាក្នុងនាមអាណាព្យាបាលកម្ពុជាដោយមានបង្ហូតទង់ជាតិនេះទៀតផង។



ទង់ជាតិកអាណានិគមបារាំងសែស
ឆ្នាំ១៩៤៥-១៩៤៨

## ខ. ព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ១៩៤៨-១៩៧០

នៅថ្ងៃទី ០៧ មករា ១៩៤៦ បារាំងសែសបានចុះសន្ធិសញ្ញាបណ្ដោះអាសន្នម៉ូឌីសវីវេនឌី(Modus Vivendi) បានន័យថាបារាំងសែសបានទទួលស្គាល់ស្វ័យភាពផ្ទៃក្នុងរបស់កម្ពុជា។ តមកនៅឆ្នាំ១៩៤៧ អាណានិគមនិយមបារាំងសែសបានអនុញ្ញាតឲ្យមានគណបក្សនយោបាយ ដើម្បីចូលរួមបោះឆ្នោតជាលើកដំបូងនៅប្រទេសកម្ពុជា។ បន្ទាប់មករដ្ឋសភាបានអនុម័តយករដ្ឋធម្មនុញ្ញទី១របស់ប្រទេស

ហើយបានប្រកាសតាមក្រឹត្យច្បាប់ថាជា "ព្រះរាជាណាចក្រកម្ពុជា"។ ហេតុនេះ ហើយបានជាអំណឹះតមកទៀតប្រទេសកម្ពុជា នៅឆ្នាំ ១៩៥៥ នាសម័យនោះត្រូវបានអ្នកប្រវត្តិសាស្ត្រហៅថា "**សម័យសង្គមរាស្ត្រនិយម**" ដែលហៅតាមឈ្មោះគណបក្សនយោបាយមួយ ដែលប្រកាន់ គោលការណ៍ឯករាជ្យ អព្យាក្រឹត្យ សង្គមនិយមព្រះពុទ្ធសាសនា ក្រោមការដឹកនាំរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ។ នៅថ្ងៃទី២០ តុលា ឆ្នាំ១៩៤៨ គឺជាការចាប់ផ្តើមមានការវិវត្តមួយដោយទង់ជាតិត្រូវបានផ្លាស់ប្តូរ។ តមកទៀត នៅថ្ងៃទី០៨ វិច្ឆិកា១៩៤៩ បារាំងសែសបានចុះសន្ធិសញ្ញាប្រគល់ឯករាជ្យដល់កម្ពុជា បានន័យថា អាណានិគមបារាំងសែសបានយល់ព្រមប្រគល់ឯករាជ្យភាពពាក់កណ្តាលដល់ប្រទេសកម្ពុជា។ ទោះបីជាយ៉ាងនេះក្តីឯករាជ្យនេះ គឺជាឯករាជ្យមានព្រំដែន ប៉ុន្តែជាមួយគ្នានោះបារាំងសែសនៅតែរក្សាការគ្រប់គ្រងផ្នែកសំខាន់ៗមួយចំនួនក្នុងប្រទេសកម្ពុជាដដែល ។

នៅឆ្នាំ១៩៥២ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ បានប្រកាសអំពី "ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ" តាមរយៈរាជបូជនីយកិច្ចនេះ នៅថ្ងៃទី០៩ វិច្ឆិកា ១៩៥៣ ប្រទេសបារាំងសែសបានបញ្ចប់អាណានិគមលើកម្ពុជា ដែលមានរយៈពេលប្រមាណ៩០ ឆ្នាំ នេះគឺជាឯករាជ្យដែលបារាំងសែស យល់ព្រមប្រគល់ជូនប្រទេសកម្ពុជាពេញបរិបូរណ៍ ហើយកម្ពុជាជាប្រទេសទីមួយ ដែលបានទទួលឯករាជ្យពីអាណានិគមនិយមបារាំងសែស បើគិតពីប្រទេសនានានៅឥណ្ឌូចិន។ បើរៀបរាប់អំពីសន្តតិវង្សព្រះមហាក្សត្រខ្មែរ **ព្រះបាទ នរោត្តម សីហនុ** ប្រហែលជាព្រះមហាក្សត្រទី ១០៨ នៃ

ព្រះរាជវង្សនៃប្រទេសកម្ពុជា។ ព្រះអង្គប្រសូត្រនៅរាជធានីភ្នំពេញ ថ្ងៃអង្គារ ១១ កើត ខែកត្តិក ឆ្នាំច ចត្វាស័កព.ស ២៤៦៦ ត្រូវនឹងថ្ងៃទី ៣១ តុលា ១៩២២ ។

ព្រឹត្តិការណ៍នៃដំណឹងប្រសូត្ររបស់ទ្រង់នេះ បាននាំឲ្យព្រះរាជវង្សានុវង្សខាងព្រះបរមរាជបិតា (នរោត្តម) និង ព្រះវររាជមាតា (ស៊ីសុវត្ថិ) មានសេចក្តីរីករាយពន់ពេក ព្រោះឆ្នាំប្រសូត្ររបស់ព្រះអង្គបានស្របនឹងឆ្នាំប្រសូត្ររបស់ព្រះសាម្មាសម្ពុទ្ធផងនោះ។ គេរិតតែមានជំនឿយ៉ាងមុតមាំនៃព្រះបារមីនៃរាជកុមារណាស់ទៅទៀត ភស្តុតាងនៃសេចក្តីសរសើរនេះ បានដក់ជាប់នៅក្នុងក្រអៅបេះដូងខ្មែរស្ទើរគ្រប់រូបមានចំពោះព្រះអង្គ អ៊ុចឹងហើយបានជាកាលនោះក្រោយពេលធ្វើព្រះរាជពិធីថ្វាយព្រះភ្លើង ព្រះរាជអយ្យកោរបស់ព្រះអង្គស្រេចហើយ នៅថ្ងៃសៅរ៍ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ ត្រីស័ក ត្រូវនឹងថ្ងៃទី២៨ តុលា ១៩៤១ ក៏មានធ្វើព្រះរាជពិធីរាជាភិសេកនៅព្រះទីនាំងទេវាវិនិច្ឆ័យ ដោយមានហែប្រទក្សិណទីក្រុងតាមប្រពៃណី ក្នុងឱកាសព្រះរាជពិធីនេះ ព្រះចៅ **ស៊ីសាវ៉ាងវង្ស** ព្រះរាជតំណាងព្រះចៅ **ប៉ៅដាយ** និងលោកឧត្តមនាវាឯក ហ្សង់ដឺគូ Amiral Jean De Caux Gouverneur Géneral បានស្តេចយាង និង អញ្ជើញជាអធិបតីលុះធ្វើពិធីមុទ្ធាភិសេករួចនៅចំពោះមុខព្រះមហាស្វេតច្ឆត្រ គេបានថ្វាយព្រះនាមព្រះមហាក្សត្រ ដោយមានចារិកលើព្រះសុវណ្ណបត្រថា "**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧបតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរដ្ឋ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅប្រទេសកម្ពុជា**"។

បើបរិយាយអំពីទង់ជាតិ ដែលបានផ្លាស់ប្តូរនៅឆ្នាំ១៩៤៨ នេះ គឺបានបង្ហាញពីខ្មែរខិតខំចាប់ផ្តើមបញ្ជាក់ពីអត្តសញ្ញាណជាតិឡើងវិញ តាមរយៈប្រព័ន្ធនៃជំនឿមោទនភាពជាតិខ្មែរ អំពីប្រាសាទអង្គរវត្ត ដែលត្រូវបានជ្រើសរើសយកប្រាសាទកំពូលបីដាក់ក្នុងផ្ទៃទង់ជាតិ ជាការបញ្ជាក់អំពីភាពរឹងមាំរបស់ខ្មែរដូចមហានគរ គឺគេអាចពិពណ៌នាបានថាៈ

ទង់ជាតិ មានសណ្ឋានបួនជ្រុងទ្រវែង តាមខ្នាតទង់ជាតិអន្តរជាតិហើយមានពណ៌ខៀវ អមពណ៌ក្រហម ឆូតបណ្តោយ ស្របគ្នាលើផ្ទៃទង់ គឺពណ៌ខៀវ ឆូតលើគែមសង្ខាងទំហំនីមួយៗ ប្រមាណ ១ភាគ៤ អមពណ៌ក្រហមដែលមានទំហំប្រមាណជិត ២ភាគ៤ នៅកណ្តាល។ នៅលើផ្ទៃពណ៌ក្រហមនេះមានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌ស បិតនៅចំកណ្តាល។ ក្នុងបណ្តាពណ៌ទាំងបីនេះ ពណ៌នីមួយៗត្រូវបានគេបកស្រាយ នឹងផ្តល់អត្ថន័យនិមិត្តរូបផ្សេងៗគ្នា ឬល្អៀងពីគ្នាទៅតាមទស្សនៈយល់ឃើញរៀងៗខ្លួន។ ប៉ុន្តែជារួមគេនិយមឲ្យអត្ថន័យដូចតទៅនេះ ពណ៌ខៀវ តាងសេចក្តីរុងរឿងថ្លៃថ្នូរ សុចរិតយុត្តិធម៌ស្មោះត្រង់របស់ជាតិ រីឯពណ៌ក្រហមតាងសេចក្តីអង់អាចក្លាហាន ឆន្ទៈមោះមុតរបស់ជាតិ ហ៊ានប្រយុទ្ធនិងធ្វើពលិកម្មគ្រប់យ៉ាង ដើម្បីការពារជាតិ និងមាតុភូមិ ដែលតាងដោយប្រាសាទអង្គរកំពូលបី ពណ៌ស ជំជានិមិត្តរូបនៃសេចក្តីបរិសុទ្ធ បញ្ញាញាណទេពកោសល្យ ត្រង់ត្រដោម អរិយធម៌ ត្រចេះត្រចង់បូរណភាពទឹកដី ឯកភាព អធិបតេយ្យរបស់ជាតិ។ ទង់ជាតិជានិមិត្តរូបនៃរាជបល្ល័ង្ករបស់ប្រជាជាតិខ្មែរ អ្នកការពាររាជបល្ល័ង្ក និងអារ្យធម៌របស់រាជាណាចក្រកម្ពុជា។



ទង់ជាតិព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៤៨-១៩៧០
ទង់ជាតិព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣...




***ព្រះសង្ហារៈ*** *មានរាងចតុកោណស្មើ ស្មើរស្មើជ្រុងលម្អរទៅដោយក្បាច់ភ្ញីទេស និងភ្ញីភ្លើង ជានិមិត្តរូបនៃភាពសម្បូរបែបនៃសិល្បៈ វប្បធម៌ និងភាពឧត្តុង្គឧត្តមនៃអារ្យធម៌ខ្មែរ ដែលមានតាំងពីព្រេងនាយមក ដែលតំណាងឲ្យនូវជាតុទាំងប្រាំ សម្រាប់រៀបចំព្រះរាជាឡើងគ្រងរាជ្យសម្បត្តិ ឬ ហៅថាពិធីស្វេតច្ឆត្រ មានអត្ថន័យជាអាទិ៍ៈ ទី១ ម្កុដរាជ, ទី២ ព្រះខ័នរាជ, ទី៣ ជើងពាន, ទី៤ ឆ័ត្ររូត, ទី៥ រាជសីហ៍ ឬ គុជសីហ៍។*

*ជាទូទៅ ព្រះសង្ការ ជាគ្រឿងសម្គាល់នៃអត្តសញ្ញាណជាតិ សម្រាប់ប្រើប្រាស់នៅលើក្បាលលិខិតផ្លូវការរបស់រដ្ឋ លិខិតឆ្លងដែន ជាដើម។*

*ព្រះសង្ការជាត្រា សម្រាប់ព្រះមហាក្សត្រ "**ព្រះចៅក្រុងកម្ពុជាធិបតី**"។*



ព្រះសង្ហារព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៨-១៩៧០
ព្រះសង្ហារព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣...

## គ. របបសាធារណរដ្ឋខ្មែរពីឆ្នាំ១៩៧០-១៩៧៥

*ក្នុងរជ្ជកាលព្រះករុណា **ព្រះបាទ នរោត្តម សីហនុ** ប្រទេសកម្ពុជាបានទទួលឯករាជ្យឆ្នាំ១៩៥៣ មកហើយដែលត្រូវបានអ្នកប្រវត្តិសាស្ត្របានហៅថា "**កោះសន្តិភាព**" មានរយៈពេលប្រហែល*

១៦ឆ្នាំ ត្រូវបានបញ្ចប់ ព្រោះក្រោមនយោបាយនៃសង្គ្រាមត្រជាក់[២៣] បានជម្រុញឲ្យមានរដ្ឋប្រហារ នៅថ្ងៃទី១៨ មីនា ១៩៧០ ដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ របបនយោបាយ ប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរពីរបប "រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" ទៅជារបប "សាធារណរដ្ឋ" ។

ទង់ជាតិ-ភ្លេងជាតិ-សញ្ញាជាតិ ត្រូវបានផ្លាស់ប្តូរថ្មី ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ នាថ្ងៃទី១០ ឧសភា ១៩៧២ ក្នុងជំពូក១ មាត្រា១ វាក្យខណ្ឌទី៤ ចែងថា: ទង់ជាតិ-ភ្លេងជាតិ និង រលញ្ជករនៃសាធារណរដ្ឋខ្មែរ គឺត្រូវបានផ្លាស់ប្តូរ បើពិពណ៌នាទង់ជាតិនៃរបបសាធារណរដ្ឋខ្មែរមានអត្ថន័យដូចតទៅ៖

ទង់ជាតិ សាធារណរដ្ឋខ្មែរមាន ៣ ពណ៌គឺ ខៀវ ស និង ក្រហម។ ទង់ជាតិនេះមានរាងចតុកោណកែង កម្ពស់មានប្រវែង ២ភាគ៣ នៃបណ្តោយ។ តួទង់ជាតិទាំងមូលមានពណ៌ខៀវ លើកលែងតែ ១ភាគ៤ នៃផ្នែកខាងលើជ្រុងខាងឆ្វេងដែលមានពណ៌ក្រហម។ នៅក្នុងផ្នែកក្រហមមានរូបប្រាសាទអង្គរវត្តពណ៌ស មើលចំពីមុខឃើញកំពូលប្រាសាទ៣ ។

នៅផ្នែកមួយភាគបួននៃពណ៌ខៀវ ភាគខាងលើមានផ្កាយ ៣ ពណ៌ស តម្រៀបគ្នាត្រង់តាមខ្សែដេក ។

---

[២៣] ប្លុកម្ខាងកុម្មុយនីស ប្លុកម្ខាងសេរី

**ន័យនៃពណ៌ និង រូបភាព មានដូចតទៅនេះ :**

- **ពណ៌ខៀវ** តំណាងសីលធម៌។ ពណ៌នេះសម្តែងនូវសន្តានចិត្ត សុចរិតយុត្តិធម៌ និងសុភមង្គលត្រជាក់ត្រជុំរបស់ប្រជាពលរដ្ឋខ្មែរ។

- **ពណ៌ក្រហម** តំណាងទឹកចិត្តអង់អាច និង ក្លាហានមុះមុត នៃប្រជាពលរដ្ឋខ្មែរ។

- **ពណ៌ស** ដែលជានិមិត្តរូបនៃភាពបរិសុទ្ធ និង ភាពទៀងត្រង់ ស្អាតស្អំ តំណាងព្រះពុទ្ធសាសនា។

- **រូបប្រាសាទ** ជានិមិត្តរូបនៃអារ្យធម៌ និងសេចក្តីថ្កុំថ្កើងនៃ ប្រទេសជាតិ។

- **រូបផ្កាយ** ជានិមិត្តរូបនៃវឌ្ឍនធម៌ និង នក្ខត្តឫក្សចំនួន ៣ នៃផ្កាយ នេះមានន័យថា:

- ត្រីបាវចនាគឺ ជាតិ សាសនា សាធារណរដ្ឋ ។
- រតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។
- អំណាចទាំង៣ គឺ និតិបញ្ញត្តិ និតិប្រតិបត្តិ និង តុលាការ ។



ទង់ជាតិនៃរបបសាធារណរដ្ឋខ្មែរឆ្នាំ១៩៧០-១៩៧៥



*ភ្លេងជាតិ មានឈ្មោះថាដំណើរសាធារណរដ្ឋខ្មែរ ប្រហែលជានិពន្ធឡើងដោយលោកសាស្ត្រាចារ្យ ម៉ម បូផានី ជានាយកសាលាតូរ្យតន្ត្រីក្នុងសតវត្សឆ្នាំ១៩៧០*[២៦]*។*

## ដំណើរសាធារណរដ្ឋខ្មែរ

LA MARCHE DE LA REPUBLIQUE KHMERE

ជនជាតិខ្មែរ ល្បីពូកែមួយក្នុងលោក មានជ័យជោគ

កសាងប្រាសាទសិលា អារ្យធម៌ខ្ពស់ បវរជាតិសាសនា

កេរដូនតាទុកលើភពផែនដី ខ្មែរក្រោកឡើង ខ្មែរក្រោកឡើង

ខ្មែរក្រោកឡើង តស៊ូតម្កើងសាធារណរដ្ឋ ខ្លាំងរំលោភ

ខ្មែរប្រយុទ្ធ មិនតក់ស្លុត យកជ័យបំផុត

ជូនជាតិខេមរា ឯករាជ្យភ្លឺថ្លា ជាមហាប្រទេសតទៅ ។

---

(២៦) *ប្រសាសន៍លោកសាស្ត្រាចារ្យ ប៉ែន សំអុល ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យតូរ្យតន្ត្រី*

# ដំណើរសាធារណរដ្ឋខ្មែរ

## LA MARCHE DE LA REPUBLIQUE KHMERE




***រដ្ឋសង្ហារ*** : *នៃសាធារណរដ្ឋខ្មែរមានរូបសំណាកគម្ពីរ រដ្ឋធម្មនុញ្ញភ្ជាប់នឹងរូបប្រាសាទអង្គរវត្ត រូបផ្កាយ៣ កម្រងភ្ញី រចនាដោយក្ដួរស្រូវស្នាកមួយមានសរសេរអក្សរចារិកខ្មែរថា: "**សាធារណរដ្ឋខ្មែរ**"។*

*រូបសំណាកគម្ពីរ រដ្ឋធម្មនុញ្ញតំកល់លើទ្រនាប់ជើងពានពីរជាន់ដែលមានបាតភ្ជាប់ទៅលើក្បាច់ភ្ញីភ្លើងពីរ។ រូបសំណាកនេះស្ថិតនៅក្នុងរង្វង់ពងក្រពើ មានស្នួលឈរត្រង់ទៅលើ ហ៊ុមព័ទ្ធដោយកាំរស្មី។ កាំរស្មីដែលវែងជាងគេក្នុងបណ្ដាកាំរស្មីទៀត ចង្អុលទិសទាំងប្រាំបី។*

ផ្នែកខាងលើនៃរូបក្បាច់ភ្ញីទាំងនេះ ដែលហ៊ុមព័ទ្ធទាំងសង្ខាង ដោយរូបនាគពីរជាភ្ញីភ្ញើងទ្រភ្ជាប់ទៅនឹងរូបប្រាសាទអង្គរវត្ត។

នៅលើរូបប្រាសាទអង្គរវត្ត មានរូបផ្កាយបី ដែលជានិមិត្តរូប នៃបាវចនាគឺ **ជាតិ សាសនា សាធារណរដ្ឋ** និង **រតនត្រ័យ** ព្រមទាំងអំណាចទាំងបី"៣"។

រូបផ្កាយទាំងបីនេះភ្ជាប់ទៅនឹងក្បាច់ភ្ញីកាំរស្មី ដែលមានទំហំធំតូចជាលំដាប់។

រូបសំណាកទាំងឡាយនេះស្ថិតនៅក្នុងរង្វង់កម្រងភ្ញីរាងកោង ទៅលើ រចនាដោយកួរស្រូវចងក្រងដោយអន្ទើ និង បូរហូតដល់ផ្នែកខាងក្រោម ។

ស្លាកមួយរាងកោងបន្តិច បូចុងសង្ខាងស្ថិតនៅជិតផ្នែកក្រោម នៃកម្រងនេះមានចារិកអក្សរខ្មែរថា "**សាធារណរដ្ឋខ្មែរ**"។

រដ្ឋសង្ហារធ្វើឡើងពីថាសទាំងមូល ឬ លាបពណ៌មាស លើកលែងតែអក្សរចារិក។




រដ្ឋសង្ហារ នៃរបបសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧០-១៩៧៥

## ឃ. របបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩

តាមឥន្ទទំនាយ ដែលបានតំណាលថា "មានផ្ទះឥតមនុស្ស នៅមានផ្លូវឥតមនុស្សដើរ" គឺហាក់ដូចជាការព្យាករណ៍ពីអ្នកប្រាជ្ញណាម្នាក់ អំពីជោគវាសនាអនាគតប្រទេសកម្ពុជា ដែលនាំឲ្យកើតមានសង្គ្រាម ទុក្ខលំបាក និងការបង្ហូរឈាមឥតឈប់ឈរ។ តាមរយៈឥន្ទទំនាយនេះ គឺបន្ទាប់ពីជ័យជម្នះដោយការច្បាំងគ្នាយ៉ាងព្រៃផ្សៃបំផុត អស់រយៈពេលប្រមាណ៥ឆ្នាំ មកគឺនៅថ្ងៃទី១៧ មេសា ១៩៧៥ ពួកខ្មែរក្រហមឈ្នះលើរបបសាធារណរដ្ឋមក បានហៅជ័យជម្នះនេះថា "មហាលោតផ្លោះ មហាអស្ចារ្យទី១" នៃប្រវត្តិសាស្ត្រកម្ពុជា ដែលមានតាំងពីរាប់ពាន់ឆ្នាំកន្លងមក ។

ក្រោយពីទទួលបានជ័យជម្នះ របបនយោបាយសង្គមកម្ពុជាបានប្រែក្លាយពីរបបសាធារណរដ្ឋ ទៅជារបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជារបបកុម្មុយនីស្តផ្តាច់ការយ៉ាងឃោរឃៅបំផុត ។

ទង់ជាតិ-ភ្លេងជាតិ-សញ្ញាជាតិ ត្រូវបានផ្លាស់ប្តូរជាបន្តទៀត ដូចមាន ចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនៅក្នុងមហាសន្និបាតជាតិលើកទី៣ អនុម័តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ប្រកាសប្រើជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ក្នុងជំពូក១១ មាត្រា១៦ អំពីទង់ជាតិមានរូបភាព និងខ្លឹមសារដូចតទៅ ៖

ផ្ទៃក្រហម មានរូបប្រាសាទកំពូលបីពណ៌លឿងនៅចំកណ្តាល។

– ផ្ទៃក្រហម ជានិមិត្តរូបនៃចលនាបដិវត្ត ការប្រយុទ្ធ មោះមុត

អង់អាចក្លាហាន ក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិ កម្ពុជារបស់ប្រជាជនកម្ពុជា ។

- ប្រាសាទពណ៌លឿង ជានិមិត្តរូបនៃប្រពៃណីជាតិ និង ប្រជាជនកម្ពុជា ដែលជាអ្នកការពារប្រទេសជាអ្នកស្ថាបនាប្រទេស ឲ្យបានថ្កុំថ្កើងរុងរឿង។



ទង់ជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥-១៩៧៩

**សញ្ញាជាតិ** គឺមានប្រព័ន្ធភ្លឺស្រែ និង ប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន មានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវ រាងជាស្នែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរចារឹកថា "**កម្ពុជាប្រជាធិបតេយ្យ**" នៅពីក្រោម។



សញ្ញាជាតិ នៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥-១៩៧៩

***ភ្លេងជាតិ*** *នៃកម្ពុជាប្រជាធិបតេយ្យ គឺមានឈ្មោះថា៖* ***"១៧ មេសា មហាជោគជ័យ"*** *និពន្ធដោយ ប៉ុលពត[២៥]។ តែបើតាម លោក* ***ប៉ែន សំអុល*** *ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យតូរ្យតន្ត្រី មាន ប្រសាសន៍ថា បទភ្លេងជាតិនេះប្រហែលជានិពន្ធឡើងដោយក្រុម និស្សិតតន្ត្រីបុរាណមួយក្រុម ដែលបានទៅសិក្សានៅប្រទេសកូរ៉េ ខាងជើង ហើយវិលត្រឡប់មកមាតុភូមិវិញ តាមការអំពាវនាវរបស់ ប៉ុល ពត រួចក៏បាននិពន្ធបទភ្លេងជាតិនេះឡើង ដោយយកតាមចលនា ទម្រង់នៃភ្លេងខ្មែរ។ សម័យកាលនោះ ឯកសារសំណេរស្ទើរតែទាំង អស់ត្រូវបាត់បង់ ម្យ៉ាងទៀតបញ្ញាវន្តត្រូវបានចាត់ទុកថាជាសត្រូវ ដ៏ធំរបស់អង្គការ ជាហេតុនាំឲ្យគ្មានបន្សល់សំណេរដែលបានបន្សល់ ទុកមកដល់សព្វថ្ងៃនេះឡើយ។ ជាការកត់សម្គាល់នោះភ្លេងជាតិ គោរពទង់ជាតិសម័យខ្មែរក្រហម បានបង្ហាញពីភាពសាហាវ ប្ដូរផ្ដាច់*

(២៥) *ឌី ខាំបូលី, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥-១៩៧៩ , ភ្នំពេញ*

*ក្នុងការការពារទឹកដី ដោយចាប់ផ្ដើមថា "ឈាមក្រហមច្រាល..." ក្នុងន័យសំដៅការការពារទឹកដីពីការឈ្លានពានរបស់បរទេស បើតាមការដាក់ស្ដែងក្នុងរបបនេះគឺសំដៅតែការឈ្លានពានពីប្រទេសវៀតណាមតែប៉ុណ្ណោះ ដោយឡែកចំពោះប្រទេសថៃឡង់ដ៍ គឺហាក់ដូចជាពុំត្រូវបានមេដឹកនាំខ្មែរក្រហម ផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ឡើយ។ តើអ្វីទៅជាឆន្ទៈពិតនៃមេដឹកនាំខ្មែរក្រហម ចំពោះបុព្វហេតុការពារទឹកដី?*

## ចម្រៀងជាតិ
## កម្ពុជាប្រជាធិបតេយ្យ
### "១៧ មេសា មហាជោគជ័យ"

ឈាមក្រហមច្រាល ស្រោចស្រពក្រុងវាលកម្ពុជា មាតុភូមិ ឈាមកម្មករ កសិករដ៏ឧត្ដម ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍។

ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ១៧ មេសា ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុតពីភាពខ្ញុំគេ ។

ជយោ! ជយោ ១៧ មេសាជោគជ័យ មហាអស្ចារ្យ មានន័យធំធេងលើសម័យអង្គរ។ យើងរួបរួមគ្នាកសាងកម្ពុជា និងសង្គមថ្មីបវរ ប្រជាធិបតេយ្យ សមភាព និង យុត្តិធម៌ តាមមាគ៌ាម្ចាស់ការ ឯករាជ្យ រឹងមាំ ប្ដេជ្ញាដាច់ខាត ការពារមាតុភូមិ ទឹកដីឧត្ដមបដិវត្តន៍ដ៏រុងរឿង ។

ជយោ! ជយោ! ជយោ កម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូរថ្កុំថ្កើង ប្តេជ្ញាប្រជាង គ្រវីទង់បដិវត្តន៍ក្រហមខ្ពស់ឡើង សាងមាតុភូមិយើង ឲ្យចម្រើនលោតផ្លោះ មហារុងរឿង មហាអស្ចារ្យ ។

## ង. របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ ១៩៧៩-១៩៨៩

*ក្រោយពីការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ដែលពួកអ្នកប្រវត្តិសាស្ត្រ ហៅថារបបខ្មែរក្រហម "**ទង់ជាតិ ភ្លេងជាតិ សញ្ញាជាតិ**" ត្រូវបានផ្លាស់ប្តូរ ស្របតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជានាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១។ ក្នុងជំពូក៩ នៃរដ្ឋធម្មនុញ្ញចែងអំពីសញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ ។*

***សញ្ញាជាតិ*** *នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាងមូលផ្ទៃក្រហម មានកម្រងកួរស្រូវពណ៌មាស អមសង្ខាងជារង្វង់ស្នែងក្របីជួបគ្នាខាងចុង។ ខ្សែបូក្រហមរុំព័ទ្ធផ្នែកខាងក្រោមនៃកម្រងកួរស្រូវជាពីរថ្នាក់។ នៅកណ្តាលខ្សែបូមានចារិកអក្សរមាសថា "**សាធារណរដ្ឋប្រជាមានិតកម្ពុជា**"។*

*សៀវភៅមាសរដ្ឋធម្មនុញ្ញ បើកទំព័រតម្កល់លើដើមស្រូវចងជាបូ។ កង់គ្រឿងចក្រចេញរាងពាក់កណ្តាល មានកាំ៧ ផ្នែកពីមុខសៀវភៅមាស។ នៅលើកង់គ្រឿងចក្ររូបប្រាសាទអង្គរវត្តកំពូល៥ពណ៌មាស ស្ថិតនៅចំរង្វង់កម្រងកួរស្រូវ។*




សញ្ញាជាតិ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៧៩-១៩៨៩
សញ្ញាជាតិ នៃរបបរដ្ឋកម្ពុជា ឆ្នាំ ១៩៨៩-១៩៩២

***ទង់ជាតិ*** *នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាង ចតុកោណកែង ពណ៌ក្រហម ចំកណ្តាលផ្ទៃមានប្រាសាទអង្គរវត្ត កំពូលប្រាំពណ៌មាស។*



ទង់ជាតិ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ ១៩៧៩-១៩៨៩



*ភ្លេងជាតិ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺនិពន្ធដោយ លោក **ជ័យ សោភា** ជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ ឃោសនាការ និងព័ត៌មាន។ និពន្ធទំនុកច្រៀងដោយលោក **កែវ ចិន្តា** រដ្ឋមន្ត្រីក្រសួង វប្បធម៌ ឃោសនាការ និងព័ត៌មាន។ ចម្លងអក្សរបែប ម៉ងដូលីន ដោយលោក **មាស សាឯម** ។*

## បទភ្លេងជាតិ
## របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង
## សម័យរដ្ឋកម្ពុជា

ពលរដ្ឋកម្ពុជាជាកម្លាំងប្តូរផ្តាច់ សច្ចាកំទេចអស់ពួកបច្ចាមិត្ត
តាំងចិត្តសាមគ្គីទើបមានមហិទ្ធិឫទ្ធិ ស៊ូប្តូរជីវិតបង្ហូរឈាមប្តូរយកជ័យ
កងទ័ពកម្ពុជាពុះពារក្លាហាន សំរុកឧបសគ្គរាំងមុខឆ្លងកាត់សម្រេចបាន
កំទេចខ្មាំងចង្រៃពូជសាមាន្យ នាំសិរីថ្កើងថ្កានជូនប្រជាជន

វីរៈកម្ពុជបុត្រមោះមុតក្នុងសង្គម    ប្ដេជ្ញាសងឈាមនឹងខ្មាំងសត្រូវ
ទង់ជ័យប្រាសាទពណ៌ឈាមខ្ពស់សន្ធៅ នាំជាតិឈានទៅសាងសុខក្សេមក្សាន្ត។

# បទភ្លេងជាតិ






## ច. របបរដ្ឋកម្ពុជា ពីឆ្នាំ ១៩៨៩-១៩៩២

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្តូរមកជា របបរដ្ឋកម្ពុជាវិញ គឺនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៨៩ ទង់ជាតិបានប្តូរតែរក្សានូវទម្រង់ សញ្ញាជាតិ និងបទភ្លេងជាតិដដែល គឺគ្រាន់តែសញ្ញាជាតិ នៅកណ្តាលខ្សែបូដោយគ្រាន់តែប្តូរពីការចារិកអក្សរមាសពី "សាធារណរដ្ឋប្រជាមានិតកម្ពុជា" មកថា "រដ្ឋកម្ពុជា" វិញតែប៉ុណ្ណោះ។ ស្របតាមរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ និងបានប្រកាសថា "រដ្ឋកម្ពុជា" រដ្ឋឯករាជ្យ សន្តិភាព និងមិនចូលបក្សសម្ព័ន្ធ។ ក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ជំពូក៩ ចែងអំពីទង់ជាតិ បើពណ៌នាឃើញថា៖

ទង់ជាតិមានផ្ទៃពណ៌ ខៀវក្រោម ក្រហមលើ ដែលមានទំហំផ្ទៃខៀវ និង ផ្ទៃក្រហមស្មើគ្នា ហើយទទឹងស្មើនឹង ២ភាគ៣ នៃបណ្តោយ។ឯរូបប្រាសាទខាងក្នុងជារូបប្រាសាទកំពូល៥ពណ៌លឿងប្រកបទៅដោយក្បូរក្បាច់រចនា កម្ពស់ពីបាតខឿនប្រាសាទទៅដល់កំពូលប្រាសាទកណ្តាលស្មើនឹងពាក់កណ្តាលនៃខឿនកម្ពស់ប្រាសាទស្មើនឹង ២ភាគ៥ នៃទទឹងផ្ទៃ។ មុំនៃកំពូលប្រាសាទកណ្តាលមកកំពូលប្រាសាទ សង្ខាងមាន១៣០អង្សារ។ ពណ៌ក្រហមតំណាងឧត្តុង្គឧត្តមអង់អាចក្លាហានរបស់ប្រជាជនកម្ពុជា ក្នុងការការពារ និងកសាងប្រទេសជាតិឲ្យសម្បូររុងរឿង ។

ពណ៌ខៀវ តំណាងប្រជាជនទាំងមូល ដែលអបអរសាទរទ្រព្យធនធានជាតិ និង តំណាងភោគផលធម្មជាតិទាំងលើ ដី ក្នុងទឹក ក្រោម

ទឹកឲ្យបិតបេរជាអមតៈ។

ពណ៌លឿងតំណាងអរិយធម៌ដ៏យូរលង់របស់ប្រជាជនកម្ពុជា និង សាសនា។ ពណ៌ទង់ជាតិនេះរាប់ថាមានលក្ខណៈត្រៃរង្គ។



ទង់ជាតិ នៃរបបរដ្ឋកម្ពុជាឆ្នាំ ១៩៨៩-១៩៩២

## ឆ. សម័យអ៊ុនតាក់ (UNTAC) ឆ្នាំ ១៩៩២-១៩៩៣

ពាក្យសន្តិភាពត្រូវបានខ្មែរអបអរសាទរហើយបានលេចឡើងតាមរយៈកិច្ចព្រមព្រៀងទីក្រុងបារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីបញ្ចប់ជម្លោះរវាងខ្មែរ និង ខ្មែរ ដោយភាគីខ្មែរទាំងបួនភាគីចុះហត្ថលេខា និងដោយមានតំណាងរដ្ឋាភិបាលផ្សេងៗទៀតចំនួន១៨ប្រទេស។ នេះជាការបើកទ្វារយ៉ាងចំហរក្នុងការផ្សះផ្សារជាតិខ្មែរឡើងវិញ ដែលបានបែកបាក់គ្នាជាង២ទសវត្សកន្លងមក។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ សម្តេចព្រះបាទ **នរោត្តម សីហនុ** និង សម្តេចព្រះអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** យាងនិវត្តន៍មកទីក្រុងភ្នំពេញជាលើក ដំបូងបន្ទាប់ពីនិរទេសព្រះកាយ ១៣ឆ្នាំ ក្រោមការ

ការពារពីអាផ្ទាធរបណ្ដោះអាសន្នរបស់ អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។

នៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩២ លោក **ប៊ូត្រូស ប៊ូត្រូស ហ្គាលី** (Boutros Boutros Ghali) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលទើបជាប់ឆ្នោតថ្មី បានតែងតាំងលោក **យ៉ាស៊ូស៊ុី អាកាស៊ុី** (Yasuhi Akashi) ជាតំណាងពិសេសរបស់លោកប្រចាំប្រទេសកម្ពុជា ក្នុងគោលបំណងរៀបចំការបោះឆ្នោតរវាងភាគីដែលមានជម្លោះទាំង៤ភាគី ប៉ុន្តែជាមួយគ្នានោះ ភាគីកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម បានធ្វើពហិការមិនចូលរួមបោះឆ្នោត។ នេះជាផែនទីបង្ហាញផ្លូវក្នុងការផ្សះផ្សារជាតិឡើងវិញ ដោយនាំឲ្យមានការរៀបចំការបោះឆ្នោតទៅតាមរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

សម័យអង្គការសហប្រជាជាតិ ចូលមករៀបចំការបោះឆ្នោត ទង់ជាតិក៏ត្រូវបានផ្លាស់ប្តូរផងដែរ សូមបញ្ជាក់ថា ទង់ជាតិដែលប្រើក្នុងអំឡុងពេលដែលអង្គការសហប្រជាជាតិ (UNTAC) ចូលមកគ្រប់គ្រងបណ្ដោះអាសន្ននៅកម្ពុជា គឺមានរយៈពេលប្រមាណត្រឹមតែមួយឆ្នាំប៉ុណ្ណោះ គឺពីក្នុងចន្លោះថ្ងៃទី២៤ មិថុនា ១៩៩២ ដល់ថ្ងៃទី៣០ មិថុនា ១៩៩៣ ជាបរិបថភាគីខ្មែរផ្សេងៗ បញ្ឈប់ការប្រយុទ្ធគ្នា និងយល់ព្រមឲ្យមានការបោះឆ្នោតជាទូទៅ។ ព្រះករុណា ព្រះបាទ **នរោត្តម សីហនុ** បានទទួលការតែងតាំងជាប្រមុខរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC)។ គួរកត់សម្គាល់ទង់ជាតិមានពណ៌ផ្ទៃមេឃ ដែលជាពណ៌របស់អង្គការសហប្រជាជាតិ និងផែនទីប្រទេសកម្ពុជា ពណ៌សព្រមទាំងសរសេរអក្សរចារិកថា "កម្ពុជា"។




ទង់ជាតិ នៃសម័យអ៊ុនតាក់ ឆ្នាំ១៩៩២-១៩៩៣

## ជ. ខ្មែរនាំគ្នាចុះផ្លូវឆ្ពោះទៅរកសន្តិភាព

ចាប់ពីឆ្នាំ ១៩៨៧ មក ដំណើរការចរចារដែលបានប្រព្រឹត្តទៅអស់រយៈពេល៥ឆ្នាំ ទើបភាគីជម្លោះខ្មែរ នាំគ្នាដើរចុះផ្លូវបង្រួបបង្រួមជាតិ តាមរយៈកិច្ចព្រមព្រៀងទីក្រុងបារីសដើម្បីបើកផ្លូវទៅរកការស្តារ និងរក្សាសន្តិភាពនៅកម្ពុជា ជាពិសេសការផ្សះផ្សារបង្រួបបង្រួមជាតិនិងការធានានូវការប្រើប្រាស់សិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋខ្មែរតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ បន្ទាប់ពីការបោះឆ្នោត ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៣ ដែលរៀបចំឡើងដោយអ៊ុនតាក់ លទ្ធផលនៃការបោះឆ្នោតគឺគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច បានទទួល ៥៨ កៅអីនៃរដ្ឋសភា (កៅអីទាំងអស់១២០ គិតជាភាគរយស្មើ៤៥,៧១%) គណបក្សប្រជាជនកម្ពុជា បានទទួល៥១កៅអី (៣៨,០២%) គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន១០កៅអី (៣,៨១%) និង គណបក្សម៉ូលីណាកា បានមួយកៅអី (១,៣៧%) ។

បើទុកជាអ្នកសង្កេតការណ៍ មិនពេញចិត្តនឹងអាជ្ញាធរបណ្ដោះអាសន្ន នៃអង្គការសហប្រជាជាតិទាំងស្រុងក្ដី ក៏អាជ្ញាធរនេះបាននាំសន្តិភាពមកឲ្យកម្ពុជាដែរ។

ប្រសិនបើយើងងាកក្រោយបន្តិច គឺចាប់ពីថ្ងៃទី០៧ មករា ១៩៧៩ តមក ប្រទេសកម្ពុជាបាននាំមកនូវព្រឹត្តិការណ៍ធំៗចំនួន២ គឺព្រឹត្តិការណ៍ទី១ ពីថ្ងៃទី៧ មករា ១៩៧៩ ដល់ថ្ងៃ២៣ តុលា ១៩៩១ គឺជាព្រឹត្តិការណ៍រំដោះប្រជារាស្ត្រកម្ពុជា ឲ្យរួចផុតពីអំពើប្រល័យពូជសាសន៍ នៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកប្រវត្តិសាស្ត្រហៅថា របបខ្មែរក្រហម និងការចាប់ផ្ដើមកសាងនូវហេដ្ឋារចនាសម្ព័ន្ធសង្គមឡើងវិញ និងព្រឹត្តិការណ៍ទី២ ថ្ងៃទី២៣ តុលា ១៩៩១ គឺជាព្រឹត្តិការណ៍នៃការរួបរួមគ្នារវាងខ្មែរ និងខ្មែរតាមរយៈកិច្ចព្រមព្រៀងទីក្រុងបារីស។ កិច្ចព្រមព្រៀងនេះមានតម្លៃជាសកល ប្រៀបបានដូចជាសម្បត្តិបេតិកភណ្ឌពិភពលោកអ៊ីចឹង ហើយដែលកើតឡើងក្រោមព្រះរាជតំរិះ សម្ដេចព្រះ **នរោត្តម សីហនុ** និងសម្ដេចតេជោ **ហ៊ុន សែន** ជាស្ថាបត្យករដ៏ឆ្នើម នៅក្នុងការចរចារ និងសម្របសម្រួលនៃភាគីខ្មែរនានា ដែលខ្មែរគំនិតគ្នារហូតសម្រេចបាននូវការឯកភាពគ្នាទាំងស្រុង។ តាមរយៈកិច្ចព្រមព្រៀងនេះ បាននាំមកនូវសមិទ្ធិផលធំៗចំនួន ៣ គឺទី១ កែប្រែពីប្រព័ន្ធឯកបក្សទៅជាប្រព័ន្ធពហុបក្ស ទី២ កែប្រែពីប្រព័ន្ធសេដ្ឋកិច្ចផែនការទៅជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី និងទី៣ បាននាំមកពីការបែកបាក់រវាងខ្មែរនិងខ្មែរ មកជាការជួបជុំជាមហាគ្រួសារខ្មែរតែមួយ ។

# ជំពូក ៣

# របបរាជានិយម និង សង្គមខ្មែរ

## ១. ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

*នៅថ្ងៃទី២៤ កញ្ញា ១៩៩៣ ជាថ្ងៃដ៏នក្ខត្តឫក្ស ថ្ងៃថ្នាំនៃការកកើតឡើងវិញនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីរបបនយោបាយកម្ពុជា ថាជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ហើយប្រទេសកម្ពុជាប្រកាន់យកនូវរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយប្រជារាស្ត្រមានសិទ្ធិអំណាចក្នុងការបោះឆ្នោតដោយផ្ទាល់ ក្នុងការជ្រើសរើសអ្នកតំណាងរាស្ត្រស្របច្បាប់តាមឆន្ទៈរបស់ខ្លួនជារៀងរាល់៥ឆ្នាំម្តង ដោយមានគណបក្សនយោបាយជាច្រើនបានចូលរួមប្រកួតប្រជែង ដែលជាបុព្វហេតុនាំឲ្យព្រះករុណាព្រះបាទ* **នរោត្តម សីហនុ** *ព្រះអង្គទ្រង់បានឡើងគ្រងរាជសម្បត្តិជាថ្មីម្តងទៀតដូចដើមឡើងវិញ ដែលអ្នកប្រវត្តិសាស្ត្រហៅថាជាករណីដ៏កម្រមួយក្នុងប្រវត្តិសាស្ត្រសកលលោក ហេតុនេះហើយបានជារដ្ឋធម្មនុញ្ញនេះគឺទង់ជាតិ-ភ្លេងជាតិ-សញ្ញាជាតិ នាំឲ្យមានលក្ខណៈដូចគ្នាព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៨ ដល់ ១៩៧០ ដែរ។*

*ក្នុងទស្សនៈនយោបាយនៅក្នុងការឡាយព្រះហស្តលេខាហាក់មានរបៀបរៀបរយ និងមានលក្ខណៈផ្ចិតផ្ចង់ គិតគូរវែងឆ្ងាយបង្កប់នូវអត្ថន័យដ៏ជ្រាលជ្រៅណាស់ គឺសម្តេចព្រះ* **នរោត្តម សីហនុ**

បានយកប៊ិចធ្វើពីផ្កាកទីនពណ៌ក្រហម ដែលជាដង្វាយរបស់លោក ***រ៉ូណាល់ រីហ្គែន*** (Ronald Reagan, 1981-1989) ប្រធានាធិបតីដ៏មានប្រជាប្រិយភាពបំផុតក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក យកមកឡាយព្រះហស្តលេខាក្នុងរដ្ឋធម្មនុញ្ញនេះ ក្នុងន័យបញ្ជាក់ថា ប្រទេសជាតិត្រូវតែប្រកាន់យកនូវរបបប្រជាធិបតេយ្យឱ្យបានពិតប្រាកដ និងត្រូវតែរក្សាឱ្យបានគង់វង្ស ឋិតថេរចីរកាលជានិច្ចនិរន្តន៍តរៀងទៅ។ បច្ចុប្បន្នប៊ិចនេះ ក៏ត្រូវបានតម្កល់ទុកក្នុងសារៈមន្ទីរសម្តេចព្រះ ***នរោត្តម សីហនុ*** នៅព្រះបរមរាជវាំង។

## ក. ទង់ជាតិ និង បូរណភាពទឹកដី

-ទង់ជាតិ ជាអត្តសញ្ញាណនៃជាតិ តំណាងឲ្យនូវដែនអធិបតេយ្យភាពជាតិ គឺតាមរយៈការបោះបង្គោលខណ្ឌសីមា សម្គាល់ដោយទង់ជាតិនៃប្រទេសជាតិនីមួយៗជាគ្រឿងសម្គាល់ ។

ការថែរក្សាការពារទង់ជាតិ ប្រៀបដូចជាការការពារបាននូវដែនអធិបតេយ្យភាពទឹកដីយ៉ាងដូច្នោះដែរ។ ដូចជាសង្គ្រាមពីថ្ងៃទី ០៤-០៧ កុម្ភៈ ២០១១ នៅបរិវេណប្រាសាទព្រះវិហារ គឺកើតឡើងពីមហិច្ឆតានៃការឈ្លានពានរបស់ថៃនៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ ជាក់ស្តែងចំពោះទង់ជាតិ នៅក្នុងវត្តកែវសិក្ខាគិរីស្វារៈ នៃប្រាសាទព្រះវិហារ ដែលស្ថិតក្នុងទឹកដីកម្ពុជា ហើយត្រូវបានប្រទេសថៃធ្វើការឈ្លានពាន ដោយប្រមាថតាមរយៈសេចក្តីថ្លែងការណ៍របស់លោក ***អាប់ភីស៊ីត វ៉េចាជីវ៉ា*** Abhisit Vejajiva នាយករដ្ឋមន្ត្រីថៃ ដោយបានទាមទារ កាលពីថ្ងៃទី៣០ មករា ២០១១ ក្នុងកម្មវិធីជៀជាក់លើប្រទេសថៃ ពីប្រទេសស្វីសមកថា ប្រទេសថៃកំពុងត្រួតពិនិត្យលើករណី

ប្រទេសកម្ពុជា លើទង់ជាតិក្នុងបរិវេណវត្តកែវសិក្ខាគិរីស្វារៈ ហើយបើរឿងនេះជារឿងពិតមែនត្រូវធ្វើការទាក់ទង ឲ្យទម្លាក់ទង់ជាតិនោះចុះ កម្ពុជាគ្មានសិទ្ធិប្រកាសអធិបតេយ្យភាពនៅក្នុងតំបន់នេះទេ។ លោកបានប្រកាសទៀតថា "ការប្រើប្រាស់កម្លាំងទ័ពជាជម្រើសចុងក្រោយរដ្ឋាភិបាលមិនខ្វាចសង្គ្រាមជាមួយកម្ពុជាទេ"។ ហើយរដ្ឋាភិបាលកំពុងទាក់ទងជាមួយកម្ពុជា ពីបញ្ហាដកទង់ជាតិចេញពីវត្តកែវសិក្ខា-គិរីស្វារៈ(២៦)។ ផ្ទុយទៅវិញ ស្ថិតក្នុងបុព្វហេតុការពារទង់ជាតិ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានថ្លែងនៅថ្ងៃទី ០៧ កុម្ភៈ ២០១១ នៅវិទ្យាស្ថានជាតិអប់រំ ក្នុងពិធីចែកសញ្ញាបត្រជូននិស្សិតថា កម្ពុជាមិនអាចដកទង់ជាតិចេញពីវត្តកែវសិក្ខាគិរីស្វារៈបានទេ បើកម្ពុជាដកទង់ជាតិចេញ គឺមានន័យ "ស្មើនឹងការដកព្រលឹងជាតិខ្មែរចេញដែរ បើយើងដកទង់ជាតិនោះចេញ គឺយើងមិនមែនជាខ្មែរនោះទេ"។

សម្តេចតេជោបានបញ្ជាក់ថាបើយើងឈានដល់ចំណុចនេះ យើងមិនចាំបាច់ធ្វើជានាយករដ្ឋមន្ត្រីកម្ពុជាទេ ហើយក៏គ្មានសិទ្ធិធ្វើជាពលរដ្ឋកម្ពុជាដែរ គឺមិនថាពលរដ្ឋសាមញ្ញនោះទេ បើអ្នកណាគិតឃើញថា ត្រូវទម្លាក់ទង់ជាតិនៅវត្តកែវសិក្ខាគិរីស្វារៈ មិនមែនជាជនជាតិកម្ពុជានោះទេ ។

ការថ្លែងរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនេះ គឺឆ្លើយតបទៅនឹងការទាមទាររបស់នាយករដ្ឋមន្ត្រីថៃ លោក **អាភីស៊ីត វេចាជីវ៉ា**

---

(២៦) សារព័ត៌មាន Bang Kok Post, INN News ថ្ងៃទី៣០ មករា ២០១១

Abhisit Vejajiva ដែលបានទាមទារឲ្យកម្ពុជាដកទង់ជាតិចេញពីវត្ត កែវសិក្ខាគិរីស្វារៈ។ នេះសឲ្យឃើញអំពីគោលការណ៍គ្រឹះនៃទង់ជាតិ ដែលសម្គាល់នូវបូរណភាពទឹកដីនៃប្រទេសនីមួយៗ ។

បើពិនិត្យអំពីប្រវត្តិនៃវត្ត យើងអាចនិយាយបានថា វត្តកែវ សិក្ខាគិរីស្វារៈ ត្រូវបានកសាងឡើងនូវឆ្នាំ១៩៩៨ ហើយក្លាយជាវត្ត មានលក្ខណៈជាប្រវត្តិសាស្ត្រមួយ ក្នុងចំណោមវត្តនានាក្នុងព្រះរាជា-ណាចក្រកម្ពុជាបញ្ជាក់អំពីបូរណភាពទឹកដី។

## ខ. អត្ថន័យនៃការគោរពទង់ជាតិ

បើពិនិត្យអត្ថន័យនៃទង់ជាតិ មានតួនាទីតំណាងឲ្យជាតិ និង ប្រាប់អំពីតម្លៃជាតិផងដែរ។ ដោយគ្រាន់តែទង់ជាតិត្រូវបានប្រែប្រួល ទៅតាមរបបនយោបាយសង្គមតែប៉ុណ្ណោះ ប៉ុន្តែនៅតែរក្សាធាតុដើម គឺ "**ជាតិ**" ។

ជាមួយគ្នានេះដែរ "**ទង់ជាតិ**" ត្រូវបានគេទទួលស្គាល់ថាជា ជាតិសាសន៍មួយបាន លុះត្រាតែជាតិសាសន៍នោះមានទឹកដីច្បាស់ លាស់។ ប៉ុន្តែប្រសិនបើពុំមានទឹកដីនោះទេ ទង់ជាតិដែលគេប្រើនោះ ពុំត្រូវបានទទួលស្គាល់ជាតំណាងជាតិ ឬ ប្រទេសណាទេ ។

ជារួម "**ទង់**" គឺតំណាងឲ្យ "**គុណ**" ដូច្នេះ ការដែលយើងនាំគ្នា គោរពទង់ជាតិ គឺជាការគោរពដឹងគុណដល់បុព្វបុរស ដែលបាន ការពារទឹកដីពីជំនាន់មួយតមកជំនាន់មួយទៀត។

ហេតុនេះ ដើម្បីបញ្ជាក់អំពីការដឹងគុណត្រូវទាមទារនូវការ ប្រតិបត្តិ ដែលមានលក្ខណៈជាការគោរពឲ្យហ្មត់ចត់បំផុត។

រួមសេចក្ដីមកចំពោះការគោរពទង់ជាតិមានលក្ខណៈបីយ៉ាងគឺៈ

ទី១. ការបង្ហូតឡើងពេលព្រឹក (ម៉ោងចូលធ្វើការ) បង្ហូតចុះវិញពេលល្ងាច (ម៉ោងចេញពីធ្វើការ)ៈ ភាគច្រើនតាមសាលារៀន ។

ទី២.ការបង្ហូតទង់ជាតិទុកជាប់ជង់ៈភាគច្រើនតាមក្រសួងមន្ទីរ និង តាមកន្លែងទីសាធារណៈសំខាន់ៗ ។

ទី៣. ការគោរពទង់ជាតិគ្មានទង់ជាតិ គឺចាក់បទភ្លេងជាតិ ឬក៏ចាក់ផ្សាយរូបភាពទង់ជាតិៈ ភាគច្រើនស្ថិតនៅតាមទីកន្លែងនៃអង្គប្រជុំនិងតាមស្ថានីយ៍វិទ្យុ-ទូរទស្សន៍ផងដែរ ព្រោះអាស្រ័យតាមទីកន្លែងជាក់ស្ដែងៗ ចំពោះការគោរពទាំងបីមានន័យដូចគ្នាៗ ហើយជាការបង្ហាញឲ្យឃើញនូវ ៖

ជនគ្រប់ៗរូប ត្រូវមានកាតព្វកិច្ចចងចាំជាតិ ឲ្យជាប់និងខ្លួនប្រៀបដូចជាប្រទេសមួយដាច់ខាត ត្រូវមានកងទ័ពការពារទឹកដីជាប្រចាំដូច្នេះដែរៗ ដោយហេតុផលយ៉ាងនេះហើយ បានជាទង់ជាតិត្រូវបានគេដោត ឬ បង្ហូតឡើងឲ្យខ្ពស់ត្រដែត ព្រោះចង់បង្ហាញពីការមើលឃើញវែងឆ្ងាយក្នុងអត្ថន័យបីយ៉ាង ទី១ សំដៅភាពជោគជ័យ ទី២ បង្ហាញឲ្យគេស្គាល់អំពីអត្តសញ្ញាណជាតិ និងទី៣ បង្ហាញពីនិមិត្តរូបនៃវីរភាពៗ

ទង់ជាតិត្រូវបានបញ្ជាក់ប្រាប់ជាការគោរពផងដែរ នៅពេលថ្នាក់ដឹកនាំប្រទេស មានគុណបំណាច់ជាតិស្លាប់ ឬ ប្រជាពលរដ្ឋមួយចំនួនណាមួយ ត្រូវបានស្លាប់ដោយធម្មជាតិ ឬឧប្បត្តិហេតុផ្សេងៗ ត្រូវបានគេបង្ហូតនៅត្រឹមពាក់កណ្ដាលជង់ ឬក៏ត្រឹម១ភាគ៣

គិតពីលើមក ដោយយោងទៅតាមការកំណត់របស់ច្បាប់។ ព្រោះជាការបង្ហាញក្នុងន័យគោរពដឹងគុណ ហើយជាសញ្ញាប្រាប់ថាប្រទេសបានបាត់បង់អ្នកមានគុណបំណាច់សម្រាប់ជាតិដូច្នោះដែរ។ ព្រមជាមួយគ្នាទង់ជាតិ ត្រូវបានផ្តល់កិត្តិយសទៅលើសាកសព គ្រាលនៅលើក្តារម្ឈូសនៅពេលជនដែលមានស្នាដៃបម្រើជាតិតែប៉ុណ្ណោះ។

ខេមរជន និងជនបរទេសទាំងឡាយ អាចលើកទង់ជាតិក្នុងពីធីបុណ្យជាតិ និងបុណ្យអន្តរជាតិបានតាមការគួរ លើកលែងតែបុណ្យឯកជន ឬសាធារណជនក្រៅផ្លូវការ ព្រមទាំងហាមផ្តាច់មិនត្រូវយកទង់ជាតិទៅគ្របលើក្តារម្ឈូស។ បើយោងទៅលើសម័យសង្គមរាស្ត្រនិយម គឺលើកលែងតែមានអនុញ្ញាតជាផ្លូវការ (ព្រះរាជក្រមលេខ២៤៤ន.ស.ចុះថ្ងៃទី១៣ មករា ១៩៥៩) បើពុំនោះទេនឹងត្រូវមានទោសតាមបទបញ្ញត្តនៃមាត្រា៣នៃព្រះរាជក្រមលេខ៤៧៣ន.ស. ចុះថ្ងៃទី២៩ តុលា ១៩៤៨។

ទង់ជាតិ ត្រូវបានគេគោរពផងដែរ នៅពេលមេដឹកនាំប្រទេសជាមិត្តណាម្នាក់ស្លាប់ គឺអាស្រ័យលើមេដឹកនាំសាមីប្រទេសយល់ថាជាមហាមិត្តជិតដិត និងមានទំនាក់ទំនងដ៏មហាធំធេងរវាងគ្នាទៅវិញទៅមក។ ដូចជាព្រឹត្តិការណ៍នៃការយាងចូលទីវង្គត់របស់ព្រះករុណាព្រះមហាវិរក្សត្រ **នរោត្តម សីហនុ** នៅប្រទេសចិននាថ្ងៃទី១៥ តុលា ឆ្នាំ២០១២ ប្រទេសចិនបានបង្ហូតទំលាក់ទង់ជាតិត្រឹម១ភាគ៣ផងដែរ ជាការសម្តែងនៃការកាន់ទុក្ខ។



ទង់ជាតិ ប្រទេសចិនត្រូវបានបង្ហូតត្រឹម១ភាគ៣នៅទីលាន
ធៀនអានមែនដើម្បីចូលរួមកាន់ព្រះមរណៈទុក្ខ
ព្រះមហាវីរក្សត្រខ្មែរសម្តេចព្រះ នរោត្តម សីហនុ

*ជាតិដែលមានអារ្យធម៌ មានសីលធម៌សូម្បីជាតិតូចក្តី មិនសូវមានឥទ្ធិពលក្តី គឺរមែងមានទង់ជាតិជាគ្រឿងសម្គាល់ជាតិរបស់ខ្លួន កាលបើដូច្នោះ ទង់ជាតិក៏ទៅជារបស់សក្តិសិទ្ធិមួយយ៉ាង ក្នុងបទរដ្ឋនិយមថា ត្រូវស្គាល់ និងស្រលាញ់ជាតិ ប្រជារាស្ត្រអ្នកនៅក្រោមម្លប់ទង់ជាតិនោះ ត្រូវសម្តែងសេចក្តីគោរព តាមសមគួរដល់ឋានៈរបស់ខ្លួន គឺជាទាហានត្រូវគោរពបែបទាហាន រាស្ត្រសាមញ្ញ ត្រូវគោរពតាមបែបរាស្ត្រសាមញ្ញ មិនត្រូវបោះបង់ចោលផ្តេសផ្តាស មិនត្រូវដើរគន្លង ដើរជាន់ញីញក់ មិនត្រូវយកទៅជូត ឬខ្ចប់អ្វីផ្សេងៗឡើយ។ ការប្រើចាស់ ហើយត្រូវរំលាយចោលដោយដុតភ្លើងចោលជាដើម មិនត្រូវចោលរាត់រាយក្នុងទីនីមួយៗឡើយ។ ការដែលពោលមកនេះ ឈ្មោះថា គោរពទង់ជាតិ អ្នកដែលមិនគោរពទង់ជាតិ ទុកជាមនុស្ស*

មិនស្រឡាញ់ជាតិ អាការៈដែលធ្វើឲ្យឃើញជាក់ស្តែងនៅទីមុខប្រជុំជន ត្រូវមានទោសក្នុងស្ថានណាមួយៗ ដូចជាករណីទំនាស់នៃការដុតទង់ជាតិ រវាងប្រទេសជប៉ុន និងប្រទេសរុស្ស៊ី ស្តីអំពីដីជាប់វិវាទ គឺ "កោះបួននៃកោះគួរីលខាងត្បូង ដែលភាគីម្ខាងៗចាត់ទុកថាជារបស់ខ្លួន ហើយត្រូវបានពួកជាតិនិយមជប៉ុន ដុតទង់ជាតិរុស្ស៊ី ដើម្បីជាការសម្តែងមតិទាមទារកោះនោះមកវិញ ហើយត្រូវបានប្រទេសរុស្ស៊ី ចេញសេចក្តីថ្លែងការណ៍តវ៉ាទៅអ្នកការទូតជប៉ុនថាពុំព្រមចង់ក្រង ជាសំណុំរឿងព្រហ្មទណ្ឌទល់នឹងពួកជាតិនិយមជប៉ុនជ្រុលមួយក្រុមដែលកាលពីថ្ងៃទី០៧ កុម្ភៈ ២០១១ បានប្រមាថលើកេតនភណ្ឌរបស់រុស្ស៊ី ដោយបានប្រញាយគ្នាហែកទង់ជាតិរុស្ស៊ីទាំងចង់កំហឹង ហើយដុតចោលនៅមុខស្ថានទូតរុស្ស៊ីក្នុងក្រុងតូក្យូៗ រុស្ស៊ីទាមទារឲ្យធ្វើការស៊ើបអង្កេតឡើងវិញ ដើម្បីកំណត់ទោសពិរុទ្ធ និងដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តទាំងនេះៗ ទង់ជាតិក៏ជាតំណាងឲ្យប្រទេសមួយ នៅក្នុងប្រទេសមួយទៀតផងដែរ ដើម្បីបញ្ជាក់ពីការចូលរួមរំលែកទុក្ខសោកសៅជាមួយគ្នា ដូចជាព្រឹត្តិការណ៍ចូលរួមរំលែកទុក្ខដល់ប្រទេសជប៉ុន ដែលរងគ្រោះដោយបាតុភូតធម្មជាតិដ៏ធ្ងន់ធ្ងរ គឺគ្រោះរញ្ជួយដី និងរលកយក្សស៊ូណាមិ កាលថ្ងៃទី១១ មីនា ២០១១ បានបណ្តាលឲ្យប្រជារាស្ត្រជប៉ុនជាង១០,០០០នាក់បាត់បង់ជីវិត គ្រោះមហន្តរាយនៃធម្មជាតិនេះ បានញ៉ាំងឲ្យទឹកចិត្តប្រជារាស្ត្រខ្មែរ មានការតក់ស្លុត និងសម្តែងនូវសមានចិត្តចូលរួមមរណទុក្ខពីគ្រប់មជ្ឈដ្ឋាន ជាមួយនឹងប្រជាជាតិជប៉ុនៗ ជាមួយគ្នានោះ តាមរយៈសារព័ត៌មានជប៉ុន The Japan Time Ltd បានចេញផ្សាយកាលពីថ្ងៃទី៣០ មីនា ២០១១ បានបង្ហាញពីស្ថានទូតមួយ

ចំនួននៅក្នុងប្រទេសជប៉ុន ដែលបានឆ្លើយតបទៅនឹងភាពរន្ធត់ញាប់ញ័រ និងបានបន់ស្រន់ឲ្យប្រជារាស្ត្រជប៉ុន រួចចាកផុតពីទុក្ខដ៏លំបាកនេះ ហើយទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានប្រទេសជប៉ុនរំលេចជាមួយនឹងទង់ជាតិប្រទេសដទៃទៀតនៅក្នុងប្រទេសជប៉ុន ដើម្បីចារិកជាការបញ្ជាក់អំពីការចូលរួមក្នុងគ្រាមានទុក្ខលំបាកជាមួយប្រជារាស្ត្រជប៉ុន។

គួរកត់សម្គាល់ថា ទង់ជាតិដែលត្រូវយកមកគោរព គឺត្រូវមានក្បួនខ្នាតត្រឹមត្រូវហ្មត់ចត់ណាស់ ពីព្រោះជាគ្រឿងសម្គាល់ដ៏ឧត្តុង្គឧត្តមចំពោះជាតិ អ៊ីចឹងហើយទើបទង់ជាតិត្រូវបានគេកំណត់ក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស គឺគេមិនត្រូវយកទង់ជាតិមកកែច្នៃ ឬធ្វើអ្វីឲ្យខុសអំពីទម្រង់ដើម ដែលកំណត់នៅក្នុងរដ្ឋធម្មនុញ្ញបានឡើយ។ ដូច្នេះ អ្វីជាការចាប់អារម្មណ៍នោះគឺថា ទង់ជាតិដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ដែលសព្វថ្ងៃនេះបាននឹងកំពុងបោះពុម្ពផ្សាយនៅតាមស្ថាប័នផ្សេងៗឃើញថា មានចំនួនកាន់តែច្រើនឡើងៗ ព្រោះយោងទៅតាមតម្រូវការនៃការប្រើប្រាស់ តែអ្វីជាការគួរឲ្យកត់សម្គាល់នោះនៅត្រង់ថា ចំពោះការបោះពុម្ពផ្សាយទង់ជាតិសង្កេតឃើញថា រូបប្រាសាទអង្គរវត្ត ហាក់ដូចជាចំណុចខ្លះមានលក្ខណៈមិនទំនងដូចគ្នាសោះ ដោយពេលខ្លះរូបប្រាសាទអត់កាំជណ្ដើរ ហើយពេលខ្លះទៀតតួប្រាសាទបែរជាមានឆ្នូតក្រហម។ ដើម្បីទុកជាទុនជូនជនរួមជាតិពិចារណា ខ្ញុំសូមចុះផ្សាយនូវទង់ជាតិ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បោះពុម្ពផ្សាយដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា និង ទង់

*ជាតិក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ពផ្សាយដោយក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី* (Cambodia National Council of Women) *និងការបោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំកម្ពុជា ខែវិច្ឆិកា ២០០៨។*



ទង់ជាតិបោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋានរដ្ឋសភា



ទង់ជាតិបោះពុម្ពផ្សាយដោយ
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
(Cambodia National Council of
Women)



បោះពុម្ពផ្សាយដោយការិយា-
ល័យឧត្តមស្នងការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា
ខែវិច្ឆិកា ២០០៨

## ២. ភ្លេងជាតិ

ភ្លេងជាតិ-បទនគររាជ ត្រូវបានប្រកាសឲ្យប្រើស្របតាមរដ្ឋ-ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

កាលពីបុរាណកាល ខ្មែរបានឲ្យឈ្មោះបទចម្រៀងចាប៉ីមួយបែបថា: "បទនគររាជ"[២៧] ប្រែថា "បទស្តេចអង្គរ" ជាសម្មតិនាមប្រហែលគ្នា និងឲ្យឈ្មោះផ្លូវសម័យបច្ចុប្បន្ន ដោយសម្មតិកម្មតាមស្ថានភាពប្រទេសកម្ពុជាក្នុងសម័យអង្គរ។ ចាប៉ីជាគ្រឿងភ្លេងបុរាណមួយបែប ក្នុងចំណោមឧបករណ៍នៃវង់ភ្លេងអារក្ស។ ជាទូទៅចាប៉ីនេះមានខ្សែ ២ឬ៤ មានស្នូកស្មើរមូលស្មើរជ្រុងហើយមានដងវែងទន្ទាំ។ ក្រៅពីលេងក្នុងវង់ភ្លេងអារក្ស និងភ្លេងការបុរាណចាប៉ីក៏និយមសម្តែងទោលសម្រាប់ជូនច្រៀងជាកាព្យ ឬ កម្រងកែវ ឬក៏ជាការច្រៀងឆ្លងឆ្លើយគ្នារវាងដៃគូពីរនាក់។សូមបញ្ជាក់ថាសិល្បៈច្រៀងចាប៉ីជាប្រភេទសិល្បៈស្ញប់ស្ញៀម ដ៏ខ្ពង់ខ្ពស់ ជាសិល្បៈប្រភេទអប់រំហើយស៊ីជម្រៅខ្លាំងណាស់។ គេដេញច្រៀងរឿង ឬច្រៀងចោទឆ្លើយតាមសំណួរវោហារចង់ដឹងឈ្នះ-ចាញ់តាមប្រាជ្ញារៀងៗខ្លួន និងល្បិចដោះស្រាយពាក្យសំដី។ ចម្រៀងចាប៉ីច្រៀងលេងប្រើក្នុងពិធីបុណ្យកែកំសាន្តហើយច្រៀងលេងបទនគររាជ, ផាត់ជាយ, ផាត់ជាយក្លាយ ...។

ក្រោយមក បទនគររាជត្រូវបានបង្កើតធ្វើជាបទភ្លេងជាតិខ្មែរនៅសម័យអាណានិគមបារាំងសែស គឺក្នុងរជ្ជកាលព្រះករុណាព្រះបាទ

---

[២៧] ព័ត៌មានពីសម្តេចព្រះមហាសុមេធាធិបតីព្រះនាម ជួន ណាត សង្ឃនាយកគណៈមហានិកាយ បោះពុម្ពដោយ ចាប ពិន ឆ្នាំ ១៩៥៩

សម្តេចព្រះស៊ីសុវត្ថិមុនីវង្ស។ ដូចពោលខាងដើមរួចហើយអ៊ីចឹង មុនសម័យនេះខ្មែរមានបទភ្លេងជាតិអ្វីខ្លះទេ។

**ភ្លេងជាតិ** បើនិយាយក្នុងន័យទូទៅ ភ្លេងជាគូនឹងចម្រៀងហៅថាតន្ត្រីជាសិល្បៈនៃអារ្យធម៌ ឬ ជាគ្រឹះស្ថានដ៏សំខាន់ប្រចាំសញ្ជាតិ ហើយជាជំហររបស់ប្រជាជាតិនីមួយៗ អាចញាំងឲ្យជាតិគង់វង្សដូចភាសា និង អក្សរដែលអាចធ្វើឲ្យជាតិឋិតថេរចីរកាលនៅក្នុងលោក។ បានជាភ្លេងកំណត់ពាក្យ "**ជាតិ**" ព្រោះភាសាក្តី អក្សរក្តី ចម្រៀងក្តី ភ្លេងក្តីរបស់ជាតិណា ជាគ្រឿងសម្គាល់ដ៏សំខាន់ សម្រាប់ជាតិនោះ គឺគេគ្រាន់តែឃើញអក្សរ ឬភាសាចម្រៀង ឬភ្លេងរបស់ជាតិណាគេអាចស្គាល់បានភ្លាមថា អក្សរ-ភាសា-ចម្រៀង-ភ្លេង របស់ជាតិនោះបានជាប្រាកដ មិនបាច់ឃើញរូបជាម្ចាស់ប្រទេសឡើយ។

**ភ្លេងជាតិ** កើតចេញពីចម្រៀងនៃជាតិនីមួយៗ គ្រាន់តែពាក្យភ្លេងជាតិ វាមានន័យភ្លេងនៃការគោរពដឹងគុណ ប៉ុន្តែវាពុំមានន័យដាច់ដោយឡែកផ្សេងពីចម្រៀងដទៃផ្សេងៗទេ គឺចម្រៀងផ្សេងៗទៀតក៏មានន័យថា ជាសិល្បៈបម្រើឲ្យជាតិជាអារ្យធម៌នៃជាតិនីមួយៗដែរ។ ដូចជាចម្រៀងខ្មែរ ជាអារ្យធម៌ ជាគ្រឹះស្ថានសំខាន់មួយផ្នែករបស់ខ្មែរសម្រាប់ឧបត្ថមជាតិខ្មែរ ឲ្យចាក់ឫសជាប់ស្ថិតស្ថេរប្រាកដប្រជានៅក្នុងលោក បើចម្រៀងខ្មែរមាននៅក្នុងលោកដរាបណា ជាតិខ្មែរក៏មាននៅក្នុងលោកដ៏រាបនោះ បើចម្រៀងខ្មែររលាយសូន្យបាត់ទៅវេលាណា ខ្មែរក៏បាត់ទៅវេលានោះជាប្រាកដ។

### ក. បទនគររាជ

នគររាជ ជាភ្លេងជាតិរបស់ខ្មែរ "**ឈរសម្ងឹងគោរព**" គឺជាអនុស្សារណៈដល់ខេត្តចាស់ មួយរបស់កម្ពុជាក្នុងសម័យបុរាណព្រេងនាយ ដែលបានឃ្លាតចេញពីប្រទេសកម្ពុជា ដោយខ្មែរបែកបាក់សាមគ្គី(២៨)។ បើយោងតាមលោក ចាប ពិន(២៩) បានអះអាងថា សម្រាប់ឲ្យជនជាតិខ្មែរ ត្រូវបន្ទឺសូរស័ព្ទធ្វើគារវកិច្ចជាផ្លូវការរំឭកដល់អតីតភាពរបស់កម្ពុជា ដែលជាប្រទេសមានឥស្សរភាពដ៏រុងរឿងនៅអាស៊ីអាគ្នេយ៍ ក្នុងសម័យអង្គរតាំងពីបរមបុរាណមក ដើម្បីដាស់សតិសម្បជញ្ញៈពលរដ្ឋខ្មែរឲ្យខំសាងជាតិឲ្យមានឥស្សរភាព ព្រមទាំងត្រៃសរណដ្ឋានផង ឲ្យគង់វង្សស្ថិតស្ថេរបើរកាលតទៅ រហូតដល់កប្បវសាន្ត ។

បទនគររាជ ភ្លេងជាតិនេះកើតដំបូងក្នុងរជ្ជកាល ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស រវាងគ.ស១៩៣៩ ដោយព្រះករុណាព្រះបាទនរោត្តមសុរាម្រឹត(៣០) ត្រូវជាព្រះបិតាព្រះបាទសម្តេចព្រះនរោត្តមសីហនុ កាលទ្រង់នៅត្រួតត្រាការរាជការក្នុងព្រះបរមរាជវាំងនៅឡើយ ទ្រង់បង្កើតជាមួយលោកហ្វ៊ីគីល ជាជាតិបារាំងសែស អ្នកបង្ហាត់ភ្លេងព្រះបរមរាជវាំង តែសម័យនោះរកពាក្យកាព្យត្រឹមត្រូវនិងបទនេះពុំទាន់បាន ។

---

(២៨) សម្តេចសង្ឃ ជួន ណាត, វចនានុក្រមខ្មែរ, គ.ស ១៩៦៧, ភ្នំពេញ

(២៩) ចាប ពិន, ប្រវត្តិភ្លេងនគររាជ, ឆ្នាំ ១៩៥៩, ភ្នំពេញ

(៣០) សម្តេចព្រះសុមេធាធិបតីព្រះនាម ជួន ណាត ជោតញ្ញាណោ បោះពុម្ពផ្សាយ ដោយ ចាប ពិន ឆ្នាំ ១៩៥៩

តមកដល់គ.ស១៩៤១[៣១] ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដមសីហនុវរ្ម័ន កាលនោះអតីតព្រះមហាក្សត្រប្រទេសកម្ពុជា ដែលជាសម្ដេចព្រះឧបយុវរាជក្នុងសម័យនោះ និង ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដមសុរាម្រិត កាលទ្រង់នៅជាសម្ដេចព្រះបរមរាជបិតាព្រះរាជានុសិទ្ធិនៅឡើយ ព្រះអង្គទ្រង់ឈ្វេងយល់ថា បទនគររាជភ្លេងជាតិ ជាបទសម្រាប់ជាតិទាំងមូល ហើយទ្រង់សព្វព្រះរាជហឫទ័យឲ្យមន្ត្រី អ្នករាជការ និង ប្រជាពលរដ្ឋទាំងអស់ដែលជួបជុំក្នុងឱកាសពិធីបុណ្យជាផ្លូវការ បន្ទឺបទនគររាជគ្រប់ៗគ្នា។ ទ្រង់និមន្តសម្ដេចព្រះមហាសុមេធាធិបតី ជួន ណាត សង្ឃនាយក កាលនៅក្នុង សមណសក្ដិជាព្រះពុទ្ធឃោសនាចារ្យនៅឡើយ ឲ្យនិពន្ធពាក្យកាព្យបទភ្លេងជាតិនេះឡើងសម្រាប់ធ្វើគារវកិច្ចជាផ្លូវការ ហៅថា "បទនគររាជ" ព្រោះបំផ្លែងមកពីបទនគររាជខ្មែរដែលមានមកពីក្នុងសម័យព្រេងនាយ។

## ខ. អត្ថន័យនៃបទនគររាជ

ដូចបានជម្រាបជូនខ្លះមកហើយថា សម្រាប់ទុកជាការចង ចាំដឹងគុណគោរព ដែលបុព្វបុរសខ្មែរពីជំនាន់មួយទៅជំនាន់មួយ បានតស៊ូការពារកសាងជាតិ ហើយតម្រូវឲ្យជនជាតិខ្មែរគ្រប់រូបត្រូវអនុវត្តនូវភារកិច្ចដ៏ប្រពៃនេះ ជាបន្តបន្ទាប់ដើម្បីរក្សាជាតិទុកឲ្យជនរួមជាតិខ្មែរតពីជំនាន់មួយទៅជំនាន់ក្រោយៗទៀតជារៀងរហូត។ ការយកបទនគររាជធ្វើជាបទភ្លេងជាតិ គឺដើម្បីរំឭកដល់សេចក្ដីរុងរឿង របស់

(៣១) ថ្ងៃ១២ រោច ខែអាសាឍ ឆ្នាំម្សាញ់ ត្រីស័ក ព.ស២៤៨៤ (២០-០៧-៤១)

ព្រះមហាក្សត្រខ្មែរសម័យអង្គរ ដែលជាប្រទេសមានព្រះមហាក្សត្រទ្រង់មានតេជានុភាពមហិមា មានការរចនាប្រាសាទថ្មល្អរុងរឿង។ បទនគររាជនេះ ជាបទសម្រាប់ច្រៀងរឿង ច្រៀងរាយការណ៍ផ្សេងៗ តាំងពីព្រេងនាយដរាបដល់បច្ចុប្បន្ន។

សម័យបុរាណប្រទេសកម្ពុជា បានឲ្យឈ្មោះបទចម្រៀង ចាប៉ី១ បែបថា "**បទនគររាជ**" ប្រែថា "**បទស្តេចអង្គរ**" បទនេះពិរោះពិសាណាស់ តែក្នុងឃ្លានីមួយៗ មិនមានកំណត់ចំនួនពាក្យ គ្រាន់តែមានចួនៗទទួលគ្នានៅចុងឃ្លាជាសម្គាល់ប៉ុណ្ណោះ។

ដោយបទនគររាជ មានអត្ថន័យ ដ៏ជ្រាលជ្រៅអ៊ីចឹងហើយ បានជារាជរដ្ឋាភិបាល សម័យសង្គមរាស្ត្រនិយមក្នុងឆ្នាំ ១៩៥៩ បានកំណត់បទនេះ ជាបទភ្លេងជាតិ ដើម្បីឲ្យប្រជារាស្ត្រទាំងមូលធ្វើគារវកិច្ច ដូចមានចែងក្នុងសារាចរខាងក្រោម ៖

**ព្រះរាជាណាចក្រកម្ពុជា**

*ទីស្ដីការនាយករដ្ឋមន្ត្រី*

*លេខ: ៣៥៨ ន.រ.ម.ល.ផ*

**សារាចរ**

*ភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៥៩*

*ទេសរដ្ឋមន្ត្រីប្រតិភូប្រចាំទីស្ដីការនាយករដ្ឋមន្ត្រី ទទួលភារៈខាងក្រសួងមហាផ្ទៃជម្រាបសហជីវិន សមាជិករាជរដ្ឋាភិបាល*

*- " - អនុរដ្ឋលេខាធិការ*

*- " - - -*

*- " - - -*

*- " - - -*

**កម្មវត្ថុ៖** *ការច្រៀងបទនគររាជ។*

*ក្នុងឱកាសពិធីបុណ្យជាផ្លូវការ ឬក្នុងឱកាសរៀបចំទទួលព្រះរាជដំណើរទស្សនការនៃសម្ដេចសហជីវិនគណៈកម្មការបុណ្យ ឬគណៈកម្មការរៀបចំបដិសណ្ឋារកិច្ចតែងចាត់ឲ្យយុវជនរាជសង្គមនិយមមួយក្រុម ច្រៀងបទថ្វាយជាកិត្តិយសចំពោះសម្ដេចព្រះបិតាឯករាជ្យជាតិ។ ដោយទ្រង់បានឈ្វេងយល់ថា បទនគររាជជាបទសម្រាប់ជាតិទាំងមូលសម្ដេចសហជីវិន ទ្រង់សព្វព្រះហឫទ័យតម្រូវឲ្យមន្ត្រីរាជការ និង ប្រជាពលរដ្ឋទាំងអស់ ដែលមកជួបជុំក្នុងឱកាសដូចមានរៀបរាប់ខាងលើនេះ ច្រៀងបទនគររាជទាំងអស់គ្នា។*

អាស្រ័យហេតុនេះ សូមសហជីវិនចាត់វិធានការឲ្យបានស្រប តាមព្រះរាជបំណងខាងលើតទៅ ។

ហត្ថលេខា

**ជា ជិនកុក**

នៅក្នុងរជ្ជកាលព្រះបាទនរោត្តម ព្រះសីហនុ ប្រទេសកម្ពុជា បានបំផ្លែង "បទនគររាជ" នោះ មកធ្វើជាបទភ្លេងជាតិឡើង ហើយធ្វើពាក្យកាព្យតម្រូវនឹងបទនោះ បំប្រួញឲ្យមានកំណត់ក្នុងបទនីមួយៗ ០៥ ឃ្លា មាន ៥៣ ពាក្យ ៖

ឃ្លាទី ១ មាន ៩ ពាក្យ

ឃ្លាទី ២ មាន ១១ ពាក្យ

ឃ្លាទី ៣ មាន ១២ ពាក្យ

ឃ្លាទី ៤ មាន ១៣ ពាក្យ

ឃ្លាទី ៥ មាន ៨ ពាក្យ

រួមជា ៥៣ ពាក្យ ក្នុង ១ បទ ។

*ពាក្យកាព្យ បទនគររាជ នេះ មាន ៣ បទ ៖*

បទទី ១ "សរសើរព្រះបារមីព្រះមហាក្សត្រខ្មែរ"

សូមពួកទេព្ដា　　　រក្សា មហាក្សត្រយើង
ឲ្យ បានរុងរឿង　　　ដោយជ័យមង្គលសិរី [៣២] សួស្ដី
យើងខ្ញុំព្រះអង្គ　　　សូមជ្រកក្រោមម្លប់ព្រះបារ-មី
នៃព្រះនរបតី　　　វង្សក្សត្រាដែលសាងប្រា-សាទថ្ម
គ្រប់គ្រងដែនខ្មែរ　　　បុរាណថ្កើងថ្កាន។

(៣២) *អានដកឃ្លាពាក្យដើម "ស្រី" មានន័យពីរយ៉ាង ទី១: "ស្រី" សម្គាល់ភេទស្រី, មនុស្សស្រី មកពីភាសាសំស្ក្រឹត "ស្ត្រី"។ទី២: ឥតមានសំដៅលើភេទអ្វីសោះឡើយ ពាក្យ "ស្រី" ឬ "ស្រី" នេះគឺសំដៅទៅលើអ្វីដែលប្រសើរ, ដែលមានតម្លៃដែលជាមង្គល ដូចជាឈ្មោះប្រាសាទព្រះវិហារ "ស្រីសិខរេស្វរ:..."។ ប៉ុន្តែគួរឲ្យកត់សម្គាល់ព្រះនាមព្រះរាជាខ្មែរ "ស្រីសុរវត្ថិ" តែដោយសៀមអានពាក្យនេះមិនច្បាស់អានថា "ស៊ីសុរវត្ថិ" ស្រុក "ស្រីសោភណ្ឌ" សៀមអានថា "ស៊ីសូផុន" ទៅវិញខ្មែរយើងក៏យកសម្លេងសៀមមកប្រើមកទល់បច្ចុប្បន្នគួរឲ្យពិចារណា...។ ហេតុនេះហើយ "ស្រីសួស្ដី" ក្លាយទៅជា "សិរីសួស្ដី" ជាពាក្យ "បាលី"។ អ្វីដែលបានពោលមកនេះ ពុំមែនមានន័យថាជាការខុសទេតែបើយកពាក្យក្នុងចម្រៀងនគររាជដែលជាបទភ្លេងជាតិទៅកែហាក់ដូចជាពុំមែនជាការសមគួរ"...ឲ្យបានរុងរឿង ដោយជ័យមង្គល ស្រីសួស្ដី..."។*

បទទី ២ "សរសើរការរចនាប្រាសាទខ្មែរបុរាណ"

ប្រាសាទសិលា[៣៣] កំបាំងកណ្ដាលព្រៃ
គួរឲ្យស្រម័យ នឹកដល់យសសក្ដិ៍ មហា-នគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អរឹងប៉ឹងជំ-ហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ។

បទទី ៣ "សរសើរតម្លៃកាន់ព្រះពុទ្ធសាសនា"

គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែប-ដូន-តា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ។

*ដើម្បីអោយអ្នកសិក្សា ភាសាបរទេសស្វែងយល់អំពី បទនគរ-រាជ ភ្លេងជាតិ ខ្ញុំសូមចុះផ្សាយជាភាសាបារាំងសែស ដូចខាងក្រោមៈ*

---

(៣៣) *អានថា សិ-ល៉ា កុំថា សី-ល៉ា*

**L'HYMNE NATIONAL KHMER**
**"NOKOREACH"**

**1er COUPLET**

ELOGES A LA GRANDEUR DE ROI KHMER
Que le ciel protège notre Roi
Et lui dispense le bonheur et la gloire
Ou'il règne sur nos cœurs et sur nos destinées
Celui qui, héritier des souverains bâtisseurs,
Gouverne le fier et vieux Royaume.

**2e COUPLET**

ELOGES AUX TEMPLES D'ANGKOR
Les temples dorment dans la forêt
Rappelant la grandeur du Moha Nokor
Comme le roe la race khmère est éternelle
Ayons confiance dans le sort du Campuchéa
L'Empire qui défie les années.

**3e COUPLET**

ELOGES A LA FOI BOUDDHIQUE
Les chants montent dans les pagodes
A la gloire de la Sainte foi Bouddhique
Soyons fidèles aux croyances de nos pères
Ainsi le ciel prodiguera-t-il tous ses bienfaits
Au vieux pays khmer, le Moha Nokor.

សូមស្រីសួស្តីកើតមានដល់លោកអ្នកដែលបន្ទឺសូរស័ព្ទបទនគររាជ ភ្លេងជាតិ !

គួរកត់សម្គាល់ថា ពាក្យកាព្យបទនគររាជ ៣បទ ដែលជាបទភ្លេងជាតិនេះ ចំពោះការលើកយកមកច្រៀងគោរពទង់ជាតិជាផ្លូវការ មិនត្រូវបានគេកំណត់ថាចាំបាច់ត្រូវតែច្រៀងឲ្យចប់នូវពាក្យ

កាព្យទាំងបីបទនោះទេ ពេលខ្លះគឺច្រៀងតែបទទី១ (សរសើរព្រះបារមីព្រះមហាក្សត្រខ្មែរ...) ចំណែកឯបទទី២-៣ ពុំត្រូវបានគេលើកយកមកច្រៀងក៏បាន។ បញ្ហានេះយើងបានស្រាវជ្រាវ និងសាកសួរព្រឹទ្ធាចារ្យចាស់ទុំជាច្រើន ប៉ុន្តែពុំមាននរណាម្នាក់អះអាងបានទេ។ អ្វីដែលគេអាចអះអាងបានបញ្ហានេះ ប្រហែលជាយោងទៅលើពេលវេលាជាក់ស្តែងច្រើនជាង។ តែក៏គ្មានឯកសារណាបញ្ជាក់ច្បាស់លាស់ឡើយ ព្រោះជាទម្លាប់មួយដែលគេឃើញតៗគ្នាតែប៉ុណ្ណោះ។ តែពេលខ្លះក៏ត្រូវបានលើកយកមកច្រៀងចប់ទាំង៣បទនេះតែម្តង។

តែអ្វីគួរឲ្យកត់សម្គាល់នោះគឺ បទនគររាជ-ភ្លេងជាតិ នេះត្រូវបានគេច្រៀងហើយថតថ្មីឡើងវិញនៅអំឡុងឆ្នាំ១៩៩៣ ចំណែកឯបទចម្រៀងបានថតសម័យសង្គមរាស្ត្រនិយម គេកម្រឃើញយកមកចាក់ផ្សាយដើម្បីគោរពទង់ជាតិណាស់ តែបញ្ហានេះត្រូវបានគេអះអាងថា អាចមកអំពីមូលហេតុចម្រៀងថតសម័យនោះ កាសែតវាចាស់ពេកពិបាកស្តាប់។ តែការថតនេះនៅរក្សាខ្លឹមសារដើមទាំងស្រុង។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះក៏ឃើញមាននៅតាមបណ្តាប្រទេសមួយចំនួនដូចគ្នានឹងកម្ពុជាដែរ ដូចជាប្រទេសប៉ូឡូញជាដើម គឺបទគោរពទង់ជាតិមានឈ្មោះថា DRABROWSKI MAZUREK ក៏មាន ៣បទ ដូចខ្មែរដែរ តែគេលើកយកមកច្រៀងតែបទទី១ ចំណែកឯបទទី២-៣ ជួនកាលច្រៀង ជួនកាលក៏អត់ទៅមិនថ្វីទេ ព្រោះយោងតាមពេលវេលា[៣២] ។

---

(៣២) ប្រសាសន៍លោកសាស្ត្រាចារ្យ ប៉ែន សំអុល ព្រឹទ្ធបុរសរងមហាវិទ្យាល័យតន្ត្រី

បើពិនិត្យប្រកពឯកសារដើមនៃបទនគររាជគឺជាទំនុកសរសើរព្រះបារមី ហើយសម្រាប់បារាំងលេងសម្រាប់ថ្វាយជាបទហ្លួង សម្តេចចៅហ្វាវាំង ជួន ជាអ្នកតែងឡើងនៅឆ្នាំ១៩៣៣ ដើម្បីរំឭកទៅដល់ភាពរុងរឿងនៃអតីតកាល និងទុកជាការចងចាំនៃប្រវត្តិសាស្ត្រខ្មែរ ដើម្បីជាការជូនជ្រាប ខ្ញុំនិងចុះផ្សាយនូវទំនុកដើមនៃបទនគររាជនេះដូចខាងក្រោម:

ទំនុកសរសើរព្រះបារមី

បទភ្លេងនគររាជ សម្រាប់ភ្លេងបារាំងលេង ទុកជាបទហ្លួង

សម្តេចចៅហ្វាវាំងតែង

១-សូមព្រះសម្ភារ បារមីមេឃា ថ្វាយព្រះករុណា អំម្ចាស់ផែនដី
ប្រសើរថ្លៃថ្លា ក្រុងកម្ពុជា មហាបុរី ។

២-សូមបំរើនសុខ ព្រះអង្គឥតទុក្ខ ព្រះជន្មវែងក្រៃ មួយរយអង្គឆ្នាំ
ទ្រង់រាជប្រពៃ បរមសុខសៃ លើរាស្ត្ររាជា ។

៣-សម្បត្តិសំបូណ៌ ពាសពេញនគរ កបដោយសុខា សិរីសួស្តី
វិសេសអស្ចារ្យ ដោយព្រះទ័យា វិសុទ្ធប្រពៃ ។

៤-ព្រះរាជវង្សា និងអស់សេនា សព្វមុខមន្ត្រី បណ្តាជនផង
សុចរិតបៃតី ឆ្លងព្រះបារមី អំម្ចាស់ជីវិត ។

៥-សោយរាជជំណា ពីមហានគរ ប្រាសាទនៅមាន សុទ្ធសឹង
សិលា ទុកជាប្រធាន គ្មានអ្វីផ្ទឹមបាន រុងរឿងពីដើម ។

៦-អស់យើងខេមរា ចូរខំឧស្សាហ៍ ប្រយោជន៍ឲ្យបាន
ល្បីកិត្តិយស ខ្ពង់ខ្ពស់ថ្កើងថ្កាន តាមដោយលំអាន
ព្រះពុទ្ធសាសនា ។

៧-គួរយើងគិតគន់ រំលឹកព្រះគុណ មហាក្សាបាល ក្រុងបាំង
សែស ឫទ្ធីមាតា សប្បុរសា តរៀងទៅហោង ។

ក្រុងភ្នំពេញថ្ងៃ ៣ ᧿ ៧ ឆ្នាំរកាបញ្ចស័ក្ស
ព្រះពុទ្ធសក្ករាជ ២៤៧៦ ត្រូវនឹងថ្ងៃ ១៣ យូវាំង ១៩៣៣

សម្តេចចៅហ្វាវាំង

ជួន

*ទម្រង់បទនគររាជនេះខ្ញុំយល់ថា សម្តេចសង្ឃ ជួន ណាត យកមកកែសម្រួលជាបទភ្លេងជាតិ-នគររាជ បើរៀបរាប់នូវពាក្យកាព្យដើមដែលបានកែសម្រួលរួមមាន ៤ បទ គឺ:*

*បទទី១ : "សរសើរព្រះបារមី ព្រះមហាក្សត្រខ្មែរ"*

*បទទី២ : "សរសើរការរចនាប្រាសាទបុរាណខ្មែរ"*

បទទី៣ : "សរសើរតម្លៃកាន់ព្រះពុទ្ធសាសនា"

បទទី៤ : "សរសើរការរួបរួមគ្នាក្នុងគ្រាមានចម្បាំង"

ពាក្យកាព្យទាំងបួនបទនេះ គឺត្រូវបានព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់ទទួលស្គាល់នៅក្នុង ឆ្នាំ១៩៤១ តែចំពោះការលើក យកមកគោរពទង់ជាតិ-ភ្លេងជាតិ ជាផ្លូវការតាំងពីទស្សវត្សឆ្នាំ១៩៥០ ក៏ដូចជាអំឡុងឆ្នាំ១៩៩៣ គឺមានតែបីបទប៉ុណ្ណោះ ដោយឡែកចំពោះបទទីបួនគឺ ត្រូវបានកាត់ចោល ឬបំភ្លេចចោល ឬមួយប្រហែលជាកុំឲ្យវែងពេកក៏ថាបាន ព្រោះថាជាធម្មតាបទគោរពទង់ជាតិគេច្រើន តែងឲ្យខ្លីសមស្របតាមពេលវេលាដូចជាបទគោរពទង់ជាតិ "អាស៊ាន" [៣៥] ក៏ដូច្នេះដែរ គឺគណៈកម្មការអាស៊ានទទួលបន្ទុក តែងនិពន្ធកំណត់ត្រឹមតែរយៈពេលមួយនាទីតែប៉ុណ្ណោះតែ មានអត្ថន័យគ្រប់គ្រាន់ទាក់ទងទៅ និងកិច្ចសហប្រតិបត្តិការល្អរវាងបណ្តាប្រទេសអាស៊ាន។

ដើម្បីទុកជាការជូនជ្រាប ខ្ញុំសូមចុះផ្សាយនូវពាក្យកាព្យដើមដែលសម្តេចសង្ឃ **ជួន ណាត** បានកែសម្រួលមាន ០៤ បទដូចខាងក្រោម ៖

---

(៣៥) ប្រសាសន៍លោកសាស្ត្រាចារ្យ ប៉ែន សំអុល ព្រឹទ្ធបុរសរងមហាវិទ្យាល័យត្បូងឃ្មុំ

# NOKOREACH

# នគររាជ

បទភ្លេងសំរាប់រាជ និងសំរាប់ជាតិខ្មែរ

***HYMNE ROYAL ET NATIONAL CAMBODGIEN***

ព្រះពុទ្ធឃោសាចារ្យ "ជួនណាត" តែង

**Paroles Cambodgiennes du vénérable "CHUON-NAT"**

**ADAPTATION MUSICALE**

**de F. PERRUCHOT et J. JEKYLL**





## ទំនុកទី ២

ប្រសាទសីលា　　កំបាំងកណ្ដាលព្រៃ
គួរឲ្យស្រឡៃ　　នឹកដល់យស់សក្ដិមហានគរ
ជាតិខ្មែរដូចថ្ម　　គង់វង្សនៅល្អរឹងប៉ឹងជុំហិរ
យើងសង់យ័មតរ　　ភ័ពព្រេងសំណាងរបស់កម្ពុជា
មហារឫទ្ធិកើតមាន　　យូរអង្វែងហើយ

## ទំនុកទី ៣

គ្រប់វត្តអារ៉ាម ឮតែស្នូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿរជាក់ស្មោះស្មាក់តាមបែបដូនតា
គង់តែទេព្ដា នឹងជួយជ្រោមជ្រែងផ្គុតផ្គង់ប្រយោជន៍ឲ្យ
ផស់ប្រទេសខ្មែរ ជាមហានគរ

## ទំនុកទី ៤

ក្នុងគ្រាក្សេមក្សាន្ត ដូចគ្រាមានបំបាំង
កម្ពុជានឹងបារាំង ជាមិត្តរួមចិត្តមួយ
យោធាក្លាហាន បានបង្ហូរឈាមដោយក្ដីទុក្ខព្រួយ
គង់មានថ្ងៃមួយ នឹងមានជុំនះដូចដើមវិញពុំខាន
ពួកខ្មែរនឹងបាន ជួបជុំគ្នាវិញ

# TRADUCTION

## $1^{er}$ COUPLET

Que le ciel protège notre Roi
Et lui dispense le bonheur et la gloire
Qu'il règne sur nos cœurs et sur nos destinées
Celui qui, héritier des Souverains bâtisseurs,
Gouverne le fier et vieux Royaume

## $2^{e}$ COUPLET

Les temples dorment dans la forêt
Rappelant la grandeur du Moha Nokor
Comme le roc la race khmère est éternelle
Ayons confiance dans le sort du Campuchéa
L'Empire qui défie les années.

## $3^{e}$ COUPLET

Les chants montent dans les pagodes
A la gloire de la Sainte foi Bouddhique
Soyons fidèles aux croyances de nos pères
Ainsi le ciel prodiguera-t-il tous ses bienfaits
Au vieux pays khmer, le Moha Nokor.

## $4^{e}$ COUPLET

Dans la paix comme dans les combats
Le Campuchéa fut l'ami de la France
Le sang de leurs héros ne coula pas en vain
Car un jour se lèvera qui verra le triomphe
Ainsi que l'union de tous les Khmers.

---

Vu pour être annexé au Kram
N° 1 du 12 Décembre 1941
*Signé : N. SIHANOUK*

ដូចបានរៀបរាប់ខាងដើមខ្លះៗហើយថា បើពិនិត្យការពណ៌នាអំពីពាក្យកាព្យទាំងបួនបទនេះខ្ញុំយល់ថា អក្សរភ្លេង បាននិពន្ធដោយចាប់ផ្ដើមពី "Indrodution" "ឃ្លាផ្ដើម" មុនច្រៀង ប៉ុន្តែបើតាមឯកសារមួយផ្សេងទៀត ដែលសរសេរដោយដៃគឺទទួលបានពីសាស្ត្រាចារ្យ **យស ច័ន្ទដារ៉ា** ព្រឹទ្ធបុរសមហាវិទ្យាល័យតន្ត្រីបានបង្ហាញថា បទភ្លេងមានតែបីបទគឺ "ពុំមានភ្លេងផ្ដើម" ទេ តែក៏ពុំមានអ្វីជាការខុសគ្នាច្រើនដែរ។ បើតាមការពិនិត្យទំនុកច្រៀង ឯកសារដែលមានបួនបទខាងដើម គឺបទទី៤មិនត្រូវបានប្រើប្រាស់ ឡើយបានសេចក្ដីថាយើងប្រើតែ៣បទ (ចប់) គឺបទទី១,ទី២, និងទី៣ បើយើងសិក្សាឲ្យស៊ីជម្រៅទាំង៣បទ គឺមានន័យគ្រប់គ្រាន់។ បើតាមការ សន្និដ្ឋាន ឯកសារសរសេរដោយដៃនេះប្រហែលជាធ្វើសម្រាប់តែការហាត់ច្រៀងតែប៉ុណ្ណោះ ព្រោះយើងឃើញថាមានតែមួយចប់[៣៦]។

អាស្រ័យហេតុនេះហើយទើបខ្ញុំបញ្ចូលនូវ សន្ទឹកភ្លេង (អក្សរភ្លេង) និងទំនុកច្រៀងសរសេរដោយដៃមានបីបទមួយទៀត ដើម្បីជាការជូនជ្រាប ។

---

[៣៦] ប្រសាសន៍លោកសាស្ត្រាចារ្យ យស ច័ន្ទដារ៉ា ព្រឹទ្ធបុរសមហាវិទ្យាល័យតន្ត្រី

Perruchot avant 39
début siècle 1900?



# – NOKOREACH –

## – នគររាជ –

១- សូមពួកទេវតា- រក្សាមហាក្សត្រយើង
ឲ្យបានរុងរឿង- ដោយជ័យមង្គល- សិរីសួស្តី-
យើងខ្ញុំព្រះអង្គសូមជ្រកក្រោមម្លប់ព្រះបារមី-
នៃព្រះនរ- បតី វង្សក្សត្រាដែលសាងប្រាសាទថ្ម-
គ្រប់គ្រងដែនខ្មែរបុរាណថ្កើងថ្កាន ។

២- ប្រាសាទសិលា- កំបាំងកណ្តាលព្រៃ-
គួរឲ្យស្រមៃនឹកដល់យសស័ក្តិមហានគរ
ជាតិខ្មែរដូចថ្មគង់វង្សនៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមានយូរអង្វែងហើយ ។

៣- គ្រប់វត្តអារាម- ឮតែសូរស័ព្ទធម៌
សូត្រដោយអំណររំលឹកគុណពុទ្ធសាសនា
ចូរយើងជាអ្នក- ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេវតា- នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរជាមហានគរ ។

## គ. បទនគររាជជាគ្រឹះនៃ ជាតិ សាសនា ព្រះមហាក្សត្រ

*ពាក្យប្រារព្ធ "ជាតិ សាសនា ព្រះមហាក្សត្រ" ពាក្យទាំង ៣ ម៉ាត់នេះ ជាពាក្យមានខ្លឹមសារសំខាន់បំផុត ជាពាក្យមានតម្លៃថ្លៃថ្នូរ ជាពាក្យគួរគោរព ជាអាយុជីវិតនៃជនរួមជាតិទាំងឡាយ ក្នុងប្រទេសនីមួយៗ ដែលគេតែងនាំគ្នាស្ទួយតំកើង ទុកក្នុងទីដ៏ខ្ពង់ខ្ពស់ព្រោះពាក្យទាំង៣ម៉ាត់នេះសុទ្ធតែជាមេពាក្យ ក្នុងពាក្យនីមួយៗសឹងមានសេចក្តីអធិប្បាយវែងឆ្ងាយ ទូលំទូលាយ ប៉ុន្តែខ្ញុំសូមពន្យល់ខ្លីៗ ដូចសេចក្តីទៅនេះ ៖*

*-**ជាតិ**: ប្រែថា "**កំណើត**" សំដៅដល់ជនទាំងឡាយ ដែលរួបរួមគ្នានៅក្នុងប្រទេសនីមួយៗមាន ភាសា អក្សរ សម្បុរ ស្បែក, ច្បាប់សម្រាប់ស្រុក, ទំនៀមទម្លាប់, រដ្ឋាភិបាលរួបរួមគ្នាតែមួយ ដូចជនជាតិខ្មែរយើងនេះជាដើមៗ ការគោរពបូជា "**ជាតិ**" មានចែងជាកំណាព្យក្នុង (ឧបសម្ព័ន្ធទី២)។*

*-**សាសនា**: តាមរូបស័ព្ទប្រែថា "ពាក្យប្រៀនប្រដៅ ពាក្យទូន្មានឱវាទ ឬដំបូន្មាន"។ តាមសេចក្តីគេអាចសំដៅដល់ "លទ្ធិ ឬបញ្ញត្តិរបស់សាស្រ្តាដែលបានតាំងបង្កើតឡើង។ លទ្ធិសាសនាក្នុងលោកមានច្រើនយ៉ាងចំពោះសាសនាធំៗ ដែលមនុស្សលោកគោរពរាប់អានច្រើន គឺសាសនាព្រះពុទ្ធ សាសនាព្រះយេស៊ូគ្រិស្ត សាសនាព្រហ្មណ៍ សាសនាមោហាម្មេទ។ ក្នុងសាសនានីមួយៗ បែកចេញទៅច្រើននិកាយ។ ចំពោះពុទ្ធសាសនា បែកជានិកាយធំៗ ពីរនិកាយ គឺឧត្តរនិកាយ ឬមហាយាន និងទក្ខិណនិកាយ ឬហិនយាន។ ចំពោះជនជាតិខ្មែរ កាន់គោរពរាប់អានពុទ្ធសាសនា បែបហិនយាន ឬថេរវាទ*

ក្នុងកាលមុនសម័យអង្គរ ដរាបមកដល់សព្វថ្ងៃនេះ។ និយាយឲ្យស្រួលស្តាប់ទៅសាសនា គឺជាទម្រង់មួយដ៏ចំណាស់ៗ នៃមនសិការសង្គម ដោយបញ្ជាក់ប្រាប់អំពីសកម្មភាពនានា នៃចរិតលក្ខណៈរបស់មនុស្ស[៣៧]។ បើយើងផ្ទុះបញ្ចាំងសាសនា ដោយផ្អែកលើសម្ភារៈនិយមវិចារវិជ្ជា (វិទ្យាសាស្ត្រ) បានបញ្ជាក់ថា អ្វីៗទាំងអស់មិនមែនអមតៈទេ បានន័យថាសាសនាក៏មិនអមតៈដែរ ពោលគឺគ្រាន់តែលេចឡើងក្នុងលក្ខណៈប្រវត្តិសាស្ត្រមួយជាក់លាក់ឧត្តុង្គឧត្តម ហើយក៏លិចទៅវិញ យោងទៅលើមូលហេតុសង្គម និងប្រវត្តិសាស្ត្រដូចក្នុងប្រវត្តិសាសនានៅកម្ពុជាជាភស្តុតាងក្នុងពេលមានការផ្លាស់ប្តូរសាសនា ក្រោយពីសម័យព្រះបាទជ័យវរ្ម័នទី៧ បន្តិចៗ ការប្រតិបត្តិសាសនាចែងជាកំណាព្យ មានក្នុង (ឧបសម្ព័ន្ធទី៣)។

-**ព្រះមហាក្សត្រ**: តាមរូបស័ព្ទបែប្រា "**ក្សត្រជាធំ ឬស្តេចធំ**" សំដៅដល់ក្សត្រជាប្រមុខរបស់ប្រទេសជាតិ។ តាមន័យសេចក្តី គេអាចពោលសំដៅដល់ព្រះអំណាច ព្រះចេស្តាបារមី ព្រះរាជានុភាព និងព្រះរាជសិទ្ធិក្សត្រផ្សេងៗក្សត្រាក្សត្រី...។ ជនជាតិខ្មែរ តាំងពីក្នុងសម័យបុរាណកាល ដរាបមកដល់សម័យសព្វថ្ងៃនេះ តែងគោរពកោតខ្លាច ព្រះចេស្តាបារមីនៃព្រះមហាក្សត្រ ហើយតំកើងព្រះអង្គទុកក្នុងទីដ៏ខ្ពង់ខ្ពស់បំផុត ជាកំពូលនៃខេមរជនក្នុងកម្ពុជរដ្ឋទាំងមូល។ កាលដែលបទនគររាជរំឭកដល់ ជាតិ-សាសនា-មហាក្សត្រ គឺគុណនាំ

---

(៣៧) ជុចកឿន, មនុស្សសិល្បៈ ជំនឿ, ចេញផ្សាយពីគណៈកម្មការស្រាវជ្រាវសាកលវិទ្យាល័យវិចិត្រសិល្បៈ ឆ្នាំ ១៩៩៣

ឲ្យកើតភាតរភាព និងសាមគ្គីធម៌ ហើយសឹមយើងព្រួតដៃគ្នាកសាងប្រទេសជាតិយ៉ាងម៉ឺងម៉ាត់តទៅ។ របៀបគោរពទង់ជាតិមានចែងក្នុង (ឧបសម្ព័ន្ធទី២)។ ដូច្នេះពាក្យ "**ជាតិ សាសនា ព្រះមហាក្សត្រ**" ជាបាវចនាមួយបែបអភិរក្ស ដែលប្រើរហូតមកដល់សព្វថ្ងៃនេះ គេអាចនិយាយបានថា ទ្រង់ឈប់ធ្វើជាស្តេចលើប្រជារាស្ត្រខ្មែរ បើនិយាយក្នុងន័យសាសនា (ទេវរាជ) ដូចមុនទៀតហើយ ប៉ុន្តែទ្រង់គឺជាព្រះមហាក្សត្រ ជាតិខ្មែរមួយអង្គ វិញ។

បើសិនជាយើងពិនិត្យទៅលើអត្ថន័យ បទគោរពទង់ជាតិ (នគររាជ) ទាំងបីបទនេះ ចំពោះការដែលលើកយក**បទទី១ (សូមពួកទេព្តា រក្សាមហាក្សត្រយើង...)** គឺចង់បញ្ជាក់ប្រាប់អំពីជំនឿរបស់មនុស្ស ទៅលើពពួកទេព្តា និងព្រះមហាក្សត្រខ្មែរ។ ព្រោះថាប្រជាពលរដ្ឋមានជំនឿលើពួកទេព្តាទៅលើពិភពឋានសួគ៌ ដែលតំណាងឲ្យសភាវៈគតិល្អ ហើយតែងតែជួយដល់ជីវិតមនុស្សនៅក្នុងពិភពស្ថានកណ្តាល ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរឡើយ។

និយាយរួមឲ្យតែមនុស្សរស់នៅក្នុងពិភពលោកស្ថានកណ្តាល មានជំនឿ និងគោរពប្រតិបត្តិតាមគន្លងធម៌ ហើយមានទឹកចិត្តឧស្សាហ៍ព្យាយាម ដោយសាងតែផ្លូវកុសលធម៌ គឺពួកទេព្តាតែងតែជួយគ្រប់ពេលវេលា។ ឲ្យតម្លៃខ្ពស់លើមនុស្ស តាមរយៈការលើកសរសើរព្រះបារមីព្រះមហាក្សត្រ ដែលបានមកពីការប្រទានពរពីទេព្តាក៏ដូច ជាសត្តនិករទាំងឡាយព្រោះ ថាកាលដែលបានជាស្តេចហើយកុំឲ្យភ្លេចភ្លាំងស្មារតី កុំកាច់ចង្កូមធ្មុងព្រះនគរ។ កុំបីញីញាក់ទង់ជ័យព្រះនគរកុំរឹបរឹតរាជទ្រព្យក្នុងព្រះនគរគប្បីមានព្រះឥរិយាបថ

ល្អស្មោះត្រង់សប្បុរស ប្រកបដោយសទ្ធាជ្រះថ្លា ជាហេតុឲ្យចម្រើនដល់ព្រះនគរទាំងក្នុងបច្ចុប្បន្ន ក៏ដូចតទៅអនាគតដឹងនូវព្រះទ័យល្អអាក្រក់ និងការគួរ ឬមិនគួរ មិនហួងហែងព្រះរាជទ្រព្យ។

បើអធិប្បាយមានន័យថា សេនាបតី និងសេនាទាហាន ឈ្មោះថាជាចង្កូម ធ្មុងព្រះនគរ។ ព្រះរាម និងព្រះរាជបុត្រជាថ្ងើម ទ្រូងព្រះនគរ។ អ្នកប្រាជ្ញបុរោហិត ចេះព្រះត្រៃបិដក ឬអ្នកកវីនិពន្ធឈ្មោះថា ភ្នែក ប្រមុះ មាត់ ត្រចៀក ព្រះនគរ។ សេដ្ឋី គហបតី ជាឆ្អឹងសរសៃព្រះនគរ។ មហាឥសីមុន្នី (អ្នកចេះដឹង) ជា**ទង់ជ័យ**ព្រះនគរ។ បណ្ដារាស្ត្រ ឈ្មោះថាជាស្បែកព្រះនគរ។ ជំពូកជនទាំងអស់នេះ កុំជិះជាន់ សង្កត់សង្កិនឲ្យកើតក្ដៅក្រហាយ ឲ្យផ្សាយព្រះហឫទ័យមមៃមមាញឹក នឹកអាណិតគ្រប់ពួកគ្រប់ក្រុម។ បួងសួងដល់ទេព្ដាដែលរក្សាស្វេតច្ឆត្រ នូវទេព្ដាធកាមាសួគ៌ទាំង ១៦ ជាន់ សូមបង្អុរភ្លៀង ផ្គរ ឲ្យស្រួលបរិបូរណ៍ក្នុងព្រះនគរ ទើបមានឈ្មោះថា ជាក្សត្រដ៏ប្រសើរប្រកបដោយនូវធម៌។ រីឯ **បទទី២** ដែលបានរៀបរាប់អំពី "**ប្រាសាទសិលាកំបាំងកណ្ដាលព្រៃ...**" គឺបានលាតត្រដាងបញ្ជាក់ឲ្យឃើញច្បាស់ថា ទឹកដីព្រះរាជាណាចក្រកម្ពុជា ពិតជាមានអំណោយផលពីធម្មជាតិច្រើន ដែលធ្វើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋមានលក្ខណៈងាយស្រួលនៅក្នុងជីវភាពប្រចាំថ្ងៃ។ ជាពិសេសគឺសម្បូរទៅដោយជំនឿ, វប្បធម៌, សិល្បៈ, ទំនៀមទម្លាប់ប្រពៃណីដ៏ច្រើនអនេក ដូចឃើញមាននូវមរតកវប្បធម៌ ប្រាសាទបុរាណជាដើម។ ប្រាសាទទាំងនេះ គឺមាននៅរាយប៉ាយពាសពេញផ្ទៃ ប្រទេសតាំងពីសម័យបុរាណតរៀងមកដល់បច្ចុប្បន្ននេះ ជាសក្ខីភាពបញ្ជាក់

ឲ្យឃើញថា ប្រជារាស្ត្រខ្មែរពិតជាមានស្នាដៃ និងមានវីរភាពអង់អាចក្លាហាន តស៊ូព្យាយាម និង ពុះពារគ្រប់ការលំបាកទាំងអស់ ដើម្បីកសាងប្រាសាទសិលាទុកជាទីសក្ការៈ គោរពបូជារបស់ព្រះមហាក្សត្រខ្មែរ ក៏ដូចជាប្រជារាស្ត្រខ្មែរទូទៅ។ ដោយឡែកចំពោះ**បទទី៣** ដែលបានរៀបរាប់ថា "**គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌...**" គឺបានបញ្ជាក់យ៉ាងប្រត្យក្សភាពថា ប្រជារាស្ត្រខ្មែរគឺជាអ្នកមានជំនឿទៅព្រះពុទ្ធសាសនា ហើយតែងតែគោរពប្រណិប័តន៍តាមគន្លងធម៌ព្រះពុទ្ធអង្គ ដែលជាព្រះបរមគ្រូនៃយើងទាំងអស់គ្នា។ ពីព្រោះថាព្រះអង្គតែងតែប្រៀនប្រដៅមនុស្សលោកឲ្យសាងតែអំពើល្អ ហើយត្រូវតែសន្សំកុសលផលបុណ្យ ដើម្បីបច្ចុប្បន្នជាតិនិងអនាគតជាតិឲ្យរស់នៅក្នុងពិភពឋានបរមសុខគ្រប់ពេលវេលា។ ម្ល៉ោះហើយបានជាប្រទេសកម្ពុជា កសាងទីវត្តអារាមនៅពាសពេញផ្ទៃប្រទេស គឺនាំឲ្យមនុស្ស តែងតែធ្វើតាមបណ្តាំមរតកដូនតា ដោយនាំគ្នាទៅទីវត្តអារាមដើម្បីរំឭកគុណព្រះពុទ្ធ និងបួងសួងសុំសេចក្តីសុខសប្បាយទៅតាមបំណងប្រាថ្នារបស់បុគ្គលនីមួយៗ ការបួងសួងនេះ គឺមិនត្រឹមគ្រាន់តែបួងសួងដល់ព្រះពុទ្ធប៉ុណ្ណោះទេ គឺថែមទាំងបួងសួងដល់ទេព្តានិងវត្ថុសក្តិសិទ្ធិនានាក្នុងលោក ដើម្បីជួយដល់សង្គម ឲ្យជួបតែសុភមង្គលគ្រប់ពេលវេលា។

រួមសេចក្តីមក នៅពេលណាយើងបានបួងសួងព្រះពុទ្ធ និងទេព្តា យើងត្រូវជួយខ្លួនឯងទៀតផង ទើបអាចទទួលបានជោគជ័យសេចក្តីសុខចម្រើន សមដូចបំណងប្រាថ្នារបស់ខ្លួន។ ការគោរពរំឭកដឹងគុណនេះ គឺមានន័យជាការផ្សារភ្ជាប់អ្នករស់ទៅនឹងអ្នកស្លាប់

គឺសំដៅទៅដល់ដីដូនដីតា អ្នកប្រាជ្ញកវី រូបសំណាកអ្នកស្នេហាជាតិ។ កាលបើយើងបានចងចាំនូវប្រវត្តិសាស្ត្រជាសំខាន់ហើយនោះ ធ្វើឲ្យជាតិរឹងមាំនៅគង់វង្ស ស្ថិតស្ថេរ តែបើយើងមិនដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនទេ គឺជាបុព្វហេតុនាំឲ្យបរទេសគេច្បាស់ជាឈ្លានពានយកទឹកដីជាក់ជាពុំខាន និយាយឲ្យខ្លី គឺផ្សារភ្ជាប់អតីតកាលមកបច្ចុប្បន្ន ដើម្បីបន្តទៅអនាគតក្នុងការរក្សាការពារទឹកដី គឺទម្លាប់មិនឲ្យភ្លេចជាតិ។

ដោយហេតុថាទង់ជាតិត្រូវបានគេគោរពយ៉ាងសម្រិតសម្រាំងយ៉ាងដូច្នេះហើយ រាល់បទភ្លេងជាតិមិនត្រូវបានគេយកមកច្រៀងលេងសើចបានឡើយ ហើយរាល់បទភ្លេងជាតិនេះត្រូវមានក្បួនខ្នាតត្រឹមត្រូវ ទើបអាចយកមកចាក់ផ្សាយជាសាធារណៈបាន។ សូមបញ្ជាក់ថា ភ្លេងជាតិដែលត្រឹមត្រូវ គឺច្រៀងឲ្យត្រូវតាមពាក្យពេចន៍ដែលគេបានតែង ហើយនិងលំនាំបទភ្លេង (Menody)។

# សេចក្តីសន្និដ្ឋាន

ការធ្លាក់ចុះនៃអារ្យធម៌អង្គរ កម្ពុជាក្លាយជាប្រទេសដ៏តូចមួយ ក្នុងចំណោមប្រទេសតូចៗដទៃទៀតនៅអាស៊ីអាគ្នេយ៍ ដែលងាយរង ទទួលឥទ្ធិពលពីបរទេស។ ទីតាំងភូមិសាស្ត្រពងបាតថ្នាំងខ្ទះ ហាក់ ដូចជាងាយស្រួលផ្ទុកនូវទឹក ឬក៏កាកសំណល់ផ្សេងៗដែលហូរពី ប្រទេសនានា ព្រោះតែស្ថិតនៅចន្លោះកណ្ដាលនៃប្រទេសដែលមាន មហិច្ឆតាពីរ គឺវៀតណាម និង ថៃឡង់ដ៍ ។ បើពិនិត្យមើលស្ថានភាព ភូមិសាស្ត្រខ្មែរ គឺមានលក្ខណៈប្រហាក់ប្រហែល និងស្ថានភាព ភូមិសាស្ត្រនៃប្រទេស ប៉ូឡូញដូច្នោះដែរ គឺស្ថិតនៅចន្លោះប្រទេស មហិច្ចតាពីរ គឺអាឡឺម៉ង់ និង រុស្ស៊ី ។

ហេតុនេះហើយ បើយើងដេករាប់នូវព្រឹត្តិការណ៍ទាំងឡាយ នៃប្រវត្តិសាស្ត្រកម្ពុជា ឃើញថាមានការផ្លាស់ប្តូរនូវរបបនយោបាយ ជាបន្តបន្ទាប់ ប្រសិនបើគេយកទៅចាត់ចំណាត់ថ្នាក់នៅក្នុងឯកត្តកម្ម ពិភពលោក អាចរាប់បានថា "ជាប់ចំណាត់ថ្នាក់លេខ១ លើពិភព លោកក៏ថាបាន"។ អ៊ីចឹងហើយទើបគេចាត់ទុក "**ទង់ជាតិ-ភ្លេងជាតិ**" គឺជាគ្រឿងសម្គាល់ នូវរបបនយោបាយសង្គម ។

ក្នុងទិដ្ឋភាពនយោបាយគឺ "**ទង់ជាតិ-ភ្លេងជាតិ**" ជាគូនឹងរបប នយោបាយសង្គម ប្រៀបដូចជាព្រៃ និងសត្វដូច្នោះដែរ បើកាលណា ព្រៃត្រូវបានភ្លើងឆាបឆេះ ច្បាស់ជាសត្វត្រូវរត់ចេញពីព្រៃជាក់ជាពុំ ខាន ។

ទង់ជាតិក៏ជាសញ្ញាប្រាប់បញ្ជាក់អំពីគំនិតទស្សនៈ ដោយពុំចាំបាច់ទាមទារឲ្យមានការពន្យល់វែងឆ្ងាយពេកទេ ដូចជាគេប្រើទង់នៅក្នុងសង្គ្រាម និងពិធីអបអរសាទរផ្សេងៗ។ នៅក្នុងសង្គ្រាម "ទង់ជាតិ" កំណត់នូវភាព "ឈ្នះ-ចាញ់" ដូចជា ក្នុងករណីសង្គ្រាមកម្ពុជា-ថៃ ពីថ្ងៃទី០៤-០៧ កុម្ភៈ ២០១១ គឺថៃបានប្រើប្រាស់កម្លាំងទ័ព ចូលមកឈ្លានពាន ទម្លាក់ទង់ជាតិកម្ពុជាចេញពីវត្តកែវសិក្ខាគិរីស្វារៈ ជាលទ្ធផលឃើញថា ថៃពុំអាចទម្លាក់ទង់ជាតិកម្ពុជាចេញពីវត្តបានទេ គឺបានន័យថា "ថៃចាញ់សង្គ្រាមកម្ពុជា" ព្រោះទង់ជាតិកំណត់នូវអធិបតេយ្យភាពដែនដី បើសិនទង់ជាតិដួលរលំ គឺទឹកដីក៏ត្រូវបាត់បង់ទៅតាមនោះដែរ ហើយទង់ជាតិផ្សេងទៀត ក៏នឹងត្រូវបានយកមកដាក់តាំងបង្ហាញជំនួសវិញ ដើម្បីបញ្ជាក់ក្នុងអត្ថន័យថ្មីនៃអធិបតេយ្យភាពដែនដី។

ក្នុងសង្គ្រាម ទង់ដែលគេទាំងអស់គ្នាស្គាល់ គឺ "ទង់ស" ជាទង់សញ្ញាសម្រាប់សុំចុះចាញ់ ជាសញ្ញាមានលក្ខណៈ "អន្តរជាតិ" ការលើកទង់នេះឡើង គឺការសុំក្តីមេត្តាដើម្បីកុំឲ្យគេបាញ់ប្រហារមកលើខ្លួន។ "ទង់ស" ពុំត្រូវបានគេរៀបចំទុកជាមុនទេ។ ក្នុងករណីចាំបាច់ គេប្រើប្រាស់អ្វីដែលមាន ក៏គេអាចរាប់ថាជា "ទង់ស" បានដែរ ។

ទង់បង្ហាញពីភាពឃោរឃៅគឺ "ជូលី រូជើ" "Jolly Roger" ទង់របស់ចោរសមុទ្រមានពណ៌ខ្មៅ និមិត្តរូបគ្មានក្តីអាណិតអាសូរ មេត្តាចំពោះអ្នកដែលប្រកែកប្រឆាំង។ ការប្រើប្រាស់ទង់ជាតិ មានអត្ថន័យច្រើនបែបច្រើនសណ្ឋានណាស់ បើនិយាយឲ្យងាយស្តាប់គឺអាស្រ័យទៅតាមដើមការបញ្ញត្តិនៃកម្មវិធីនីមួយៗ ដូចជានៅពេលមានគណៈ-

ប្រតិកូលំដាប់ថ្នាក់ជាតិមកបំពេញទស្សកិច្ចផ្លូវការ គឺទង់ជាតិនៃប្រទេសទាំងនោះ ត្រូវបានគេដាក់តាំងបង្ហាញ និងគោរពផងដែរក្នុងន័យស្វាគមន៍ និងគោរពគ្នាទៅវិញទៅមក។ ទន្ទឹមនឹងនោះដែរយើងឃើញថា ទង់ជាតិរបស់រដ្ឋមួយត្រូវបានគេបង្ហូតឡើង និងភ្លេងជាតិ ត្រូវបានគេបន្លឺឡើង នៅទីណាដែលជនជាតិនោះត្រូវបានគេទទួលស្គាល់ដូចជាក្នុងផ្នែកកីឡាអន្តរជាតិជាដើម។

នៅក្នុងប្រព័ន្ធជំនឿខ្មែរ "ទង់ជាតិ" ជាវត្ថុស្ថិតនៅទីដ៏ខ្ពស់ទោះបីការប្រើប្រាស់ជាលក្ខណៈម្តងម្កាល ឬជាប្រចាំក្តី គឺទង់ជាតិត្រូវបានគេចងភ្ជាប់ទៅនឹងដង ឬចង្ក្រងទឹងខ្សែឲ្យផុត ពីដីហើយពាក្យ "លើកឬព្យួរ" មានន័យថាធ្វើឲ្យខ្ពស់ឡើង។

ដូចជាទង់ជាតិ ត្រូវបានតម្រូវឲ្យប្រជារាស្ត្រទូទាំងប្រទេសបង្ហូតឡើងនៅមុខគេហដ្ឋាន ស្ថាប័នរដ្ឋ ឯកជននានា ទូទាំងប្រទេសនៅទិវារំឭកបុណ្យឯករាជ្យជាតិថ្ងៃ០៩ វិច្ឆិកា ឬ ក៏ទិវាបុណ្យជាតិធំៗជាផ្លូវការជាដើម។ ទង់ជាតិត្រូវបានគេសម្រិតសម្រាំងបង្ហូតឲ្យខ្ពស់ត្រដែតឡើង ដូចជានៅក្នុងទស្សនៈខ្មែរ អំពីព្រហ្មញ្ញសាសនាថាសេចក្តីល្អពិសេសរបស់ព្រះព្រហ្មណ៍គឺ "ស្ថិតនៅឋានសួគ៌"។ រីឯការបង្ហូតទង់ជាតិ អមដោយភ្លេងជាតិ ឬហៅថា "គោរពទង់ជាតិ" មានសេចក្តីថា "ទង់ជាតិ និង ភ្លេងជាតិ" ជាគូតែមួយ ប្រៀបដូចជាខ្លួននិងព្រលឹងដូច្នេះឯង ហើយក៏ជាការពិតណាស់ថា គឺជាការប្រកូកប្រកាសដល់អ្នកនៅឋានសួគ៌។ ដូច្នេះការលើកទង់ជាតិ ជារឿងភ្ជាប់ទំនាក់ទំនងទៅឋានសួគ៌ ដោយសារទង់ជាតិក្នុងពេលលើក គេធ្វើឲ្យ

ទង់ជាតិបុកភ្លោះទៅឋានសួគ៌ ដូច្នេះការគោរពទង់ជាតិអមដោយភ្លេងជាតិគឺពុំមានន័យថាធ្វើឲ្យពីរោះស្តាប់ឬសប្បាយរីករាយនោះទេ។

ពីដើមគេរចនាទង់ជាតិ ដោយគូរនឹងខ្មៅដៃ ប៊ិច តែបច្ចុប្បន្នគេប្រើកុំព្យូទ័រ។ ពណ៌នៃទង់ជាតិ មានសារៈសំខាន់ណាស់ ដូចជាពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាជាដើម។ ជាច្រើនឆ្នាំមុនគេដេរទង់ជាតិដោយដៃមានប៉ាក់ជាយ ឬលាបពណ៌។ បច្ចុប្បន្ន គេបោះពុម្ពទង់ជាតិពីក្រណាត់កី រត់តាមម៉ាស៊ីនពុម្ព ដែលអាចបោះពុម្ពចេញជដែលៗសារជាថ្មីដូចៗគ្នា ហើយសាច់ក្រណាត់អាចបោកគក់សម្ងួតបាន ។

ហេតុនេះ ដោយ"ទង់ជាតិ-ភ្លេងជាតិ" ជាគ្រឿងសម្គាល់យ៉ាងសំខាន់សម្រាប់ជាតិ ដូច្នេះគោងខ្មែរត្រូវគោរពទង់ជាតិ-ភ្លេងជាតិ ឲ្យបានម៉ឺងម៉ាត់ ទៅតាមម៉ោងក្នុងកម្មវិធីនីមួយៗ ដែលបានកំណត់ ហើយនាំគ្នាចាប់យក ទង់ជាតិ-ភ្លេងជាតិ នគររាជ ដាក់ក្នុងថ្លើមប្រមាត់ទុកជាត្រីវិស័យក្នុងការឯកភាពជាតិរំឭកដល់សម័យអង្គរគ្រប់ៗគ្នា ដូចពាក្យកាព្យបទ នគររាជ ចែងទុកមកថា "...ជាតិខ្មែរដូចថ្ម..." មានន័យថា អង្គរវត្តដែលរឹងមាំរហូតមកដល់សព្វថ្ងៃ គឺដោយសារថ្មមួយដុំៗរឹងមាំជាប់លាប់ជាបន្តបន្ទាប់គ្នាជាធ្លុងមួយ ប៉ុន្តែក្នុងនោះបើមានថ្មដុំណាមួយ បាក់បែក ពុកផុយ ច្បាស់ជាបង្កបញ្ហាដល់លំនឹងទ្រង់ទ្រាយអង្គរជាពុំខាន ។

សូមជនរួមលោហិតខ្មែរ បន្ទឹបទនគររាជគ្រប់ៗរូប ដើម្បីដាស់នូវមនសិការជាតិ ដោយគិតអំពីអត្ថប្រយោជន៍ជាតិមុនអ្វីៗទាំងអស់។

សូមបទនគររាជ ក្លាយជាជន្ទុលទ្រកម្លាំងសាមគ្គីជាតិឯកភាពខ្មែរជាធ្លុងមួយ   ដូចសម័យមហានគរដ៏រុងរឿងនៃយើងតរៀងទៅហោង ។

ឧបសម្ព័ន្ធទី១

# ជំនុំគាថចម្រៀង

## "អ្ហែ"

I - បទទី១ : អ្ហែទី ១

អ្ហែ...... អើយ សម្ដេច ព្រះរាជា គង់នាវាល្អឆើតឆាយ

ហែ ហែ ហែ ហែ......ល្អឆើតឆាយ ។

ពួកពល សុកលកាយ សឹងរៀបថ្វាយ បំរុងការណ៍

ហែ ហែ ហែ ហែ...... បំរុងការណ៍។

ទូកទិព្វ សុទ្ធសឹងមាស ច្រាលពេញពាស លើជលសារ

ហែ ហែ ហែ ហែ...... លើជលសារ។

II - បទទី២ : សុវណ្ណហង្ស

សុវណ្ណហង្ស អង្គស្នួយស្មើត ទើបន្ទើប លើនាវា

ហាក់ហង្ស អង្គព្រហ្មា លេលាលយ ដោយនាភា

ទីនាំងម្កុរ ល្អប្រាកដ ដូចហារមាត់ ពាំកែវមុនី

លូនលេច លើនាវា គួរជាទី ទស្សនាការណ៍ ។

III - បទទី៣ : ផាត់ សុផាន់

ទស្សនា មច្ឆាជាតិ ហែលមិនឃ្លាតពីគូវា និងស្ងួនភ្ងារ

ជាគូគាប់ជាប់សួរវង្ស។

ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ អឺ អឺ អើង អើយ

ជាប់សួរវង្ស។

ត្រីឆ្អិន សាច់ដូចមាស មិនវិលាស ដូចឆោមយង់

ល្អសមទ្រង់ ល្អវង្សភ័ក្ត្រ មានលក្ខិណា

ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ អឺ អឺ អើង អើយ

មានលក្ខិណា។

ប្រាព្រួល ប្រែព្រួយចិត្ត នឹកអាណិត អាណាថា អាណុង

នៅឯកា នរណានឹង នៅនែបនិត្យ

ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ អឺ អឺ អើង អើយ

នៅនែបនិត្យ។

រាជរាស់ដូចរៀមរ័ក ចិត្តជំពាក់ ស្នេគ្រជាប់ចិត្ត កេសកែ

គូជីវិតកែវគិតរៀម ស្ងៀមស្ងួតក្រៃ

ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ ហេ អឺ អឺ អើង អើយ

ស្ងៀមស្ងួតក្រៃ។

ឧបសម្ព័ន្ធទី ២

# បទកាកគតិ

## "ជាតិ"

ជាតិកម្ពុជា ធ្លាប់ល្បីនាមា អំពីព្រេងនាយ
សម័យអង្គរ ល្បីខ្ចរសុះសាយ ជាតិយើងសប្បាយ
ថ្កើងបុណ្យថ្កើងសក្តិ។

ជាតិកម្ពុជា ធ្លាប់ល្បីនាមា រួមចិត្តស្មោះស្ម័គ្រ
សាងប្រទេស ឥតធ្វេសគ្មានអាក់ ជាតិខ្មែរបែរភ័ក្ត្រ
ទាន់កាលសម័យ។

ជាតិកម្ពុជា ធ្លាប់ល្បីនាមា ដោយសារស្នាដៃ
កសាងប្រាសាទ សាងស្អាតថ្លាថ្លៃ ឆ្លាក់ថ្មចរណៃ
ល្អឯកក្នុងលោក។

ជាតិខ្មែរឥឡូវ ត្រូវដើរតាមផ្លូវ គន្លងជ័យជោគ
ព្យាយាមកសាង យ៉ាងសម័យគោក ធ្លកខ្មែរសាងលោក
ទុកកេរកូនចៅ។

ឱបងប្អូនខ្មែរ គួរគិតកែប្រែ គំនិតឲ្យជ្រៅ
ព្រួតដៃបងបាច់ ញាតិសាច់ពង្សផៅ រួមជនក្នុងក្រៅ
កសាងជាតិយើង។

បងប្អូនរួមជាតិ ត្រូវខំខ្មីឃ្មាត ស្ទួយជាតិឲ្យថ្កើង
ឲ្យខ្មែរបែរភ័ក្ត្រ កាន់ថ្នាក់ខ្ពស់ឡើង រុងរឿងជាតិយើង
ជយោជាតិខ្មែរ ! ។

ឧបសម្ព័ន្ធទី ៣

# បទព្រហ្មគិត

## "សាសនា"

ព្រះពុទ្ធសាសនាយើង ត្រូវតំកើងដោយគោរព
ទីពឹងនៃត្រៃភព ប្រសើរក្រៃថ្លៃឧត្តម។
ជាតិខ្មែរទាំងប្រុសស្រី ក្មេងចាស់ក្តីត្រូវប្រឹងខំ
សិក្សាឲ្យដំណំ កុំប្រឡំខុសជាត្រូវ។
បុព្វជិតគិតប្រឹតប្រៀន សង្វាតរៀនប្រតិបត្តិផ្លូវ
មគ្គផលដែលនាំទៅ ឋាននិព្វានគ្មានទុក្ខសោក។
គ្រហស្ថត្រូវប្រឹងប្រែង ប្រុងស្វះស្វែងជួយផ្តល់លោក
ភោជន៍ភ័ស្តុគ្រឿងបរិភោគ គឺបច្ច័យទាំង ៤យ៉ាង។
ព្រះសង្ឃជាស្រែបុណ្យ យើងចុះទុនព្រោះសាបសាង
កើតផលឃើញភស្តុតាង ក្នុងលោកនេះនិងលោកនាយ
ព្រះពុទ្ធទ្រង់ទេសថា ការសាសនាល្អពណ្ណរាយ
ឬរៀវរោយរាយមាយ ដោយបរិស័ទទាំងបួនប៉ែក។
ហេតុនេះត្រូវស្រុះស្រួល កុំបបួលគ្នាបំបែក
សាមគ្គីជាបង្អែក ទើបសាសន៍ជាតិយើងរុងរឿង។

ឧបសម្ព័ន្ធទី ៤

# គោរពទង់ជាតិខ្មែរ

ដល់ពេលវេលាលើកទង់ ពួកយើងឈរប្រុងៗទាំងអស់គ្នា (២ដង)
ស្មារតីគោរពទង់ជាតិ កម្ពុជាអើយយើងទាំងអស់គ្នា
គោរពទង់ជាតិខ្មែរៗ

(ច្រៀង ២ដង)

# សន្ទានុក្រម
# (GLOSSARY)

"ក"

-ក្សត្រ : ព្រះមហាក្សត្រ ឬស្ដេចធំ សំដៅដល់ក្សត្រជាប្រមុខរបស់ប្រទេសជាតិ

"ខ"

-ខេន (ken) : ជាកុសលសម្ព័ន្ធរស់នៅភាគពាយ័ព្យនៃប្រទេសអង់គ្លេស នៅសម័យនោះជនជាតិ ken ទោះក្នុងវណ្ណៈសង្គមក៏ដោយពួកគេកោតស្ញប់ស្ញែងតន្ត្រី អ្នកចម្រៀងជាពួក Voix ទាំងនេះណាស់។ ហើយត្រូវមជ្ឈឹមចាប់បង្ខំអនុវត្តនរបបសមាហរណកម្ម ជាតិសាសន៍រហូតធ្វើឲ្យជាតិសាសន៍ទាំងនេះងើបឈរពើបម្រះដើម្បីរក្សាអត្តសញ្ញាណ សម្បត្តិវប្បធម៌ សិល្បៈមានក្មេងផងដែរ។

"គ"

-គ្រហឹម : សម្លេងរន្ទឺ

"ច"

-ចតុរង្គ : ពិធីនៃកម្លាំងទ័ពទាំងបួនអង្គ គឺទ័ពដំរី ទ័ពសេះ ទ័ពរថឬ រទេះទ័ពថ្មើរជើង ។

- ចម្រៀង : ការច្រៀងបញ្ចេញសម្លេងរាយទំនុកឲ្យឮមានខ្ពស់ទាប ។

-ចាមរ : ជាគ្រឿងមួយប្រភេទមានរាងដូចជាផ្ចិតសម្រាប់មន្ត្រីរាជាគណៈកំពូលស្រួចនិងជាយផែកជុំវិញមានដងវែង សម្រាប់ក្បួនហែក្នុងព្រះរាជពិធីផ្សេងៗ មានព្រះរាជាភិសេក ជាដើម។

"ជ"

-ជីវចលនិយម : ព្រលឹងនិយមគោរព អ្នកតាម្ចាស់ស្រុក ដំបូកទួលខ្ពស់។

-ជាតិ : កំណើត

"ទ"

-ទង់ : ជាគ្រឿងសម្គាល់នៃប្រភេទទង់មានឈ្មោះផ្សេងៗ ដូចជាទង់សាសនា, ទង់ជាតិ, ទង់ជ័យ, ទង់មហារាជ, ទង់សាសនា, ទង់ផ្កាលា, ទង់ប្រចាំកង...។

-ទង់មហារាជ : ទង់សម្គាល់សម្រាប់ព្រះមហាក្សត្រម្ចាស់ដែនដី

-ទង់ជាតិ : ជានិមិត្តសញ្ញា ឬរូបតំណាងឲ្យប្រទេសនីមួយៗ មានលក្ខណៈ គឺ ជាផ្ទាំងសំពត់ ឬចម្រៀកសំពត់ដែរគេដេរឲ្យមាន សណ្ឋាន ជាពណ៌ ជារូបភាពផ្សេងៗ ធ្វើដោយក្រដាសក៏ហៅថា ទង់ជាតិដែរ។

-ទង់ជ័យ : ទង់ប្រសិទ្ធីជាប្រធានជ័យជម្នះនៃសង្គ្រាមដូចជា នៅពេលបានជ័យជម្នះទង់ជាតិភាគីមួយត្រូវបានទម្លាក់ចុះដាក់ជំនួសវិញនូវទង់ជ័យភាគីឈ្នះជាការបង្ហាញពីភាពឈ្នះ-ចាញ់នៃសង្គ្រាម។

-ទង់ក្រពើ : ទង់មានរាងដូចក្រពើ និយាយទង់នេះ ទាក់ទងនិង សពហៅថា "ទង់សព" ឬ "ទង់ស" ។

-ទាក់ទាម : ទើសទាល់គំនិត។

"ត"

-ត្រៃវង្គ : បីពណ៌ដូចជាទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈជា ត្រៃវង្គពណ៌ស ក្រហម ខៀវ។

-តន្ត្រី : tamtri ( សំ. តន្ត្រិន, បា. តន្ត្រី) ភ្លេងមានខ្សែគ្រឿង ភ្លេង ដេញ ផ្លុំ គូត....។

"ប"

-បៃមន់ : ជាប្រដាប់មួយប្រភេទមានសណ្ឋានដូចស្លឹកមនស្រដៀង និងចាមរ។

-បទនគររាជ : បទស្តេចអង្គរជាភ្លេងជាតិមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារំលឹកដល់អតីតភាពរបស់កម្ពុជា ដែលជាប្រទេសមានឥស្សរភាពរុងរឿងតាំងពីបុរមបុរាណមក។

"ព"

-ព្រះភ្លើង : ជាក្រុមក្មេងពេលចេញច្បាំង ដើម្បីលើកទឹកចិត្តទ័ព ដង្ហែមុខក្បួនទ័ពជាមួយក្រុមអ្នកកាន់ទង់មានលក្ខណៈដូចទ័ពដែរ។

-ព្រលឹង : មានស្រីស្ងួស្តី ដែលជាទីស្រលាញ់ស្មើជីវិត

"ភ"

-ភ្លេង : ឧបករណ៍នៃសម្លេង ឬ សូរ

-ភ្លេងជាតិ : ភ្លេងនិមិត្តរូបជាតិ ត្រូវបានប្រកាសឲ្យប្រើស្រប តាមរដ្ឋធម្មនុញ្ញ

-ភាសា : សម្តី

-ភុជុងនាគ : ពិភពនាគ

-ភារតៈ : ឈ្មោះរឿងនិទានមួយ មានសេចក្តីពិស្តារវែងឆ្ងាយនៅប្រទេសឥណ្ឌាពីព្រេងនាយ ទាក់ទងដោយពូជពង្សមហាក្សត្រព្រះនាម ភារតៈខ្មែរក្នុងសម័យបុរាណ រាប់អានគោរពជារឿងសក្តិសិទ្ធិ

"ម"

-មូឌីសវីវេនឌី (Modus Viendi) : ការទទួលស្គាល់ស្វ័យភាពផ្ទៃក្នុងរបស់កម្ពុជាពីអាណានិគមនិយមបារាំងសែស

"រ"

-រាជរថ : យានជំនិះព្រះមហាក្សត្រ

-របាំ : ល្បែង ច្រៀង រាំ

"វ"

-វរ្ម័ន : អ្នកការពារ ឧ. ជ័យវរ្ម័នទី៧ គឺជាអ្នកការពារជ័យជម្នះ

-វានរកេតុ : ទង់ពានរ ឬ ទង់ហនុមាន

-វត្តកែវសិក្ខាគិរីស្វារៈ : វត្តព្រះពុទ្ធសាសនា កសាងឡើងក្នុងឆ្នាំ១៩៩៨ ស្ថិតនៅទីតាំងប្រាសាទព្រះវិហារ ជាទីកន្លែងសក្ការបូជា នៃអាទិទេពភ្នំ ព្រះឥសូរ

"ស"

-សង្គមរាស្ត្រនិយម : ជាឈ្មោះរបបមួយនៃការគ្រប់គ្រងប្រទេសកម្ពុជា ឯករាជ្យ អព្យាក្រឹត្យ សង្គមនិយមព្រះពុទ្ធ សាសនា ដ៏បរិសុទ្ធ ស្អាត ។ សង្គមនេះមានប្រាកដឡើងក្នុងកាល ព.ស២៤៩៩ គ.ស ១៩៥៥ ដោយសម្តេចឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ព្រះអង្គជាព្រះអគ្គមហាប្រធាន។

-សត្តន្តបិដក : ឈ្មោះគម្ពីរព្រះពុទ្ធសាសនា ក្នុងព្រះត្រៃបិដក ទាំងបីផ្នែក គឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម។

-សាមគ្គីភេទ : ការបែកបាក់សាមគ្គី

-សាសនា : ពាក្យប្រៀនប្រដៅ ទូន្មាន ឱវាទ ឬដំបូន្មាន

-សុរិយរង្សី : រស្មីព្រះអាទិត្យ

-សែនតួ៌ន : ជាផ្ចិតមានសណ្ឋានមូល ធ្វើអំពីសំពត់ផ្កាមាស ឬប្រាក់ ជាដើមមានក្ងក់ខាងចុងប្រើសម្រាប់បាំងកំដៅថ្ងៃកុំឲ្យចាំងត្រូវ។

-សន្ទូត : កំណាត់ជា

-ស្រី : "ស្រី" ឬ "ក្រី" គឺសំដៅអ្វីដែលប្រសើរខ្ពង់ខ្ពស់ ប្រសើរ ថ្លៃថ្លា ជាមង្គល គឺមិនសំដៅសម្គាល់ភេទ "ស្រី" មកពីពាក្យ "ស្ត្រី" ទេ ។

-ស្គរមហោធិក : ជាឈ្មោះស្គរ ឬ ឈ្មោះមួយប្រភេទ ធ្វើអំពីស្ពាន់ ទង់ដែង និងសំរឹទ្ធ សម័យបុរាណគេប្រើស្គរនេះក្នុងពិធីសុំទឹកភ្លៀងគេហៅថា "ស្គរភ្លៀង" សម្លេងលាន់ឮខ្លាំងណាស់។

-ស្វេតច្ឆត្រ : ជាពិធីមានគ្រឿងសម្គាល់ គឺទី១ មកុដរាជ, ទី២ ព្រះខ័ន, ទី៣ ជើងពាន, ទី៤ ឆ័ត្ររួត, ទី៥ រាជសីហ៍ ឬ គុជសីហ៍

**"ហ"**

-ហ៊ីម (Hymn) : ជាបទសូត្រវិទ្យា សម្រាប់ ច្រៀងថ្វាយដល់អាទិទេព ឬ សរសើរព្រះជាម្ចាស់

-ហីនយាន : យានតូចជានិកាយព្រះពុទ្ធសាសនា

"អ"

-អភិរម្យ : ជាច័ត្រមានរំភាយដូចក្ងស់

-អមនុស្ស : អ្នកតាម្ចាស់ស្រុកកាលពីអតីតកាលក៏ជាមនុស្ស ដូចយើងតែដោយគាត់មានស្នាដៃអ្វីមួយអស្ចារ្យ បន្ទាប់ពីស្លាប់ទៅអ្នកស្រុកនៅតែគោរពគាត់ ហើយគេចាត់ទុកគាត់ជាអ្នកតាម្ចាស់ស្រុក ។

-អតីត : កាលកន្លងទៅ

-អសុរៈ : គំនិតអាក្រក់ ប្រើសំដៅពពួកយក្ស

-អេ្ហ : ជាឈ្មោះបទចម្រៀង "អេ្ហ" ដែលគេច្រៀងដើម្បីរៀបរាប់ពន្យល់អ្វីមួយ គេចែកចេញជាបីបទគឺ បទទី១ : បទអេ្ហ , បទទី២ : បទសុវណ្ណហង្ស និង បទទី៣ : បទផាត់សុផាន់ ៕

# គន្ថនិទ្ទេស ភាសាខ្មែរ


- (គ. ស. ១៩៩៩), ប្រជុំរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា (ពីឆ្នាំ ១៩៤៧-១៩៩៨), ភ្នំពេញ : ខុទ្ទកាល័យសម្តេច ជា ស៊ីម
- (គ. ស. ២០១០), រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ ១៩៤៧-២០០៧, ភ្នំពេញ : ...
- កែវ ណារុំ, (២០១១), តន្ត្រីនៅប្រទេសកម្ពុជា, ភ្នំពេញ: គ្រឹះស្ថានផ្សាយនគរវត្ត
- ក្រុមជំនុំព្រះត្រៃបិដក, (២៥០៨), ព្រះត្រៃបិតក បាលី និងសេចក្តីប្រែជាភាសាខ្មែរអភិធម្មបិតកធាតុកថាបុគ្គលបញ្ញត្តិ, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ចាប ពិន, (១៩៥៩), ប្រវត្តិបទភ្លេងជាតិ-បទនគររាជ, ភ្នំពេញ: ដោយអ្នកនិពន្ធ
- ជួន ណាត (សម្តេចព្រះសង្ឃរាជ), (១៩៦៧), វចនានុក្រមខ្មែរភាគ ១-២, ភ្នំពេញ: ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជួន (សម្តេចចៅហ្វាវាំង),(១៩៣៣),ទំនុកសរសើរព្រះបារមីបទនគររាជ, កម្ពុជសូរិយា, ឆ្នាំទី៦ លេខ១,២,៣ ៦, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ឈន អៀម, (១៩៩៧), ទង់ជាតិសាសនា កម្ពុជសូរិយា, ឆ្នាំទី៥១, ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

- ឈឹម ក្រសេម(ទេពពិទូ), (១៩៤២), ប្រវត្តិទង់ប្រចាំជាតិខ្មែរ (កម្ពុជសូរិយា, ឆ្នាំ ទី១ លេខ ១), ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ឈឹម ក្រសេម (ទេពពិទូ), (១៩៥០), ព្រះរាជពិធីទ្វាទសមាស ភាគ ១-៣, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ឌី ខាំបូលី,(២០០៧),ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩, ភ្នំពេញ: មជ្ឈមណ្ឌលឯកសារកម្ពុជា
- ថង់ វង់, (១៩៦២), ទង់សាសនា ឆ្នាំទី៣៤ លេខ១, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ទីស្តីការគណៈរដ្ឋមន្ត្រី (...) តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ រឿងក្តីប្រាសាទព្រះវិហារ កម្ពុជាទល់នឹងថៃ អង្គសេចក្តីសាលដីកាថ្ងៃទី ១៥ មិថុនា ១៩៦២, ភ្នំពេញ: ទីស្តីការគណៈរដ្ឋមន្ត្រី
- ប៉ាង ខាត់ (ភិក្ខុ), (១៩៦១), ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ប៉ែន ងឿន, (១៩៩៤), ពិភាក្សាបញ្ហាជាតិខ្មែរ, ភ្នំពេញ: ដោយអ្នកនិពន្ធ
- ពុត សុភ័ត្រា, (១៩៦៩), ទង់ព្រះពុទ្ធសាសនា កម្ពុជសូរិយា,ឆ្នាំទី៥០ លេខ២, ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ម៉ិញ នាគ្រី, (១៩៥១), សាសនាគឺជាអ្វី, ភ្នំពេញ: បណ្ណាគារ ប៊ុត នាង
- មីរ៉ុ បេនីស្ទី, (១៩៧០), ទំនាក់ទំនងសិល្បៈខ្មែរដំបូងនិងសិល្បៈឥណ្ឌា: សាលាចុងបូព៌ាប្រទេស

- ស៊ុន សារ៉ាត,(២០០៤), សារណាបរិញ្ញាបត្រផ្នែកតន្ត្រីវិទ្យា ការសិក្សាស្រាវជ្រាវអំពី អក្សរភ្លេង ឆ្នាំសិក្សា ២០០៣, ២០០៤, ភ្នំពេញ : ...
- ហង់គ្រី ម៉ាសាល់, (១៩៥១), ក្បាច់រចនា និងចម្លាក់ខ្មែរ ក្បាលទី៣, ភ្នំពេញ: .
- ហង់ជួន ណារ៉ុន (បណ្ឌិត), (២០០៨), ប្រាសាទព្រះវិហារ, ភ្នំពេញ: ដោយអ្នកនិពន្ធ
- ហួត តាត (ព្រះវិសិទ្ធិវង្ស), (១៩៣៤), សត្តបរិត្ត ទ្វាទសបរិត្ត, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- ឱម សុមេធា, (២០០០), ទង់ព្រះពុទ្ធសាសនា និង ចម្រៀងបង្ហូតទង់, កម្ពុជសុរិយា, ឆ្នាំទី៥៤ លេខ១, ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- អាំង ជូលាន, (២០០៨), សូមកើតមកជាខ្មែរទៀត (លេខ ៣), ភ្នំពេញ: Khmer Renaisance
- អាំង ជូលាន/អេរិក ប្រេណ្សាវិត្យ, (១៩៩៩), អង្គរ-អតីត-បច្ចុប្បន្ន-អនាគត, ភ្នំពេញ: អាជ្ញាធរអប្សរ

# គន្ថនិទ្ទេសភាសាបរទេស


- B.PH.Grolier; Angkor et le Cambodge au XVIe Siède le sources portugaies et Espanoles, Paris, 1958
- Bhat tacharya-K; Les religion brahmaniques dans l'ancien "EFEO" 1961
- BEHEO; XII, 2, 1912
- Charnvit Kasetsiri; Siam/Thai Nationalism and Cambodia a case study of the Preah Vihear Temple Nov, 2008
- C oedès;George;Inscription du Combodge; EFEO
- Groslier;George "La mort de S.M. Sisowath"; L'ILLus tration; Oct-1927
- G. Coedès; Les statues du roi khmer Paris; 1937
- Giteau-M; Iconographie du Cambodge post Angkorien EFEO, 1975
- MBN International 2006-2007
- Paul M. HANDLEY, The King Never Smiles Abiography of Thailand's Bhumibol Adulyadej
- Penny EDWARDS, Cambodge The Cultivation of A Nation, 1860-1945
- Reconnaissances a érien au Cambodge "BEFEO" 1936
- R.GRAHMANN; La préhistoire de l'humanité Paris 1955
- SARIN CHHAK, Les Frontiers du Cambodge, 1966

# អក្ខរក្រម
# INDEX

"ក"

- ក្បូត្រ ៧, ៣២, ១០៦
- ក្ងស់អភិរម្យ ៤៥
- ក្រអួន ១៤
- កម្ពុជរដ្ឋ ១០៦
- កង់ទ័ព ៤, ៧
- កុលសម្ព័ន្ធ ៦
- កំហឹង ២៣, ៦៤
- ក្បួនសឹក ៣៧
- ក្បួនទ័ពបុរាណ ៣៨

"ខ"

- ខេន Ken ១៦
- ខេមរជន ២, ៧៨

"គ"

- គ្រហឹម ១៥, ១៧

- គ្រុឌ ១០, ១១
- គីតសិល្បៈ ២២

"ឃ"

- ឃោរឃៅ ៦១, ១១២

"ច"

- ចក្រពត្តិយោជានិយម ៤៧
- ចក្រពត្តិ ១១
- ចិទម្លរ ១៩
- ចម្បាំង ២៣,២៤,២៧,៣៣,៤៤,៩៧
- ចាមរ ៤៥
- ចតុរង្គ ៣៧

"ឆ"

- ឆន្ទៈ ៥៣, ៦៤

"ជ"

- ជីវចលនិយម ២៥

"ដ"

- ដំរីស ៣៥

"ឋ"


- ឋានសួគ៌ ៥, ៤៣, ១០៧, ១១៣


"ត"


- តំកល់ ៥៩
- តន្ត្រី ១៤, ២១, ២៤, ២៧, ៣០, ៣៧
- ត្រៃវត្ត ៩, ៣៤, ៣៥, ៣៦, ៣៧, ៤៤, ៧០
- ត្រីកោណ ៣៩
- ត្រីវិស័យ ១១៤


"ថ"


- ថយក្រោយ ១១, ១២, ១៣
- ថយកម្លាំង ១១, ១២, ១៣
- ថោកទាប ១១, ១២, ១៣


"ទ"


- ទង់មហាភជ ៨, ៩
- ទង់ជ័យ ៩, ១០, ១១, ១២, ១៣, ៦៨
- ទង់ក្រពើ ៦
- ទង់សាសនា ៥, ៣០

- ទង់ផ្កាលា ៥, ៨, ៣៧
- ទេវកថា ១៧
- ទេវរាជ ១០៧

"ន"

- និគម ១១, ១២

"ប"

- បទនគររាជ ២, ៣០, ៨៣, ៨៤, ៨៥, ៨៦
៨៧, ៨៩, ៩០, ៩១,៩៣
៩៤, ៩៥, ៩៦, ១០៥,
១០៦, ១១៤, ១១៥
- បៃមន់ ៤៥

"ព"

- ព្រះភ្លើង ៧
- ព្រះត្រៃបិដក ១១, ៣១, ១០៨
- ព្រលឹង ២៥, ២៦, ៣០, ៣៦, ៧៦, ១២៣
- ព្រៃភ្នំ ២៦
- ព្រះពិស្ណុការ ១៨
- ព្រះថោងនាងនាគ ២៤

- ព្រះពុទ្ធសាសនា ២៥, ៥៧, ៧២, ៩២, ៩៧, ១០៩, ១១៩

"ភ"

- ភេ្ទជាតិ ១, ២, ៣០, ៣១, ៤០, ៥៦, ៥៨, ៦១, ៦៣, ៦៥, ៦៧, ៧៤, ៨៣, ៨៤, ៨៥, ៨៦, ៨៧, ៩០, ៩២, ៩៣, ៩៤, ៩៧, ១១០, ១១១, ១១៣, ១១៤
- ភុជង្គនាគ ១៧
- ភារតៈ ៦

"ម"

- មគ្គុទេសក៍ ៣
- មាតុគ្រាម ១២, ១៣
- មនោគមវិជ្ជា ២៥

"រ"

- រាជរថ ៧, ៩
- របាំ ១៩

"វ"

- វត្តកែវសិក្ខាគិរីស្វារៈ ៧៥, ៧៦, ១១២

- ហេនរកេតុ ៦

"ស"

- សង្គមរាស្ត្រនិយម ៧៨
- សាមគ្គីភេទ ៤០
- សុរិយវង្ស ៣៤
- សែនតូ៊ន ៤៥
- ស្រី ២, ១១, ១២, ១៤, ២៤, ៩១
- ស្គរមហាធិក ១៨
- សាសនា ៦, ៧, ១១, ១២, ១៣, ១៥, ២៥, ២៦, ៣០, ៣២, ៣៣, ៣៤, ៤២, ៥៧, ៦០, ៧០, ១០៥, ១០៦, ១០៧
- សុគតិភព ១៩
- សាស្ត្រាស្លឹករឹត ២៤
- ស្វេតច្ឆត្រ ៥២, ៥៤, ១០៨

"ហ"

- ហ៊ីម (Hymm) ១៥
- ហ៊ីនយាន ១២០

"អ"

- អាទិទេព ១៥
- អមនុស្ស ២៦, ៣០
- អសុរៈ ៧, ៨
- អ្ហូ ២៧, ២៨, ២៩, ១១៦
- អមតៈ ៧០, ១០៦ ។ល។

"...បើយើងដកទង់ជាតិចេញពីវត្ត កែវសិក្ខាគិរីស្វារៈ
គឺមានន័យស្មើនឹងការដកព្រលឹងជាតិខ្មែរចេញដូច្នេះដែរ..."

(សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន)



9 789996 357206